

# “ខ្ញុំភ័យស្ទើរលស់ព្រលឹងអស់ពីខ្លួន”

## ការសិក្សាស្តីពីអំពើហិង្សាលើយេនឌ័រក្នុងរបប កម្ពុជាប្រជាធិបតេយ្យ នៅខេត្ត បាត់ដំបង និង ខេត្តស្វាយរៀង

កាទ្រីណា ណាតាឡេ
Katrina Natale

## អំពីចំណងជើង

ចំណងជើង "ខ្ញុំភ័យស្ទើរលស់ព្រលឹង" គឺជាសម្ដីដែលអ្នកចូលរួមម្នាក់ ក្នុងចំណោមអ្នកចូលរួមជាច្រើននៅក្នុងការអង្កេតនេះ បានរៀបរាប់អំពីអារម្មណ៍ផ្ទាល់របស់នាង នៅពេលដែលនាងបានប្រទះឃើញនារីម្នាក់ត្រូវទាហានខ្មែរក្រហមមួយក្រុមរំលោភសេពសន្ថវៈ ហើយពេលនោះ នាងដឹងថាខ្លួនគ្មានសមត្ថភាពជួយនារីនោះ។

## រូបថតនៅគម្រប

រូបថតគម្របដែលពិពណ៌នាអំពីអំពើរំលោភសន្ថវៈ ក្នុងសម័យខ្មែរក្រហមត្រូវបានផ្ដល់ឲ្យដោយសហគមន៍មួយនៅក្នុងខេត្តបាត់ដំបង។

## គម្រោងស្ដីពីអំពើហិង្សាលើយេនឌ័រក្នុងរបប ខ្មែរក្រហម ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

គម្រោងស្ដីពីអំពើហិង្សាលើយេនឌ័រត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៩ ហើយគម្រោងនេះមានបំណងឲ្យជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម ចូលរួមក្នុងដំណើរយុត្តិធម៌អន្តរកាលបច្ចុប្បន្នតាមរយៈការតស៊ូមតិ ការអប់រំផ្សព្វផ្សាយផ្សេងៗ និងគំនិតផ្ដួចផ្ដើមផ្ដល់ជំនួយដោយផ្ទាល់។ ចាប់ពីឆ្នាំ២០១២ វិសាលភាពនៃគម្រោងនេះនឹងត្រូវពង្រីកជាទូទៅ ដើម្បីឲ្យស្ដ្រីរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហមចូលរួមឲ្យបានគ្រប់ទិដ្ឋភាពនៃដំណើរការយុត្តិធម៌អន្តរកាល។

## ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

ក្នុងឋានៈជាជាអង្គការសង្គមស៊ីវិលមួយដែលមានវ័យចំណាស់បំផុតក្នុងចំណោមសង្គមស៊ីវិលដែលមានវ័យចំណាស់នានា ក្នុងប្រទេសកម្ពុជា ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ប្ដេជ្ញាចិត្តផ្ដល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ព្រមទាំងលើកកម្ពស់នីតិរដ្ឋការធ្វើអោយប្រសើរផ្នែកតុលាការ និងអភិបាលកិច្ចបែបលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ក្រោមការណែនាំរបស់ កាស៊ូមិ ណាកាហ្គាវ៉ា **(Kasumi Nakagawa)** អង្គការ នេះ បានចាប់អារម្មណ៍ជាលើកដំបូងទៅលើបញ្ហាអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម ដោយផ្ដោតលើការសិក្សាស្រាវជ្រាវលើកដំបូងទៅលើប្រធានបទនេះនៅឆ្នាំ២០០៦។ ចាប់តាំងពីពេលនោះ មកអង្គការនេះបានបន្តកិច្ចប្រឹងប្រែងគាំទ្រក្នុងការស្រាវជ្រាវ និងធ្វើការតស៊ូមតិអំពីអំពើហិង្សាលើយេនឌ័រ។

## ព័ត៌មានសម្រាប់ទំនាក់ទំនងអ្នកនិពន្ធ

យើងអាចទាក់ទងលោកស្រី កាទ្រីណា ណាតាឡេ អ្នកនិពន្ធរបាយការណ៍នេះ តាមរយៈអ៊ីមែល៖ **katrinamarienatale@gmail.com.**

# “ខ្ញុំភ័យស្ទើរលស់ព្រលឹងអស់ពីខ្លួន”

## ការសិក្សាស្តីពីអំពើហិង្សាលើយេនឌ័រក្នុងរបប
## កម្ពុជាប្រជាធិបតេយ្យ នៅខេត្ត
## បាត់ដំបង និង ខេត្តស្វាយរៀង

ខែវិច្ឆិកា ២០១១

គម្រោងស្តីពីអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម នៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
ផ្ទះលេខ ៥៥៧ ផ្លូវលេខ ៤៥០ សង្កាត់ទួលទំពូង ខណ្ឌ ចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ០១២ ៨០០ ៨១៦
គេហទំព័រ៖ **www.cdpcambodia.org**

# តារាងមាតិកា



អក្សរកាត់


១. សេចក្តីសង្ខេប..........................................................................១

១.១ របកគំហើញសំខាន់ៗ..........................................................................២

១.២ អនុសាសន៍ ..........................................................................៦

២. សេចក្តីផ្តើម..........................................................................១៥

៣. គម្រោងសិក្សា..........................................................................១៨

៣.១ សំណួរស្រាវជ្រាវ ..........................................................................១៨

៣.២ វិធីសាស្រ្ត ..........................................................................១៩

៣.៣ ការកំណត់ ..........................................................................២១

៤. សាវតា..........................................................................២៣

៤.១ របបខ្មែរក្រហម និងកម្ពុជាប្រជាធិបតេយ្យ ......................................២៣

៤.២ ស្ត្រី និងគ្រួសារ ..........................................................................២៤

៤.៣ ទស្សនាទានស្តីពីអំពើហិង្សាលើយេនឌ័រក្នុងស្ថានភាព មានជម្លោះ និងក្រោយជម្លោះ..........................................................២៥

៤.៤ អំពើហិង្សាលើយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ......................២៩

៤.៥ អំពើហិង្សាលើយេនឌ័រមុនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា...៣៣

៥. របកគំហើញ..........................................................................៣៧

៥.១ ប្រជាសាស្រ្ត ..........................................................................៣៧

៥.២ របកគំហើញទូទៅ ..........................................................................៤០

៥.៣ ប្រធានបទទូទៅនៅក្នុងរបាយការណ៍ស្តីពីអំពើហិង្សាលើយេនឌ័រ ....៦០

៦. សេចក្តីសន្និដ្ឋាន..........................................................................៧៣

៧. អ្នកនិពន្ធ និងសេចក្តីថ្លែងអំណរគុណ......................................៧៦



# អក្សរកាត់

| | |
|---|---|
| **BTB** | ខេត្តបាត់ដំបង |
| **CDP** | ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| **CPK** | គណបក្សកុម្មុយនីស្តកម្ពុជា |
| **DK** | កម្ពុជាប្រជាធិបតេយ្យ |
| **GBV** | អំពើហិង្សាលើយេនឌ័រ |
| **អ.វ.ត.ក** | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| **ICC** | តុលាការព្រហ្មទណ្ឌអន្តរជាតិ |
| **ICTR** | សាលាក្តីព្រហ្មទណ្ឌអន្តរជាតិប្រចាំប្រទេសរ៉្វាន់ដា |
| **ICTY** | សាលាក្តីព្រហ្មទណ្ឌអន្តរជាតិប្រចាំប្រទេសយូហ្គោស្លាវី |
| **PGBV** | គម្រោងស្តីពីអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម |
| **SCSL** | តុលាការពិសេសប្រចាំប្រទេសសារ៉ាឡេអូន |
| **SR** | ខេត្តស្វាយរៀង |
| **TPO** | អង្គការចិត្តសង្គមអន្តរវប្បធម៌ |
| **VSS** | អង្គភាពគាំពារជនរងគ្រោះ |

# ១.សេចក្តីសង្ខេប



ជាងសាមសិបឆ្នាំបានកន្លងផុតទៅចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម កម្ពុជាប្រជាធិបតេយ្យ។ នៅសម័យនោះ ពិភពលោកបានដឹងតិចតួចអំពីអំពើឃោរឃៅជាច្រើនដែលប្រជាជនបានជួបប្រទះក្នុងកណ្តាប់ដៃរបស់ពួកខ្មែរក្រហម រាប់ទាំងការផ្ទេរ និងជម្លៀសដោយបង្ខំ ការសម្លាប់ក្រៅតុលាការ ពលកម្មទាំងបង្ខំ ការបង្អត់អាហារ ជម្ងឺ និងការស្លាប់។ ការសិក្សាស្រាវជ្រាវដ៏ទូលំទូលាយ និងការទទួលស្គាល់ជាធាសារណៈ ដែលបញ្ហាទាំងនេះបានទទួលនូវរបាយការណ៍ស្តីពីអំពើហិង្សាលើយេនឌ័រ **(GBV)** ដែលត្រូវបានប្រព្រឹត្តដោយខ្មែរក្រហម ទទួលបានអត្ថប្រយោជន៍ពីការសិក្សា និងការយកចិត្តទុកដាក់តិចតួច។

ការសិក្សាទ្រង់ទ្រាយតូចនេះត្រូវបានធ្វើឡើង ដើម្បីសិក្សាស្រាវជ្រាវមួយចំនួនទៀតអំពីប្រធានបទនៃអំពើហិង្សាលើយេនឌ័រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គោលបំណងចម្បងនៃការសិក្សានេះគឺដើម្បីឆ្លុះបញ្ចាំងបន្ថែមអំពីទម្រង់ និងលក្ខណៈសម្គាល់នៃអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម ដោយប្រមូលទិន្នន័យស្តីពី៖ ១) ប្រភេទនៃអំពើហិង្សាលើយេនឌ័រដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ, ២) ជនរងគ្រោះ និងជនល្មើសនៃអំពើហិង្សានេះ, ៣) ទីតាំង និងស្ថានភាពដែលបានកើតឡើង និង៤) ថាតើទិន្នន័យនេះ ធៀបនឹងទិន្នន័យដែលត្រូវបានប្រមូលតាមរយៈការសិក្សាពីមុនមកមានលក្ខណៈយ៉ាងដូចម្តេច។

បទសម្ភាសន៍សម្រាប់ការអង្កេតនេះត្រូវបានធ្វើឡើងកាលពីខែកញ្ញា និងខែតុលា ២០១១ ដោយមានអ្នកឆ្លើយសំណួរ១០៤នាក់អាយុចន្លោះពី៤២ ទៅ៨៤ឆ្នាំ រស់នៅក្នុងខេត្តបាត់ដំបង និងស្វាយរៀង។អ្នកឆ្លើយសំណួរទាំងនេះត្រូវបានសម្ភាសដោយសម្ងាត់អំពីការយល់ដឹងនិងបទពិសោធន៍របស់ពួកគេពាក់ព័ន្ធអំពើហិង្សាលើយេនឌ័រ ដែលបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយប្រើកម្រងសំណួរអង្កេតពាក់កណ្តាលរចនាសម្ព័ន្ធ រួមមាន សំណួរបើក និងសំណួរបិទ។

ខណៈពេលដែលសំណុំរឿងទីពីរ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានបន្តអនុវត្ត ហើយគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរកាល និងគំនិតផ្តួចផ្តើមកសាងសន្តិភាពផ្សេងទៀតត្រូវបានបង្កើតឡើង របាយការណ៍នេះមានបំណងលើកកម្ពស់ការយល់ដឹងអំពីបញ្ហានៃអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម នាំមកនូវការទទួលស្គាល់ដល់ជនរងគ្រោះ ដាក់បញ្ចូលរបកគំហើញ ពីការសិក្សានេះទៅក្នុងបរិបទនៃច្បាប់អន្តរជាតិ និងការសិក្សាជ្រាវស្រាវស្តីពីអំពើហិង្សាលើយេនឌ័រ ផ្តោតការយកចិត្តទុកដាក់ឡើងវិញទៅលើយន្តការគណនេយ្យភាពសំដៅចំពោះអំពើហិង្សាលើយេនឌ័រ និងជំរុញឲ្យដាក់បញ្ចូលការយល់ដឹងនេះទៅក្នុងគំនិតផ្តួចផ្តើមទាំងអស់ដែលលើកឡើងពីអំពើឃោរឃៅរបស់ខ្មែរក្រហម។

# សេចក្តីសង្ខេប

## ១.១ របកគំហើញសំខាន់ៗ

### ១.១.១ សកម្មភាពនៃអំពើហិង្សាលើយេនឌ័រ

- ក្នុងចំណោមអ្នកឆ្លើយសំណួរនៅក្នុងការអង្កេតនេះ ៦៥.៤% ដឹងអំពីការ**រំលោភសេពសន្ថវៈ** ដែលក្រុមខ្មែរក្រហមបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។២៨.៨%ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់ គឺជាសាក្សីផ្ទាល់ដែលបានឃើញអំពើរំលោភសេពសន្ថវៈ ហើយក្នុងនោះមានស្ត្រីម្នាក់ក៏ជាជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈនេះផងដែរ។
- ទិន្នន័យត្រូវបានប្រមូលផ្អែកលើ**សេណារីយ៉ូនៃការរំលោភសេពសន្ថវៈ**ផ្សេងៗគ្នា ដែលស្របទៅនឹងរបាយការណ៍ស្រដៀងគ្នានៅក្នុងការសិក្សាស្រាវជ្រាវពីមុនមក។ ការចាប់រំលោភទាំងនោះរួមមានការរំលោភបូក ការរំលោភសេពសន្ថវៈនៅក្នុងកន្លែងធ្វើការ និងសហករណ៍ខ្មែរក្រហម ការចាប់រំលោភដោយប្រើឧបករណ៍ណាមួយ ការរំលោភតាមរយៈការកេងប្រវ័ញ្ចផ្លូវភេទនិងទាសភាពផ្លូវភេទ ការប៉ុនប៉ងរំលោភសេពសន្ថវៈ ការរំលោភសេពសន្ថវៈលើបុរស និងការរំលោភសេពសន្ថវៈដែលបានកើតឡើង ក្នុងអំឡុងពេលមានជម្លោះមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។
- អ្នកឆ្លើយតបជិតមួយភាគបួន (២៤%)បានរាយការណ៍ថា បានដឹងអំពីការ**កាត់អវៈយវៈភេទ** ដែលបានកើតឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៅទៀត ១៦.៣% ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់គឺជាសាក្សីផ្ទាល់ដែលបានឃើញការកាត់អវៈយវៈភេទ ជាទូទៅបានឃើញសាកសពទាំងនោះត្រូវគេកាត់និងដាក់បង្ហាញអវៈយវៈភេទ ឬផ្នែករាងកាយនៃសាកសពជនរងគ្រោះ។
- សាកសពដែលត្រូវបានកាត់អវៈយវៈភេទត្រូវបានប្រទះឃើញនៅវាលពិឃាដ នៅក្នុងគុកនៅក្នុងកន្លែងធ្វើការខ្មែរក្រហមនិងរណ្តៅសាកសពរួម។ផ្នែកនៃសាកសពដែលត្រូវបានកាត់អវៈយវៈភេទស្ទើរតែឃើញមាននៅគ្រប់ទីកន្លែងនៅឯ ឬនៅជិតកន្លែងធ្វើការខ្មែរក្រហមរួមមានគុកមណ្ឌលអប់រំកែប្រែ និងការិយាល័យថ្នាក់ឃុំ។
- អ្នកឆ្លើយសំណួរជាង២០%បានរាយការណ៍ថា បានដឹងពីការ**រំលោភបំពានខាងផ្លូវភេទ និងការធ្វើឲ្យអាម៉ាស់ខាងផ្លូវភេទ** ដែលក្រុមខ្មែរក្រហមបានប្រព្រឹត្ត ហើយអ្នកឆ្លើយសំណួរ ១៣.៥% បានឃើញផ្ទាល់ភ្នែកនូវរាល់ទង្វើបែបនេះ។ អ្នកឆ្លើយសំណួរ៦.៨%ទៀតបានរាយការណ៍ថាបានឃើញផ្ទាល់ ភ្នែកនូវការរំលោភបំពានខាងផ្លូវភេទ និងការធ្វើឲ្យអាម៉ាស់ខាងផ្លូវភេទ។អ្នកឆ្លើយសំណួរជាច្រើនទៀតបានរាយការណ៍អំពីសកម្មភាពរំលោភបំពានខាងផ្លូវភេទ និងការធ្វើឲ្យអាម៉ាស់ខាងផ្លូវភេទ ដែលក្នុងរួមមានការរំលោភបំពានដោយពាក្យ

សម្តីការសើចចំអក ការបង្ខំឲ្យដោះសម្លៀកបំពាក់ ការបង្ខំឲ្យមើលអំពើរំលោភ និងការប៉ះពាល់ ឬស្ទាបដោយបង្ខំ។

- ទោះបីជាអ្នកឆ្លើយសំណួរទាំងនេះមិនត្រូវបានសួរនាំអំពី **ការបង្ខំឲ្យរៀបការ**នៅក្នុងការអង្កេតនេះក៏ដោយ ក៏អ្នកឆ្លើយសំណួរជិត២០%បានលើកឡើងអំពីបញ្ហានេះដោយគំនិតផ្តួចផ្តើមផ្ទាល់របស់ពួកគាត់។ ពួកគាត់សង្កត់ធ្ងន់ថា បុគ្គលម្នាក់ៗគ្មានជម្រើសក្នុងការជ្រើសរើសប្តី/ប្រពន្ធដោយខ្លួនឯងនោះទេ និងបារម្ភថានាំឲ្យមនុស្សជាច្រើនយល់ព្រមរៀបការ ពួកគាត់ក៏បានត្អូញត្អែរផងដែរថា ពិធីរៀបអាពាហ៍ពិពាហ៍ទាំងនោះត្រូវបានធ្វើឡើងដោយមិនសមស្រប និងបានរាយការណ៍អំពីការរំលោភសេពសន្ថវៈក្នុងការបង្ខំឲ្យរៀបការ។គួរឲ្យកត់សម្គាល់ផងដែរ អ្នកឆ្លើយសំណួរជាច្រើនបានកំណត់ថា ការបង្ខំឲ្យរៀបការក្រោមរបបខ្មែរក្រហមជាទិដ្ឋភាពដ៏សំខាន់មួយបង្ហាញពីអំពើហិង្សាដែលប្រព្រឹត្តមកលើប្រជាជនក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

## ១.១.២ ប្រធានបទនៅក្នុងរបាយការណ៍ស្តីពីអំពើហិង្សាលើយេនឌ័រ

- អ្នកឆ្លើយសំណួរបានដឹងអំពីគោលនយោបាយខ្មែរក្រហម ដែលហាមឃាត់**ការខុសសីលធម៌** ហើយអ្នកឆ្លើយសំណួរជាច្រើនរាយការណ៍ថា បានឃើញជនរងគ្រោះត្រូវបានគេដាក់ទណ្ឌកម្មចំពោះបទល្មើសបែបនេះ។ អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍ថា គោលនយោបាយនេះបានបណ្តាលឲ្យជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រមួយចំនួនសម្លាប់ខ្លួន ដោយមិនហ៊ានប្រឈមមុខនឹងទណ្ឌកម្មពីខ្មែរក្រហមចំពោះអ្វីដែលគេយល់ឃើញថាពាក់ព័ន្ធនឹងការខុសសីលធម៌។ អ្នកឆ្លើយសំណួរទាំងនោះបានរាយការណ៍ថា គោលនយោបាយប្រឆាំងនឹងកំហុសផ្នែកសីលធម៌បានបណ្តាលឲ្យជនដែលទាំងនោះសម្លាប់ជនរងគ្រោះ សម្លាប់ខ្លួនឯង ឬរត់គេចពីការដាក់ទណ្ឌកម្ម។ ទោះបីជាអ្នកឆ្លើយសំណួរជិត២០%បានចូលរួមក្នុង "កិច្ចប្រជុំវិនិច្ឆ័យ" ការខុសសីលធម៌ ឬបានឃើញគេធ្វើទណ្ឌកម្មចំពោះកំហុសផ្នែកសីលធម៌ក៏ដោយក៏នៅក្នុងករណីទាំងអស់នោះ មានតែ


ទីតាំងដែលការស្រាវជ្រាវបានធ្វើឡើងនៅតាមបណ្តាខេត្ត

ពីរករណីប៉ុណ្ណោះដែលអ្នកឆ្លើយសំណួរទាំងនេះបានរាយការណ៍ថា អ្នកដែលទទួលទណ្ឌកម្មនោះមានការពាក់ព័ន្ធនឹងទំនាក់ទំនងដោយព្រមព្រៀង។ ជនដៃដល់ត្រូវបានដាក់ទណ្ឌកម្មតែមួយករណីប៉ុណ្ណោះ។ របកគំហើញទាំងនេះបានលើកឡើងថា គោលនយោបាយរបស់ខ្មែរក្រហមប្រឆាំងនឹង**អំពើខុសសីលធម៌**មិនត្រូវបានអនុវត្តឲ្យបានស៊ីសង្វាក់គ្នា និងគ្មានប្រសិទ្ធភាពក្នុងការទប់ស្កាត់អំពើហិង្សាលើយេនឌ័រនោះទេ។

- អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍ថា វិធីសាស្ត្រទាក់ទងនឹង**ការលែលកដោះស្រាយក្ដីបារម្ភ និងការមាក់ងាយ**បណ្ដាលមកពីអំពើហិង្សាលើយេនឌ័រ ដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ស្ត្រីអ្នកឆ្លើយសំណួរមួយចំនួនបានរៀបរាប់ថាបានដឹងអំពីអំពើហិង្សាលើយេនឌ័រតាមរយៈបណ្ដាញមិត្តភក្ដិរបស់ពួកគាត់ និងបានលម្អិតអំពីការចាត់វិធានការរបស់ពួកគេដើម្បីជៀសពីភាពក្លាយជាជងរងគ្រោះ។ ទាំងបុរស និងស្ត្រីបានសម្ដែងនូវការភ័យខ្លាច រន្ធត់ និងក្រៀមក្រំក្រៃលែងដោយសារតែអំពើហិង្សាលើយេនឌ័រដែលពួកគាត់បានឃើញឬទទួលរង។ ទាំងបុរស និងស្ត្រីអ្នកឆ្លើយសំណួរបានទទួលស្គាល់នូវការមាក់ងាយ ដែលពាក់ព័ន្ធនឹងភាពក្លាយជាជនរងគ្រោះផ្លូវភេទទាំងក្នុងអំឡុងរបបខ្មែរក្រហម និងបន្តមកដល់ថ្ងៃនេះ។
- **ជនរងគ្រោះ**ដោយអំពើហិង្សាលើយេនឌ័រ ដែលត្រូវបានរាយការណ៍នៅក្នុងការសិក្សានេះភាគច្រើនជាស្ត្រី។ ពួកគាត់ជា "ប្រជាជនថ្មី" "ប្រជាជនមូលដ្ឋាន" និងជាស្ត្រី មន្ត្រីខ្មែរក្រហមដែលមានឋានៈទាប។ ជារឿយៗគេរាយការណ៍មកថា ជនរងគ្រោះទាំងនេះត្រូវបានសម្លាប់ជាពិសេសដោយសារការរំលោភជាក្រុម ដែលកើតឡើងនៅឆ្ងាយពីសហករណ៍ប៉ុន្តែការរំលោភសេពសន្ថវៈដែលគេបានរាយការណ៍ថា បានកើតឡើងនៅក្នុងសហករណ៍នោះជារឿយៗមិនសូវបានរាយការណ៍ថា ជនរងគ្រោះស្លាប់នោះទេ។ លើសពីនេះទៅទៀតអ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍ថា បានស្គាល់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រដែលរួចជីវិតពីរបបនេះ។ របកគំហើញទាំងនេះបានលើកឡើងថា ការរំលោភសេពសន្ថវៈមិនត្រូវបានប្រព្រឹត្តជាដាច់ខាតឬភាគច្រើនមកលើប្រជាជនថ្មីនោះទេ ហើយថាជនរងគ្រោះដោយការរំលោភសេពសន្ថវៈ ភាគច្រើនបានរួចជីវិតពីបទពិសោធន៍ដ៏អាក្រក់នេះ។
- នៅគ្រប់ករណីទាំងអស់ លើកលែងតែករណីមួយស្ដីពីអំពើហិង្សាលើយេនឌ័រនៅក្នុងការសិក្សានេះប៉ុណ្ណោះ ដែល**ជនដៃដល់ម្នាក់**ត្រូវបានស្គាល់អត្តសញ្ញាណថាជាភ្នាក់ងារខ្មែរក្រហម។ នៅគ្រប់ករណីទាំងអស់ លើកលែងតែពីរករណីប៉ុណ្ណោះ ដែលជនដៃដល់ត្រូវបានស្គាល់អត្តសញ្ញាណថាជាបុរស។ ទោះបីជាពេលវេលានេះបានកន្លងផុតទៅហើយក្ដី ក៏អ្នកឆ្លើយ

សំណួរភាគច្រើនបានស្គាល់ឈ្មោះ និង/ឬតួនាទីរបស់ជនដៃដល់ក្នុងរបបខ្មែរក្រហម។ នៅក្នុងករណីភាគច្រើន ជនដៃដល់ដដែលនោះ ត្រូវបានស្គាល់អត្តសញ្ញាណថា បានប្រព្រឹត្ត អំពើហិង្សាលើយេនឌ័រ មកលើជនរងគ្រោះជាច្រើន។ លើសពីនេះទៅទៀត អ្នកឆ្លើយសំណួរ ជាច្រើននៅខេត្តស្វាយរៀងបានរាយការណ៍ថា អំពើហិង្សាលើយេនឌ័រ បានកើនឡើងនៅ ពេលដែលទាហានពីភូមិភាគនិរតី និងតំបន់២៥នៅខេត្តតាកែវត្រូវបានផ្ទេរមកសហគមន៍ របស់ពួកគេ។

- អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍ថា អំពើហិង្សាលើយេនឌ័រដែលសំដៅចំពោះ **ក្រុមជនជាតិនោះ** រួមមាន ជនជាតិវៀតណាម ចាម និងចិន។ អំពើហិង្សានេះរួមមាន សេណារីយ៉ូ(ឆាក) នៃការរំលោភជាក្រុម ការរំលោភសេពសន្ថវៈ និងការបង្ខំឲ្យដោះសម្លៀក បំពាក់ជាដើម។ ឧក្រិដ្ឋកម្មស្រដៀងគ្នាទាំងនេះក៏បានក្លាយជាឯកសារយោងនៅក្នុងការ សិក្សាពីមុនមក និងត្រូវបានរាយការណ៍នៅក្នុងពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះ មុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការសំដៅចំពោះក្រុមទាំងនេះ គឺសមស្របទៅនឹងឥរិយាបថទូទៅរបស់ខ្មែរក្រហមចំពោះប្រជាពលរដ្ឋទាំងនេះក្នុងអំឡុង របបដែលពួកគេត្រូវបានគិតទុកដោយភាពសង្ស័យ និងជារឿយៗត្រូវបានចាត់ទុកជាសត្រូវ ទៀតផង។
- ទិន្នន័យដែលប្រមូលបាននៅក្នុងការអង្កេតនេះបានលើកឡើងថា ការប្រព្រឹត្តអំពើហិង្សា លើយេនឌ័រមានលក្ខណៈខុសគ្នាទៅតាម**តំបន់ភូមិសាស្ត្រ និងពេលវេលា**នៅក្នុងរបបនេះ។ ការកាត់ និងដាក់បង្ហាញប្រដាប់បន្តពូជរបស់ជនរងគ្រោះត្រូវបានរកឃើញភាគច្រើនបំផុត នៅក្នុងស្រុកមួយនៃខេត្តស្វាយរៀង ដែលជាទូទៅផ្នែកនៃសាកសពទាំងនេះត្រូវបានដាក់ បង្ហាញនៅក្នុងកន្លែងធ្វើការខ្មែរក្រហម។ ជាមួយគ្នានេះដែរ ការរំលោភជាក្រុម ក៏ត្រូវ បានរាយការណ៍ ភាគច្រើនបំផុតនៅភាគខាងលិចនៃខេត្តស្វាយរៀង ភាគខាងកើតខេត្ត បាត់ដំបង ព្រៃវែង និង ពោធិ៍សាត់។ គេបានរាយការណ៍ថា ការរំលោភសេពសន្ថវៈទាំង នេះបានកើតឡើងមុនគេនៅក្នុងរបបនេះ (ខេត្តបាត់ដំបង) និងចុងក្រោយនៅក្នុងរបបនេះ (ខេត្តស្វាយរៀង ព្រៃវែង និងពោធិ៍សាត់) នៅពេលដែលគេបានដឹងថា ការបោសសម្អាត ប្រជាជនបានកើតឡើង។ ភាពខុសគ្នានៃការប្រព្រឹត្តអំពើហិង្សាលើយេនឌ័របានលើក ឡើងថា តំបន់ភូមិសាស្ត្រ បរិយាកាសនយោបាយ និងថ្នាក់ដឹកនាំនៅក្នុងតំបន់អាចមាន ផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើ អ្វីដែលអំពើហិង្សាលើយេនឌ័រ បានកើតឡើង និង ចម្លើយដែលខ្លួនបានទទួល។លើសពីនេះទៀតមានការកត់សំគាល់ថាអំពើហិង្សាយេនឌ័រ

ត្រូវបានគេដឹង និងបណ្ដែតបណ្ដោយយ៉ាងហោចណាស់នៅផ្នែកខ្លះៗក្នុងប្រទេស និងជាពិសេសក្នុងកាលៈទេសៈមួយជាក់លាក់។

## ១.២ អនុសាសន៍

### ១.២.១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)

- ***អង្គជំនុំជម្រះសាលាដំបូងគួរតែស៊ើបអង្កេត ក្នុងករណីសមស្របត្រូវតែផ្ដន្ទាទោសចំពោះអំពើហិង្សាលើយេនឌ័រ ដែលមានវិសាលភាពដ៏ធំធេង នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។*** ការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញថា អំពើហិង្សាលើយេនឌ័រគឺជាកត្តាដ៏សំខាន់មួយនៃឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា។ មានភស្តុតាងមួយចំនួនលើកឡើងថា ក្នុងករណីខ្លះការកើតមានអំពើហិង្សាលើយេនឌ័រនេះត្រូវបានឬគួរត្រូវបានដឹងច្បាស់ដោយមេដឹកនាំខ្មែរក្រហម ហើយជនដៃដល់ទាំងនោះមិនត្រូវបានឲ្យទទួលខុសត្រូវទៀងទាត់ចំពោះទង្វើរបស់ពួកគេនោះទេ។ ថ្វីបើដំណើរការនីតិវិធី មានភាពយឺតយ៉ាវក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងមានអំណាចក្នុងការបង្គាប់ឲ្យស៊ើបអង្កេតបន្ថែម និងពិចារណាលើឧក្រិដ្ឋកម្មបន្ថែម ដោយគំនិតផ្ដួចផ្ដើមផ្ទាល់របស់ខ្លួន។ នេះអាចជាវិធានការដ៏សំខាន់មួយក្នុងការអនុវត្តទៅតាមបទដ្ឋានអន្តរជាតិនៃយុត្តិធម៌យេនឌ័រ ដោយបញ្ចប់នូវនិទណ្ឌភាពជុំវិញឧក្រិដ្ឋកម្មទាំងនេះ និងទទួល ស្គាល់នូវគ្រោះថ្នាក់ដែលកើតមានចំពោះជនរងគ្រោះ។



*វេទិកាថ្នាក់តំបន់នៃដើមបណ្ដឹងរដ្ឋប្បវេណីក្នុងខេត្តបាត់ដំបង អង្គភាពគាំពារជនរងគ្រោះរបស់ ECCC*

- ***មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សហមេធាវីនាំមុខ និងអ្នកតំណាងជនរងគ្រោះផ្សេងទៀតគួរតែបន្តជំរុញឲ្យដាក់បញ្ចូលអំពើហិង្សាលើយេនឌ័រ នៅគ្រប់រូបភាពនៃការងាររបស់តុលាការ។*** ជាពិសេស មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបន្តជំរុញឲ្យតុលាការផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មផ្សេងៗទៀត និងគួរតែបន្តអនុវត្តទៅមុខទៀត។ ពួកគេក៏បានគាំទ្រចំពោះការទាមទារសំណងជំងឺចិត្តជាច្រើន (វិធានការតាមផ្លូវតុលាការ) ដែលនឹងដោះស្រាយដោយផ្ទាល់នូវព្យសនកម្ម ដល់ជនរងគ្រោះដែលទទួលរងការបង្ខំឲ្យរៀបការ។ ពួកគេក៏អាចជំរុញឲ្យតុលាការដាក់បញ្ចូលនូវការទទួលស្គាល់ជាក់លាក់អំពីផលប៉ះពាល់នៃអំពើហិង្សាលើយេនឌ័រ មកលើជនរងគ្រោះនៅក្នុងការវិនិច្ឆ័យរបស់តុលាការ

ដោយផ្តល់នូវទម្រង់សំខាន់ៗនៃសំណងជំងឺចិត្តជានិមិត្តរូប និងតាមនីតិវិធីសម្រាប់ជនរងគ្រោះ។ សហព្រះរាជអាជ្ញា សហចៅក្រមសើុបអង្កេត សហមេធាវីនាំមុខ អ្នកតំណាងជនរងគ្រោះនិងសង្គមស៊ីវិលគួរតែគាំទ្រដល់កិច្ចប្រឹងប្រែងទាំងនេះ។

- ***អង្គភាពគាំទ្រជនរងគ្រោះដែលមានភាពដៃគូជាមួយនឹងតួអង្គសង្គមស៊ីវិល និងអ្នកតំណាងជនរងគ្រោះគួរតែសំដៅចំពោះវិធានការក្រៅផ្លូវតុលាការ ដែលស្វះស្វែងផ្តល់អំណាចដល់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ និងទទួលស្គាល់បទពិសោធន៍របស់ពួកគេ។*** ក្រុមទាំងនេះបានរៀចំគម្រោងមួយរួចជាស្រេច ក្រោមវិធានការក្រៅផ្លូវតុលាការ ដែលបម្រើប្រយោជន៍ដល់ជនរងគ្រោះ ដោយអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។ នៅពេលដែលការងារនេះបន្តទៅមុខ ក្រុមទាំងនេះជាមួយនឹងអ្នកតំណាងជនរងគ្រោះ អ្នកស្រាវជ្រាវ និងភាគីដែលមានចំណាប់អារម្មណ៍ផ្សេងទៀតគួរតែបន្តបង្កើតគម្រោងដែលមានគំនិតច្នៃប្រឌិត និងឆ្លើយតបនឹងតម្រូវការ ដែលនឹងផ្តល់វេទិកាតាមជម្រើសសម្រាប់ជាការផ្តល់អំណាចដល់ជនរងគ្រោះ ព្រមទាំងការលើកកម្ពស់ការយល់ដឹងអំពីប្រធានបទស្តីពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។ ក្រុមទាំងនេះអាចរួមមានឱកាសនិយាយការពិតអំពីថ្នាក់មូលដ្ឋាន យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងគម្រោងផ្សេងទៀត ដែលត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយ ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម។
- ***ផ្នែកកិច្ចការសាធារណៈរបស់តុលាការ គួរតែផ្តល់ព័ត៌មានដល់សាធារណជនអំពីរបៀបដែលតុលាការកំពុងឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមលើយេនឌ័រ។*** ព័ត៌មាននេះគួរតែមានការពន្យល់ច្បាស់លាស់អំពីឧក្រិដ្ឋកម្មលើយេនឌ័រ ដែលកំពុងត្រូវបានផ្តន្ទាទោសនៅក្នុងតុលាការ។ តុលាការក៏គួរតែលម្អិតអំពីឧក្រិដ្ឋកម្មនានាដែលមិនបានផ្តន្ទាទោសនៅតុលាការ និងហេតុផលផ្សេងទៀតដែលលើកឡើងថាហេតុអ្វីបានជាព័ត៌មាននេះ ជាករណីមួយ។ តម្លាភាពក្នុងការផ្តល់ព័ត៌មាននេះនឹងកាត់បន្ថយការយល់ឃើញរបស់សាធារណជនអំពីនិទណ្ឌភាពចំពោះឧក្រិដ្ឋកម្មទាំងនេះ ជាពិសេស ចំពោះជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម។ លើសពីនេះទៅទៀត នៅក្នុងការទទួលស្គាល់ និងការឆ្លើយតបពេញលេញទៅនឹងអំពើហិង្សាលើយេនឌ័រ តុលាការខ្មែរក្រហមនឹងលើកយកឧទាហរណ៍ដ៏សំខាន់មួយថា តើតុលាការជាតិ រាជរដ្ឋាភិបាល និងអ្នកបង្កើតគោលនយោបាយគួរដោះស្រាយអំពើហិង្សាលើយេនឌ័រក្នុងពេលបច្ចុប្បន្ននៅកម្ពុជាដោយរបៀបណា។

### ១.២.២ អង្គការសង្គមស៊ីវិល និងម្ចាស់ជំនួយ

- ***រៀបចំ និងអនុវត្តគម្រោង និងកម្មវិធីទាក់ទងនឹងអំពើឃោរឃៅរបស់ខ្មែរក្រហម ដោយពិចារណាទៅលើបទពិសោធន៍ និងតម្រូវការរបស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។*** មកទល់ពេលនេះ គំនិតផ្តួចផ្តើមភាគច្រើនដែលសំដៅចំពោះសម័យខ្មែរក្រហមមិនបានរាប់បញ្ចូលទស្សនវិស័យរបស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ ឬដោះស្រាយទម្រង់នៃអំពើហិង្សាដែលត្រូវបានប្រព្រឹត្តក្នុងសម័យខ្មែរក្រហមនោះទេ។ វិធីសាស្ត្រដែលដាក់បញ្ចូលយេនឌ័រ និងទស្សនវិស័យនៃអំពើហិង្សាលើយេនឌ័រនឹងរាប់បញ្ចូលទាំងការបង្កើតភាពជាដៃគូនិងការសហការជាមួយអង្គការនានា ដែលកំពុងធ្វើការជាក់លាក់ទៅលើប្រធានបទនេះ។ វិធីសាស្ត្រនេះក៏នឹងរាប់បញ្ចូលការស្វែងរកគំនិត និងសេចក្តីជាក់ស្តែង និងផលប្រយោជន៍របស់ជនរងគ្រោះទាំងនេះ និងវិធីដែលគេអាចឆ្លុះបញ្ចាំងពីធាតុផ្សំនៃប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងគំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិល។
- ***បង្កើត និង គាំទ្រយន្តការប្រាប់ការពិត និង យន្តការយុត្តិធម៌អន្តរកាល ដែលឆ្លើយតបទៅនឹងតម្រូវការ និងបទពិសោធន៍របស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។*** យន្តការទាំងនេះអាចជាមធ្យោបាយដ៏សំខាន់មួយក្នុងការផ្តល់អំណាចដល់ជនរងគ្រោះ និងលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីទិដ្ឋភាព នៃបទពិសោធន៍ក្រោមរបបខ្មែរក្រហមដែលគេមិនសូវយល់ដឹងឲ្យបានទូលំទូលាយ ហើយអាចជាប្រភពនៃការមាក់ងាយ និងការខ្មាសអៀនចំពោះជនរងគ្រោះ និងគ្រួសាររបស់ពួកគាត់។ ទោះបីជាយន្តការទាំងនេះមិនអាចជំនួសដោយទណ្ឌកម្មប្រកបដោយប្រសិទ្ធភាពនៃឧក្រិដ្ឋកម្មទាំងនេះតាមរយៈដំណើរការយុត្តិធម៌ក៏ដោយ ក៏វាអាចជាគន្លឹះនាំទៅរកការកាត់បន្ថយនិទណ្ឌភាពជាពិសេសដំណើរការយុត្តិធម៌ណាដែលមិនមាន ឬមិនគ្រប់គ្រាន់។ យន្តការមួយនោះគឺវេទិការសម្លេងពិតរបស់ស្ត្រីដែលបានរៀបចំឡើងដោយក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា។ គម្រោងបន្ថែមទៀត ជាពិសេសនៅក្នុងសហគមន៍មូលដ្ឋាន និងក្រៅរាជធានីភ្នំពេញគួរតែត្រូវបានបង្កើតឡើងដោយមានកិច្ចសហប្រតិបត្តិការជាមួយបណ្តាអង្គការនានាដែលអនុវត្តទៅលើអំពើហិង្សាលើយេនឌ័រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។
- ***បង្កើតឱកាសសម្រាប់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រដើម្បីចែករំលែក និងកែច្នៃបទពិសោធន៍ដែលពួកគាត់ធ្លាប់ក្លាយជាជនរងគ្រោះឲ្យទៅជាបរិយាកាសប្រកបដោយសុវត្ថិភាព ការគាំទ្រ និងផ្តល់សិទ្ធិអំណាច។*** ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គមប្រកបដោយវិជ្ជាជីវៈមានរៀបចំជាឯកសារច្បាស់លាស់នៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្រៅរាជធានី

ភ្នំពេញ។ គំរូសេវាសុខភាពផ្លូវចិត្តនៅបស្ចិមប្រទេសក៏មិនធ្លាប់បានឆ្លងកាត់ និងមិនអាចជាគំរូដ៏សមស្រប ឬមានប្រសិទ្ធភាពបំផុតនៅក្នុងបរិបទកម្ពុជានោះទេ។ ការគាំទ្រផ្លូវចិត្ត និងការកែច្នៃបទពិសោធន៍នៃជំងឺផ្លូវចិត្តអាចសម្រេចបានជោគជ័យតាមរយៈមធ្យោបាយផ្សេងៗ ដូចជាក្រុមពិភាក្សា ក្រុមជួយខ្លួនឯង ដំណើរការព្យាបាលតាមបែបបរិយាយ ឬមធ្យោបាយច្នៃប្រឌិតផ្សេងទៀត ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ជនរងគ្រោះអាចទទួលយកបាន និងមាននិរន្តរភាព។ គេអាចឃើញគំរូដ៏សំខាន់មួយសម្រាប់វិធីសាស្ត្របែបនេះនៅក្នុងអង្គភាពគាំទ្រជនរងគ្រោះ**(VSS)**/អង្គការចិត្តសាស្ត្រសង្គម និងអន្តរវប្បធម៌ **(TPO)** ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា **(CDP)** គម្រោងនៃក្រុមជួយខ្លួនឯង បច្ចុប្បន្នកំពុងត្រូវបានសាកល្បងនៅកម្ពុជា។[១]



*ការប្រារព្ធពិធីរបស់អ្នករស់រានមានជីវិតពី CDP-GBV*

- ***ផ្ដល់អំណាចដល់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ ដើម្បីកំណត់ និងគាំទ្រដល់ផលប្រយោជន៍ ។*** ការផ្ដល់អំណាចនេះអាចសម្រេចបានតាមរយៈការជួយជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្នុងការកំណត់តម្រូវការ និងផលប្រយោជន៍របស់ពួកគេតាមរយៈដំណើរការដោយមានការចូលរួម។ ដំណើរការនេះអាចពាក់ព័ន្ធនឹងក្រុមសង្គមស៊ីវិល ដែលជួយជនរងគ្រោះក្នុងការកំណត់នូវវិធីអ្វីដែលពួកគេចង់ចូលរួមក្នុងការកសាងសន្តិភាព និងការផ្ដួចផ្ដើមយុត្តិធម៌អន្តរកាល និងធ្វើការជាមួយពួកគេដើម្បីកំណត់គោលដៅរបស់ពួកគេក្នុងការអនុវត្តការងារ និងកំណត់តម្រូវការរបស់ពួកគេដើម្បីជំរុញឲ្យពួកគេចូលរួមប្រកបដោយប្រសិទ្ធភាព និងមានអត្ថន័យ។ ក្រុមសង្គមស៊ីវិលក៏អាចផ្ដល់ជំនួយបច្ចេកទេស និងការបណ្ដុះបណ្ដាលដើម្បីគាំទ្រដល់ការចូលរួមរបស់ជនរងគ្រោះ និង កសាងទំនុកចិត្ត និងសមត្ថភាពរបស់ពួកគេដើម្បីចូលរួមក្នុងការកសាងសន្តិភាព និងដំណើរការយុត្តិធម៌អន្តរកាល។
- ***ម្ចាស់ជំនួយគួរតែពិចារណាផ្ដល់មូលនិធិដល់គម្រោងតាមកម្មវិធី និងគម្រោងផ្អែកលើការស្រាវជ្រាវសំដៅចំពោះអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។*** ការស្រាវជ្រាវបន្ថែមជាពិសេសអំពីបញ្ហាដែលត្រូវបានកត់សម្គាល់នៅក្នុងអនុសាសន៍សម្រាប់ការស្រាវជ្រាវ និងអ្នកជំនាញ (ខាងក្រោម) ជាធម្មតា មានការលំបាកក្នុងការផ្ដល់មូលនិធិ។ ទោះជាយ៉ាង

[១] សម្រាប់ការពិពណ៌នាអំពីគម្រោង សូមមើលជើងទំព័រ៧១ខាងក្រោម។

នោះក្ដី នៅក្នុងបរិបទដែលអាចរកបានព័ត៌មានតិចតួចស្ដីពីអំពើហិង្សាលើយេនឌ័រ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងយន្តការយុត្តិធម៌អន្តរកាលកំពុងដំណើរការ អ្វីដែលសំខាន់នោះគឺត្រូវឈ្វេងយល់មិនត្រឹមតែហេតុការណ៍ដែលបានកើតឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវឈ្វេងយល់ថា តើវាមានផលប៉ះពាល់យ៉ាងណាទៅលើជនរងគ្រោះ គ្រួសារ សហគមន៍ និងសង្គមនានា។ គម្រោងស្រាវជ្រាវដោយមានការចូលរួមក៏នឹងមានមុខងារដ៏សំខាន់ ក្នុងការផ្ដល់អំណាចដល់ជនរងគ្រោះឲ្យមានតួនាទីសកម្មនៅក្នុងដំណើរការទាំងនេះ និងជួយកំណត់តម្រូវការរបស់ពួកគេ និងដាក់ទស្សនវិស័យរបស់ពួកគេទៅក្នុងដំណើរការទាំងនេះ។

### ១.២.៣ រាជរដ្ឋាភិបាលកម្ពុជា

- ***ការទទួលស្គាល់ ការគោរព និងការឲ្យជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហមចូលរួមក្នុងគម្រោង និងដំណើរការរបស់រាជរដ្ឋាភិបាល។*** នៅក្នុងវិធីដែលរាជរដ្ឋាភិបាលលើកឡើងពីអំពើឃោរឃៅរបស់ខ្មែរក្រហមនោះ គួរតែពិគ្រោះយោបល់ និងរាប់បញ្ចូលទស្សនវិស័យរបស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។ យន្តការដើម្បីសម្រេចឲ្យបានគោលដៅនេះអាចត្រូវបង្កើតក្រុមប្រឹក្សាយោបល់ពិសេសមួយនៅក្នុងរាជរដ្ឋាភិបាលស្ដីពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម ដែលអាចត្រូវបានសម្របសម្រួលតាមរយៈក្រសួងកិច្ចការនារី ដែលត្រូវផ្ដួចផ្ដើមនូវគម្រោង និងកម្មវិធីដើម្បីផ្ដល់គំនិត និងការណែនាំអំពីរបៀបដាក់បញ្ចូលទស្សនវិស័យរបស់ក្រុមជនរងគ្រោះទាំងនេះ ប្រកបដោយជោគជ័យទៅក្នុងគំនិតផ្ដួចផ្ដើមដែលរាជរដ្ឋាភិបាលបានគិតទុកជាមុន។
- ***គាំទ្រអង្គការសង្គមស៊ីវិល និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបានផ្ដល់គំនិតផ្ដួចផ្ដើមស្ដីពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។*** ដូចបានកត់សំគាល់ពីដំបូង អង្គការសង្គមស៊ីវិល កំពុងតែសំដៅទៅរកគម្រោង និងកម្មវិធីដែលលើកឡើងពីបទពិសោធន៍ និងតម្រូវការរបស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏អាចផ្ដល់ជំនួយជាសំណងជំងឺចិត្ត (វិធានការតាមផ្លូវតុលាការ) ដើម្បីដោះស្រាយព្យសនកម្មនានា ដែលជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័របានជួបប្រទះ។ នៅក្នុងករណីទាំងពីរនេះ មានវិធានការប្រតិសកម្មមួយចំនួនដែលរាជរដ្ឋាភិបាលកម្ពុជាអាចចាត់ឡើង ដើម្បីគាំទ្រ និងចូលរួមនៅក្នុងគំនិតផ្ដួចផ្ដើមទាំងនេះ។ វិធីដែលវិធានការនេះអាចសម្រេចបានជោគជ័យ គឺត្រូវឲ្យរាជរដ្ឋាភិបាលមានអ្នកទំនាក់ទំនងពីទីស្ដីការគណៈ

រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី ឬរដ្ឋសភាដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលអំពីគម្រោងទាំងនេះ ដែលភាគច្រើនតម្រូវឲ្យមានការសម្របសម្រួលជាមួយរដ្ឋអំណាចមូលដ្ឋាន ឬប្រឈមមុខនឹងបញ្ហាការិយាធិបតេយ្យផ្សេងទៀត នៅក្នុងការអនុវត្តរបស់ពួកគេ។

- **បង្កើតភាពជាដៃគូអង្គការសង្គមស៊ីវិល និងរាជរដ្ឋាភិបាល ដើម្បីទទួលស្គាល់និងគាំទ្រជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។** រាជរដ្ឋាភិបាលគួរតែចូលរួមដោយផ្ទាល់ជាមួយសង្គមស៊ីវិល និងជនរងគ្រោះ សម្រាប់កម្មវិធីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម និងគាំទ្រជនរងគ្រោះដោយអំពើហិង្សានេះ។ កម្មវិធីនេះមិនត្រឹមតែផ្ដល់វិធានការដ៏សំខាន់ក្នុងការទទួលស្គាល់ជនរងគ្រោះដោយខ្មែរក្រហមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានផ្សារភ្ជាប់ទៅនឹងបញ្ហានៃអំពើហិង្សាលើយេនឌ័រ នៅកម្ពុជាសព្វថ្ងៃទៀតផង មិនតែប៉ុណ្ណោះកម្មវិធីនេះបានជួយកាត់បន្ថយការមាក់ងាយដែលជនរងគ្រោះបានទទួលរងដោយឧក្រិដ្ឋកម្មទាំងនេះ និងប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពចំពោះអំពើហិង្សានេះ។


*អ្នករស់រានមានជីវិតពិនិត្យមើលរូបថតនៅសារមន្ទីរទួលស្លែង*

## ១.២.៤ អ្នកស្រាវជ្រាវ និងអ្នកជំនាញ

- ***ធ្វើការស្រាវជ្រាវដើម្បីឈ្វេងយល់ឲ្យបានច្បាស់លាស់អំពីសហគមន៍ដែលរងគ្រោះដោយសារអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម។*** មកទល់ពេលនេះ ការស្រាវជ្រាវអំពីប្រធានបទនេះភាគច្រើនបានផ្ដោតទៅលើលក្ខណៈទូទៅនៃអំពើហិង្សាលើយេនឌ័រ និងបញ្ជាក់ថាអំពើហិង្សាបែបនេះពិតជាបានកើតឡើងមែន។ នៅក្នុងការសិក្សាដែលទាំងនេះ អ្នកឆ្លើយសំណួរបានលើកឡើងថា តើឧក្រិដ្ឋកម្មទាំងនេះអាចមានផលប៉ះពាល់វិសមាមាត្រទៅលើក្រុមមួយចំនួនយ៉ាងដូចម្ដេច (ឧ. ជនជាតិចាម វៀតណាម អ្នករកស៊ីផ្លូវភេទជាដើម)។ ជាឧទាហរណ៍មួយ នៃប្រវត្តិផ្ទាល់មាត់ពីសហគមន៍មួយក្នុងចំណោមសហគមន៍ទាំងនេះ ហ្វារីណា សូ **(Farina So)** ក៏បានសិក្សាអំពីបទពិសោធន៍របស់ស្ត្រីជនជាតិចាមក្នុងរបបខ្មែរក្រហម តាមរយៈគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់របស់គាត់ ដែលរៀបរាប់ពីករណីជាច្រើន

នៃអំពើហិង្សាលើយេនឌ័រ ដែលគេបានប្រព្រឹត្តមកលើស្ត្រីទាំងនេះ។[២] ទិន្នន័យដែលត្រូវបានប្រមូលតាមរយៈប្រភពទាំងនេះគឺជាចំណុចចាប់ផ្ដើមមួយ និង រួមចំណែកសំខាន់នៅក្នុងទិន្នន័យ ដែលត្រូវបានកំណត់ផ្សេងពីនេះ ហើយតាមធម្មតាទិន្នន័យទាំងនេះបានមកពីបុគ្គលនៅក្រៅក្រុមទាំងនេះ។ វាមានប្រយោជន៍ក្នុងការឈ្វេងយល់ឲ្យបានច្បាស់ថា តើក្រុមជនជាតិភាគតិចបានទទួលរង និងរងគ្រោះ ដោយអំពើហិង្សានេះ និងពីទស្សនវិស័យផ្ទាល់របស់ពួកគេដោយរបៀបណា។ ដើម្បីបានទៅដល់សមាជិកនៃក្រុមទាំងនេះដោយប្រសិទ្ធភាព ការស្រាវជ្រាវដែលមានគោលដៅជាក់លាក់នៅក្នុងសហគមន៍ទាំងនេះគឺជាការចាំបាច់។ លទ្ធផលនៃការស្រាវជ្រាវបែបនេះ អាចត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោង ដែលចងក្រងឯកសារអំពីបទពិសោធន៍របស់អ្នក រួចជីវិតពីរបបខ្មែរក្រហមក៏ដូចជាការលើកកម្ពស់ការយល់ដឹង និងយុទ្ធនាការប្រាប់ការពិត។

- ***ស៊ើបអង្កេតអំពីឥរិយាបថ ទស្សនៈ តម្រូវការ និងផលប្រយោជន៍របស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម។*** មកទល់ពេលនេះ ជនរងគ្រោះពិតប្រាកដដោយអំពើហិង្សាលើយេនឌ័រមានសម្លេងតិចតួចបំផុត នៅក្នុងការអភិវឌ្ឍន៍គម្រោងដែលផ្ដល់សេវាសម្រាប់ពួកគេ ឬដំណើរការយុត្តិធម៌អន្តរកាលដ៏ទូលំទូលាយ។ ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងដើម្បីកំណត់ថា តើជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រយល់ដឹងពីដំណើរការយុត្តិធម៌អន្តរកាល ដែលកំពុងអនុវត្តនៅកម្ពុជាដោយរបៀបណា និងថាតើពួកគេត្រូវការអ្វី ដើម្បីទទួលយកបទពិសោធន៍ទាំងនេះ និងថាតើពួកគេចង់ចូលរួមបែបណានៅក្នុងគំនិតផ្ដួចផ្ដើមបច្ចុប្បន្ន និងអនាគត។ ព័ត៌មានដែលប្រមូលបានតាមរយៈដំណើរការនេះនឹងមានប្រយោជន៍ក្នុងការអភិវឌ្ឍន៍គម្រោង និងកម្មវិធីសំដៅចំពោះជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។ វិសេសវិសាលជាងនេះ ការស្រាវជ្រាវបែបនេះនឹងអាចសម្រេចបានដោយប្រើវិធីសាស្ត្រស្រាវជ្រាវដោយមានការចូលរួមដែលពាក់ព័ន្ធនិងផ្ដល់អំណាចដល់ជនរងគ្រោះ។
- ***ធ្វើការសិក្សាបន្ថែមអំពីអំពើហិង្សាលើយេនឌ័រ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលផ្ដោតទៅលើការវាយតម្លៃអំពើហិង្សាលើយេនឌ័រតាមរយៈក្របខ័ណ្ឌច្បាប់អន្តរជាតិ យុត្តិសាស្ត្រ និងដំណើរការកែទម្រង់យុត្តិធម៌។*** ការជឿនលឿនជាច្រើនក្នុងការចោទប្រកាន់អំពីអំពើហិង្សាលើយេនឌ័រជាឧក្រិដ្ឋកម្មមកលើមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍បានកើតឡើង ដោយសារតែមានការចោទប្រកាន់នៅចំពោះមុខសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី **(ICTY)**សាលាក្ដីព្រហ្មទណ្ឌ

[២] *សូមមើល* Farina So, *The Hijab of Cambodia: Memories of Cham Muslim Women after the Khmer Rouge* (Phnom Penh: DC-Cam, ២០១១)។

អន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា **(ICTR)** និងតុលាការពិសេសសម្រាប់ប្រទេសសារ៉ាឡេអូន **(SCSL)**។ អ្នកប្រឹក្សាច្បាប់ អ្នកជំនាញ និងជនរងគ្រោះក៏បានចាប់ផ្តើមបង្វែរការយកចិត្តទុកដាក់របស់ពួកគេទៅលើសំណាងជំងឺចិត្ត និងគំនិតផ្តួចផ្តើមកែទម្រង់យុត្តិធម៌ ដែលស្វះស្វែងទប់ស្កាត់ការកើតមានជាថ្មីនូវអំពើហិង្សាលើយេនឌ័រ និងផ្លាស់ប្តូររចនាសម្ព័ន្ធសង្គម និងថាមពលដែលតែងតែជំរុញឲ្យមានអំពើហិង្សាលើយេនឌ័រ។ ការស្រាវជ្រាវគួរតែត្រូវបានធ្វើឡើងដើម្បីគាំទ្រដល់ការវិនិច្ឆ័យលើឧក្រិដ្ឋកម្មទាំងនេះ កំណត់ផលប៉ះពាល់នៃអំពើហិង្សាលើយេនឌ័រ នៅក្នុងសហគមន៍នានាក្នុងរយៈពេលវែង និងរយៈពេលខ្លី និងកំណត់អព្ភូតហេតុសង្គម និងវប្បធម៌ ដែលបង្កឲ្យមានអំពើហិង្សាលើយេនឌ័រនៅក្នុងសង្គមកម្ពុជា។

- ***ធ្វើការសិក្សាឲ្យទូលំទូលាយអំពីអំពើហិង្សាលើយេនឌ័រក្នុងរយៈពេលបន្តនៃអំពើហិង្សា និងអស្ថិរភាពនយោបាយដែលធ្លាប់កើតមាននៅកម្ពុជា។*** ទាំងសម័យមុន និងសម័យក្រោយការគ្រប់គ្រងរបស់ខ្មែរក្រហមត្រូវបានកត់សម្គាល់ដោយភាពចលាចល និងជម្លោះដ៏គួរឲ្យកត់សម្គាល់។ប្រជាជនកម្ពុជាបានឆ្លងកាត់សង្គ្រាមស៊ីវិលដ៏យូរលង់អស់រយៈពេលជិត៤ឆ្នាំក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម និងជម្លោះជាមួយវៀតណាម និងជម្លោះនយោបាយជាច្រើនឆ្នាំ និងអំពើហិង្សាដែលបានបន្តក្រោមការគ្រប់គ្រងរបស់វៀតណាម។ អ្នកឆ្លើយសំណួរនៅក្នុងការសិក្សានេះ ព្រមទាំងប្រភពផ្សេងទៀត បានរាយការណ៍អំពីអំពើហិង្សាលើយេនឌ័រដែលបានកើតឡើងក្នុងអំឡុងសម័យជម្លោះប្រដាប់អាវុធអសន្តិសុខ និងអស្ថិរភាពនយោបាយ។ ដើម្បីយល់អំពីបរិបទពេញលេញនៃអំពើហិង្សាលើយេនឌ័រ និងបង្ហាញទិដ្ឋភាពទាំងមូលនៃបទពិសោធន៍របស់ជនរងគ្រោះ អ្វីដែលជាការសំខាន់គឺត្រូវសិក្សាឈ្វេងយល់អំពីបញ្ហា និងព្រឹត្តិការណ៍នានានៅក្នុងសម័យនោះ។
- ***ធ្វើការសិក្សាអំពីអំពើហិង្សាលើយេនឌ័រដែលបានកើតឡើងនៅកម្ពុជាបច្ចុប្បន្ន។*** កង្វះការយល់ដឹង ការយកចិត្តទុកដាក់នៅក្នុងអំពើហិង្សាលើយេនឌ័រត្រូវបានកំណត់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យប៉ុន្តែត្រូវបានអនុវត្តនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃ។[៣] វប្បធម៌ទូទៅនៃការនៅស្ងៀមមិននិយាយស្តីនៅលើប្រធានបទ និងនិទណ្ឌភាពចំពោះឧក្រិដ្ឋកម្មទាំងនេះ

[៣] *សូមមើល ឧ.* Cambodian League for the Promotion and Defence of Human Rights (LICADHO), *Rape and Indecent Assaults Cases, and the Cambodian Justice System* (Phnom Penh: LICADHO, ២០០៤) ៦ (កត់សម្គាល់ឃើញថា "កម្ពុជាប្រឈមមុខនឹងវិបត្តិឧក្រិដ្ឋកម្មផ្លូវភេទលើស្ត្រី និងកុមារ" និង "ឧក្រិដ្ឋកម្មផ្លូវភេទមានផលវិបាកយ៉ាងធំធេងសម្រាប់ជនរងគ្រោះម្នាក់ៗ និងសង្គម កម្ពុជាផងដែរ") និង Amnesty International, *Breaking the Silence: Sexual Violence in Cambodia* (London: Amnesty International, ២០១០) ៥ (ការបញ្ជាក់ថា "នគរបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីសាធារណៈដែលធ្វើការដោះស្រាយបញ្ហានេះ យល់ស្របថា ការរំលោភសេពសន្ថវៈបានកើនឡើង" ហើយ "សេវាដ៏សមស្របសម្រាប់ជនរងគ្រោះនៅខ្វះខាតច្រើន និងឆ្លុះបញ្ចាំងពីឥរិយាបថសង្គមស្តីពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាលើផ្លូវភេទ")។

# សេចក្តីសង្ខេប

ធ្វើឲ្យជនរងគ្រោះមានអារម្មណ៍ថា នៅតែមានការមាក់ងាយ ទោះបីពួកគេជាជនរងគ្រោះបច្ចុប្បន្នក្តី ឬក្រោមការគ្រប់គ្រងនៅសម័យខ្មែរក្រហមក្តី។ ការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាលើយេនឌ័រនាពេលបច្ចុប្បន្ន ដែលប្រទេសកម្ពុជាបានបម្រើផលប្រយោជន៍ដល់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រកាលពីអតីតកាលបច្ចុប្បន្ន និងអនាគតដោយលើកឡើងពីស្ថានភាពនៃបញ្ហានេះ និងបង្កើតកិច្ចពិភាក្សាជាសាធារណៈអំពីប្រធានបទដែលអាចប្រឈមមុខនឹងការមាក់ងាយក្នុងសង្គម ដែលជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រធ្លាប់ទទួលរងប្រឆាំងនឹងនិទណ្ឌភាពជុំវិញឧក្រិដ្ឋកម្មទាំងនេះ និងលាតត្រដាងបញ្ហាដ៏សំខាន់នេះ។

- ***រៀបចំគម្រោងស្រាវជ្រាវដែលត្រូវទាក់ទងទៅអ្នកឆ្លើយសំណួរម្តងហើយម្តងទៀត ដើម្បីអាចកសាងទំនុកចិត្តគ្រប់គ្រាន់ ដើម្បីឲ្យពួកគេមានអារម្មណ៍ថា មានសុវត្ថិភាពក្នុងការចែករំលែកបទពិសោធន៍របស់ពួកគេអំពីអំពើហិង្សាលើយេនឌ័រ។*** គេបានរៀបចំចងក្រងនៅក្នុងឯកសារស្រាវជ្រាវស្តីពីការសិក្សាស្រាវជ្រាវអំពើហិង្សាលើយេនឌ័រ ដែលគម្រោងសិក្សានេះ គួរតែបង្កើតឲ្យមានបរិយាកាសប្រកបដោយសុវត្ថិភាពឲ្យបានច្រើនតាមតែអាចធ្វើទៅបានសម្រាប់ជនរងគ្រោះមកចែករំលែករឿងរ៉ាវរបស់ពួកគេ។ គេបានពិចារណាយ៉ាងដិតដល់អំពីបញ្ហាសុវត្ថិភាព និងសន្តិសុខរបស់អ្នកឆ្លើយសំណួរនៅក្នុងការអភិវឌ្ឍន៍លើការសិក្សានេះ ប៉ុន្តែធនធានមានកម្រិតទាំងនេះ មិនបានអនុញ្ញាតឲ្យមានធាតុផ្សំនៃគម្រោងមួយចំនួនដែលត្រូវបានពិចារណានោះទេ។



ការពិតនេះអាចមានផលប៉ះពាល់ទៅលើចំនួនជនរងគ្រោះផ្ទាល់ដោយអំពើហិង្សាលើយេនឌ័រ ដែលត្រូវបានកំណត់នៅក្នុងការសិក្សានេះ។ នៅពេលខាងមុខ អ្នកស្រាវជ្រាវគួរតែព្យាយាមធានាថា ពួកគេមានមូលនិធិ និងពេលវេលាគ្រប់គ្រាន់ ដើម្បីកសាងទំនុកចិត្ត និងអារម្មណ៍អំពីសុវត្ថិភាពដែលចាំបាច់ក្នុងការលើកទឹកចិត្តឲ្យជនរងគ្រោះបញ្ចេញមតិ។

# ២. សេចក្តីផ្តើម



គម្រោងស្រាវជ្រាវនេះត្រូវបានធ្វើឡើងដើម្បីលើកកម្ពស់ និងធ្វើឲ្យមានការយល់ដឹងស៊ីជម្រៅអំពីវិសាលភាព និងលក្ខណៈសម្គាល់នៃអំពើហិង្សាលើយេនឌ័រ ដែលបានកើតឡើងក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ[៩] ជាសម័យគ្រប់គ្រងបែបផ្តាច់ការដ៏ឃោរឃៅដែលនាំឲ្យកើតមានសង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនឆ្នាំនៅកម្ពុជា និងអស្ថិរភាពនៅក្នុងប្រទេស និងតំបន់។ ទោះបីជាប្រភពជាច្រើនយោងទៅលើអំពើហិង្សាលើយេនឌ័រ ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមក៏ដោយ ក៏អំពើហិង្សានេះភាគច្រើនលែងមាននៅក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈ អំពីអំពើឃោរឃៅរបស់ខ្មែរក្រហម និងត្រូវបានបង្ហាញឲ្យឃើញតិចតួចប៉ុណ្ណោះតាមរយៈការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនៅសាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមរបស់កម្ពុជាដែលហៅថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។



ក្នុងការលើកកំពស់ទៅលើការស្រាវជ្រាវកន្លងមកដែលគូសបញ្ជាក់ថា អំពើហិង្សាលើយេនឌ័រមិនត្រឹមតែបានកើតឡើងក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ការសិក្សានេះថែមទាំងលើកឡើងថា រូបភាពពេញលេញបង្ហាញពីអ្វីដែលបានកើតឡើង នរណាជាជនរងគ្រោះ នរណាជាអ្នកទទួលខុសត្រូវ ហើយរបៀបដែលមេដឹកនាំរបបនេះមានប្រតិកម្មយ៉ាងណា នៅតែត្រូវបានយកមកលាតត្រដាងនៅឡើយ។ ថ្វីបើជាង៣០ឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យនេះក្តី ក៏អ្នកដែលត្រូវបានសម្ភាសនៅក្នុងការសិក្សាស្រាវជ្រាវនេះ និងការសិក្សាផ្សេងទៀតបានគូររូបភាពច្បាស់លាស់អំពីរបៀបដែលអំពើហិង្សាលើយេនឌ័រអាចដំណើរការទៅក្នុងបរិយាកាសប្រកបដោយការភ័យខ្លាចការគ្រប់គ្រង និងនិទណ្ឌភាពដែលធ្វើឡើងដោយរបបខ្មែរក្រហម។ បច្ចុប្បន្នខណៈពេលដែលជនរងគ្រោះពីសម័យខ្មែរក្រហម និងប្រទេសកម្ពុជាឆ្លុះបញ្ចាំងពីភាពអន្ធការនៃប្រវត្តិសាស្ត្ររបស់ខ្លួនតាមរយៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងយន្តការយុត្តិធម៌អន្តរកាលផ្សេងទៀត លក្ខណៈនៃការធ្វើទុក្ខបុកម្នេញដោយពួកខ្មែរក្រហមត្រូវយកមកលាតត្រដាងឲ្យបានឆាប់រហ័សជាងនេះ។

នៅពេលដែលប្រទេសកម្ពុជាដើបចេញពីរបបខ្មែរក្រហម ៣ឆ្នាំ ៨ខែ ២០ថ្ងៃ កាលពីថ្ងៃទី០៧

[៩] ពាក្យកម្ពុជាប្រជាធិបតេយ្យ និងខ្មែរក្រហមអាចប្រើមួយណាក៏បាននៅក្នុងរបាយការណ៍នេះ ដើម្បីគូសបញ្ជាក់ពីរយៈពេលចន្លោះថ្ងៃទី ១៧ មេសា ១៩៧៥ និងថ្ងៃទី០៧ មករា ១៩៧៩ នៅពេលដែលខ្មែរក្រហមបានត្រួតត្រាប្រទេសទាំងមូល។

# សេចក្តីផ្តើម

មករា ១៩៧៩ គេមិនទាន់បានបង្កើតពាក្យអំពើហិង្សាលើយេនឌ័រនៅឡើយទេ។ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ ភាពងាយរងគ្រោះដ៏ចម្បងរបស់ស្ត្រី និងកុមារក្នុងពេលមានសង្គ្រាមនិងជម្លោះត្រូវបានឈ្វេងយល់ និងបានចងក្រងជាឯកសារសម្រាប់ពិភពលោក ខណៈពេលដែលមាននិន្នាការនៅក្នុងសង្គមក្រោយជម្លោះដែលមើលរំលង ឬកាត់បន្ថយអំពើហិង្សាសំដៅចំពោះក្រុមងាយរងគ្រោះទាំងនេះ។ បច្ចុប្បន្នអំពើហិង្សាលើយេនឌ័រត្រូវបានឈ្វេងយល់យ៉ាងទូលំទូលាយដើម្បីធ្វើប្រតិបត្តិការដោយឈរលើមូលដ្ឋាននៃស្ត្រីដែលមានឋានៈទាបនៅក្នុងសង្គម និងអតុល្យភាពអំណាច និងភាពងាយរងគ្រោះដែលកើតមានចំពោះស្ត្រី និងកុមារី ទាំងកម្រិតផ្ទាល់ខ្លួន និងកម្រិតរចនាសម្ព័ន្ធ។ បច្ចុប្បន្នគេយល់ថា កម្លាំងនិងកត្តាជម្រុញដែលនាំឲ្យស្ត្រី និងកុមារីប្រឈមមុខនឹងអំពើហិង្សាលើយេនឌ័រក្នុងសម័យសន្តិភាព ជារឿយៗត្រូវគេកេងប្រវ័ញ្ច និងធ្លាក់ក្នុងស្ថានភាពកាន់តែធ្ងន់ធ្ងរក្នុងពេលមានសង្គ្រាម និងជម្លោះដោយបង្កឲ្យមានផលប៉ះពាល់នៅក្នុងសង្គមគ្រប់ជាន់ថ្នាក់ពីបុគ្គលម្នាក់ៗ និងលាតសន្ធឹងចាប់ពីពេលដែលអំពើហិង្សាលើយេនឌ័រនៅក្នុងជម្លោះប្រដាប់អាវុធកើតឡើងរហូតដល់ពេលអនាគត។

ការស្រាវជ្រាវនេះត្រូវធ្វើឡើង ដើម្បីជួយនាំយកបទពិសោធន៍ពីអំពើហិង្សាលើយេនឌ័រ ក្រោមរបបខ្មែរក្រហមមកដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍ជាសាធារណៈឲ្យបានទូលំទូលាយស្តីពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដើម្បីដាក់បញ្ចូលអំពើហិង្សាលើយេនឌ័រទៅក្នុងបរិបទនៃការយល់ដឹងសម័យបច្ចុប្បន្នអំពីអំពើហិង្សាបែបនេះ ដើម្បីគាំទ្រដល់ការដាក់បញ្ចូលផ្នែកនៃប្រវត្តិសាស្ត្រកម្ពុជាទៅក្នុងយន្តការយុត្តិធម៌អន្តរកាល ដែលប្រទេសកម្ពុជាបានអនុវត្តនាបច្ចុប្បន្ន និងអនាគត និងដើម្បីប្រយុទ្ធប្រឆាំងនឹងមតិកនៃនិទណ្ឌភាពចំពោះអំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចជាបន្តកើតមាននៅកម្ពុជាសព្វថ្ងៃ។

របាយការណ៍ស្រាវជ្រាវដែលនៅសល់ត្រូវបានរៀបចំជា៤ផ្នែកសំខាន់ៗ ចាប់ផ្តើមដោយផ្នែកទី៣នៃរបាយការណ៍ដែលលម្អិតអំពីគម្រោង និងវិធីសាស្ត្រដែលប្រើនៅក្នុងការសិក្សានេះ។ ផ្នែកទី៤ផ្តល់ព័ត៌មានសារតា ក្នុងគោលបំណងផ្តល់នូវបរិបទមួយចំនួនដែលរបកគំហើញពីការស្រាវជ្រាវបច្ចុប្បន្នអាចត្រូវបានឈ្វេងយល់ឲ្យកាន់តែច្បាស់លាស់ថែមទៀត។ ផ្នែកនៃសារតា នេះរួមមានកិច្ចពិភាក្សាអំពីប្រវត្តិសាស្ត្រ និងទម្លាប់អនុវត្តរបស់របបខ្មែរក្រហមព្រមទាំងការប្រព្រឹត្តចំពោះស្ត្រី និងក្រុមគ្រួសារក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។ ផ្នែកនេះពិភាក្សាខ្លីៗអំពីទស្សនាទានសហសម័យនៃធម្មជាតិ និងប្រភពដើមនៃអំពើហិង្សាលើយេនឌ័រនៅក្នុងជម្លោះប្រដាប់អាវុធ។ ផ្នែកនេះសន្និដ្ឋាន ដោយការពិនិត្យឡើងវិញនូវការស្រាវជ្រាវពីដំបូង និងបទអត្ថាធិប្បាយអំពីប្រធានបទស្តីពីអំពើហិង្សាលើយេនឌ័រក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការប្រព្រឹត្តអំពើហិង្សាផ្អែក

# សេចក្តីផ្តើម

លើយេនឌ័រត្រូវបានបង្ហាញ នៅក្នុងដំណើរការនីតិវិធីដែលកំពុងអនុវត្តបច្ចុប្បន្ន នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ផ្នែកទី៥នៃរបាយការណ៍នេះបង្ហាញពីរបកគំហើញនៃការសិក្សាស្រាវជ្រាវនេះ។ ផ្នែកនេះរួមមានការពិនិត្យឡើងវិញនូវលក្ខណៈសម្គាល់ប្រជាសាស្ត្ររបស់អ្នកឆ្លើយសំណួរស្រាវជ្រាវរបស់យើងបន្ទាប់មករបកគំហើញពីការសិក្សាស្រាវជ្រាវ ដែលត្រូវបានបែងចែកប្រភេទនៃអំពើហិង្សាលើយេនឌ័រដែលត្រូវបានរាយការណ៍ ហើយនៅចុងបញ្ចប់ការពិភាក្សាតាមប្រធានបទអំពីថា តើគេអាចឈ្វេងយល់អំពីរបកគំហើញទាំងនេះដោយរបៀបណា ហើយតើរបកគំហើញទាំងនេះលើកឡើងពីអ្វីខ្លះ។ របាយការណ៍នេះត្រូវបានបញ្ចប់ដោយមួយផ្នែកដែលបាននិយាយលម្អិតអំពីសេចក្តីសន្និដ្ឋានដែលគេបានទាញចេញពីការស្រាវជ្រាវនេះ ហើយដែលនាំមកនូវអនុសាសន៍ដែលមានបង្ហាញនៅក្នុងផ្នែកសង្ខេបសំខាន់នៃរបាយការណ៍នេះ។



# ៣. គម្រោងសិក្សា

ដោយផ្តោតទៅលើការសិក្សាឈ្វេងយល់ថ្មីៗឲ្យបានស៊ីជម្រៅអំពីអំពើហិង្សាលើយេនឌ័រ ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគម្រោងអង្កេតរួមមាន សំណួរស្រាវជ្រាវដែលត្រូវបានលើកឡើង និងវិធីសាស្ត្រដែលយកមកប្រើដើម្បីឆ្លើយសំណួរទាំងនេះត្រូវបានរៀបរាប់ភាគច្រើនតាមរយៈការសិក្សាពីមុនមក ក៏ដូចជាទស្សនៈ និងព័ត៌មានដែលទទួលបានតាមរយៈបទសម្ភាសន៍សំខាន់ៗពីអ្នកឆ្លើយសំណួរក្នុងអំឡុងពេលធ្វើគម្រោងសិក្សានេះ។ ក្នុងការឆ្លើយតបទៅនឹងប្រភពទាំងនេះ ព្រមទាំងការពិចារណាជាក់ស្តែង ការសិក្សានេះត្រូវបានធ្វើឡើងនៅក្នុងខេត្តពីរ រួមមានខេត្តបាត់ដំបង និងស្វាយរៀង។

ហេតុផលនៃការជ្រើសរើសកន្លែងទាំងនោះគឺមានបួនយ៉ាង។ ទី១ ការមានកំរិតខាងធនធានបង្ហាញថា វិសាលភាព ភូមិសាស្ត្រ នៃការងារមូលដ្ឋានសម្រាប់ការសិក្សានេះត្រូវកំណត់។ ទី២ ពីមុនមកគេមិនបានធ្វើការសិក្សាផ្តោតលើភូមិសាស្ត្រ អំពីអំពើហិង្សាលើយេនឌ័រនៅក្នុងខេត្តទាំងពីរនេះទេ។ ទី៣ ក្នុងបទសម្ភាសន៍ ដែលត្រូវបានធ្វើឡើងជាមួយអ្នកជំនាញតាមមូលដ្ឋានគេបានស្នើសុំម្តងហើយម្តងទៀតថា អំពើហិង្សាលើយេនឌ័រអាចកាន់តែមានលក្ខណៈទូទៅនៅក្នុងខេត្តស្វាយរៀង និងតំបន់នានាដែលគេបានជម្លៀសប្រជាជននៅខេត្តស្វាយរៀងក្នុងនោះក៏មានខេត្តបាត់ដំបងផងដែរ។ ទី៤ គេក៏បានលើកឡើងផងដែរថា អំពើហិង្សាលើយេនឌ័រអាចកាន់តែមានលក្ខណៈទូទៅនៅក្នុងតំបន់ ដែលនៅជិតពន្ធនាគារ និងកន្លែងប្រហារជីវិតដូច្នេះ ហើយបានជាគេធ្វើការស្រាវជ្រាវនៅជិតទីតាំងបែបនេះនៅក្នុងខេត្តទាំងនេះ។[៥]



*ក្រុមការងារស្រាវជ្រាវនៅក្នុងខេត្តស្វាយរៀង*

## ៣.១ សំណួរស្រាវជ្រាវ

ការសិក្សានេះត្រូវបានរៀបចំឡើង ដើម្បីប្រមូលទិន្នន័យសម្រាប់ឆ្លើយសំណួរដូចខាងក្រោម៖

- តើអំពើហិង្សាយេនឌ័រប្រភេទអ្វីខ្លះបានកើតឡើងនៅក្នុងខេត្តបាត់ដំបង និងស្វាយរៀង ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម?

[៥] គេបានធ្វើការសិក្សាស្រាវជ្រាវនៅក្នុងតំបន់ដែលនៅជិតវត្តគិរីរម្យ វត្តធ្លក និងវត្តបឹងរ៉ែ។ ទីតាំងទាំងបីនេះមានឈ្មោះនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ បច្ចុប្បន្ននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ *សូមមើលដីការដំណោះស្រាយ* (សាធារណៈ) លេខសំណុំរឿង: ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ D427 ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១០(ពីនេះតទៅ សំណុំរឿង០០២ ដីកាដំណោះស្រាយ)។

- តើនរណាជាជនរងគ្រោះដោយអំពើហិង្សានេះ ហើយនរណាជាជនដៃដល់?
- តើព័ត៌មានលម្អិត និងលក្ខណៈសម្គាល់នៃអំពើហិង្សានេះ មានដូចជាទីតាំង និងស្ថានភាព ដែលអំពើហិង្សានេះបានកើតឡើងគឺមានអ្វីខ្លះ?
- តើបទពិសោធន៍នៃអំពើហិង្សាលើយេនឌ័រនៅក្នុងតំបន់ទាំងនេះមានលក្ខណៈខុសគ្នាឬដូចគ្នាយ៉ាងណាខ្លះៈឬយកលក្ខណៈសម្គាល់ដែលត្រូវបានរាយការណ៍ អំពីការសិក្សាអំពើហិង្សាលើយេនឌ័រនេះមកអនុវត្តយ៉ាងដូចម្ដេចនៅក្នុងតំបន់ផ្សេងៗទៀតនៃប្រទេស?

## ៣.២ វិធីសាស្ត្រ

អ្នកឆ្លើយសំណួរសម្រាប់ការសិក្សាស្រាវជ្រាវនេះ ត្រូវបានជ្រើសរើសជាលើកដំបូងសរុបចំនួន ៨ឃុំស្ថិតក្នុងខេត្តទាំងពីរ គឺខេត្តបាត់ដំបង និងស្វាយរៀង ដោយប្រើវិធីសាស្ត្រ **"snowball"**។[៦] បទសម្ភាសន៍លើកដំបូងត្រូវបានធ្វើឡើងជាមួយបុគ្គលដែលត្រូវបានជ្រើសរើសតាមរយៈអន្តរការី[៧] នៅក្នុងសហគមន៍មូលដ្ឋានរបស់ពួកគេ ដោយប្រើលក្ខណៈវិនិច្ឆ័យ ដែលជាការបង្ហាញថានឹងទទួលរងអំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការនេះរួមមានបុគ្គលៈ

- ដែលគេបានគិត ឬដឹងថា បានឃើញ ឬទទួលរងអំពើហិង្សាលើយេនឌ័រ
- ដែលបានធ្វើការនៅជិតពន្ធនាគារ ឬកន្លែងប្រហារជីវិត
- អ្នកមានអំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
- ដែលត្រូវបានគេគិតថាបានទទួលរង ជាពិសេសការព្យាបាទធ្ងន់ធ្ងរ
- ដែលបានធ្វើការនៅទីខ្ពស់ៗ (ដូចជា ឡើងដើមឈើ ឬ ឡើងភ្នំ)
- និង/ឬបានធ្វើការជាឆ្មប ឬគ្រូពេទ្យក្នុងសម័យខ្មែរក្រហម។ នៅពេលបិទបទសម្ភាសន៍នីមួយៗ អ្នកឆ្លើយសំណួរត្រូវបានសួរថា តើមាននរណាម្នាក់ផ្សេងទៀតដែលពួកគេមានអារម្មណ៍ថា ក្រុមស្រាវជ្រាវនេះគួរតែសម្ភាសដែរឬយ៉ាងណា ឬអាចមានព័ត៌មានអំពីប្រធានបទដែលមាននៅក្នុងបទសម្ភាសន៍នេះដែរឬយ៉ាងណា។ នៅពេលដែលមានពេលវេលា និងធនធានគ្រប់គ្រាន់ អ្នកផ្ដល់ពត៌មានបន្ថែមទាំងនេះក៏ត្រូវយកមកបញ្ចូលក្នុងបទសម្ភាសន៍ជាមួយក្រុមស្រាវជ្រាវនេះផងដែរ។

[៦] នៅក្នុងសំណាក "snowball" អ្នកផ្ដល់ព័ត៌មានដែលត្រូវបានជ្រើសរើសជាមុនត្រូវបានសម្ភាស និងស្នើសុំឲ្យលើកឡើងពីបុគ្គលបន្ថែមទៀតដែលអាចត្រូវបានសម្ភាសក្នុងប្រធានបទតែមួយ។ អ្នកផ្ដល់ព័ត៌មានបន្ទាប់ត្រូវបានជ្រើសរើសផ្អែកលើសំណូមពរទាំងនេះ។ ការធ្វើសំណាក "snowball" មិនមែនធ្វើដោយមិនច្បាស់លាស់នោះទេ (គេមិនអាចប្រើទិន្នន័យសំណាកដើម្បីបង្ហាញពីលក្ខណៈណាមួយនៃអ្នកឆ្លើយសំណួរ) និងគោលបំណង (សំណាកនេះត្រូវបានកំណត់តាមគោលបំណង និងមិនមែនធ្វើព្រាវៗនោះទេ)។

[៧] អន្តរការីត្រូវបានជ្រើសរើសតាមរយៈអង្គការសង្គមស៊ីវិល និងទំនាក់ទំនងមូលដ្ឋាន។ អន្តរការីមានជាអាទិ៍ មេភូមិ និង មេឃុំ បុគ្គលិកអង្គការសង្គមស៊ីវិល និងអ្នកតំណាងស្ត្រីមូលដ្ឋាន។

# គម្រោងសិក្សា

បទសម្ភាសន៍ទាំងនេះត្រូវបានធ្វើឡើងម្នាក់ទល់ម្នាក់ជាមួយអ្នកឆ្លើយសំណួរក្នុងលក្ខណៈសម្ងាត់ នៅឯ ឬនៅជិតផ្ទះរបស់ពួកគេដែលក្នុងនោះអ្នកសម្ភាសន៍សួរទៅកាន់អ្នកឆ្លើយសំណួរដែលមានភេទដូចគ្នា។ អត្ថបទសរសេរជាគំរូដែលពន្យល់ពីគោលបំណង (ដើម្បីឈ្វេងយល់ និងរាយការណ៍អំពីអំពើហិង្សាផ្លូវភេទដែលបានកើតឡើងក្នុងរបបខ្មែរក្រហម) និងលក្ខណៈផ្សេងៗ (ការស្រាវជ្រាវឯករាជ្យ ដែលធ្វើឡើងដោយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល)ត្រូវបានប្រើដើម្បីណែនាំអំពីគម្រោង។ គេបានទទួលយកការព្រមព្រៀងដោយផ្ទាល់មាត់ ដោយប្រើនីតិវិធីដែលសង្កត់ទៅលើលក្ខណៈសម្ងាត់នៃបទសម្ភាសន៍ ហើយថាការចូលរួមនេះធ្វើឡើងដោយស្ម័គ្រចិត្តទាំងស្រុង (រួមមានសិទ្ធិបដិសេធមិនឆ្លើយសំណួរណាមួយ និងមានសិទ្ធិបញ្ឈប់បទសម្ភាសន៍នៅត្រង់ចំណុចណាមួយ)។អ្នកឆ្លើយសំណួរគ្រប់រូបត្រូវបានផ្តល់ព័ត៌មានអំពីសេវាគាំទ្រផ្លូវចិត្តតាមរយៈទូរស័ព្ទ ហើយអ្នកឆ្លើយសំណួរណាម្នាក់ ដែលប៉ះពាល់អារម្មណ៍ក្នុងអំឡុងពេលសម្ភាសន៍ត្រូវបានផ្តល់ឱកាសឲ្យពិភាក្សា ជាមួយអ្នកចិត្តសាស្ត្រក្នុងក្រុមស្រាវជ្រាវ។


អ្នកស្រាវជ្រាវសម្ភាសន៍ទៅធ្វើការ

កម្រងសំណួរបទសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធដែលមានសំណួរបិទតិច ហើយសំណួរបើកច្រើនជាង បង្កើតបានជាមូលដ្ឋាននៃបទសម្ភាសន៍។ សំណួរសម្ភាសន៍ទាំងនេះត្រូវបានចាត់ជាក្រុមតាមប្រភេទដូចខាងក្រោម៖ ព័ត៌មានប្រជាសាស្ត្រសង្គម ជីវិតក្រោមរបបខ្មែរក្រហម និងអំពើហិង្សាលើយេនឌ័រ (ឧ. ការកាត់អវៈយវៈភេទ ការកេងប្រវ័ញ្ចផ្លូវភេទ ទាសភាពផ្លូវភេទ/ការបង្ខំឲ្យធ្វើពេស្យាចារ្យ ការបំពានផ្លូវភេទ ការរំលោភសេពសន្ថវៈ ការធ្វើឲ្យអាម៉ាស់ខាងផ្លូវភេទ និងបញ្ហាផ្សេងទៀត)។ នៅពេលសង្កត់ធ្ងន់អំពីលក្ខណៈប្រមូលទិន្នន័យបែបគុណភាពអ្នកសម្ភាសន៍បានលើកទឹកចិត្តឲ្យ អ្នកឆ្លើយសំណួរបង្កើនចម្លើយទៅនឹងសំណួរនានា និងរៀបរាប់ពីព័ត៌មានដែលគិតថាពាក់ព័ន្ធ។ កម្រងសំណួរដំបូងត្រូវបានធ្វើជាភាសាអង់គ្លេស និងបន្ទាប់មកបកប្រែជាភាសាខ្មែរ។ ការពិនិត្យឡើងវិញលើការបកប្រែនេះត្រូវបានធ្វើឡើងជាមួយអ្នកជំនាញក្នុងមូលដ្ឋាន ហើយការបកប្រែឯកសារនេះត្រូវបានធ្វើឡើងដើម្បីធានាថា ភាសាដែលប្រើប្រាស់នេះគឺត្រឹមត្រូវ។ បន្ទាប់មកកម្រងសំណួរ ត្រូវបានយកមកសាកល្បងជាមួយអ្នកឆ្លើយសំណួរចំនួន២១នាក់នៅក្រៅកន្លែងសិក្សា ដើម្បីធានាឲ្យច្បាស់ថា កម្រងសំណួរទាំងនេះងាយយល់ និងសមស្របទៅតាមវប្បធម៌។

ការប្រមូលទិន្នន័យសម្រាប់ការសិក្សានេះ ត្រូវបានអនុវត្តដោយអ្នកសម្ភាសន៍មួយក្រុមមានគ្នា៨នាក់ ដែលត្រូវបានជ្រើសរើសផ្អែកលើការសិក្សាស្រាវជ្រាវកន្លងមក និងមានបទពិសោធន៍

សម្ភាសន៍ ក៏ដូចជាការអនុវត្តការងារនៅក្នុងវគ្គបណ្តុះបណ្តាលត្រៀមចុះមូលដ្ឋាន។ ការបណ្តុះបណ្តាលនេះត្រូវបានផ្តល់ជូន ក្រុមការងារមូលដ្ឋានស្តីពីវិធីសាស្ត្រសម្ភាសន៍ស្រាវជ្រាវ (ឧ. បច្ចេកទេសក្នុងការកាត់បន្ថយភាពមានលម្អៀង ការកែតម្រូវទិន្នន័យមានក្រមសីលធម៌នៅក្នុងការស្រាវជ្រាវ ជម្រាបពីការយល់ព្រមធ្វើការសម្ភាសន៍ ត្រូវបានយកចិត្តទុកដាក់លើបញ្ហាខាងយេនឌ័រ ការរក្សាការសម្ងាត់ជាដើម) ក៏ដូចជា ប្រធានបទ និងគោលបំណងនៃការសិក្សានេះ។ អ្នកសម្ភាសន៍ក៏បានចូលរួមក្នុងសកម្មភាពអនុវត្តតាមដានមុនពេលចាប់ផ្តើមការងារមូលដ្ឋាន។ នៅក្នុងផ្នែកនេះអ្នកសម្ភាសន៍បានធ្វើការជាក្រុមដែលមានចំនួន២នាក់ ដើម្បីសម្រួលដល់ការរក្សាការសម្ងាត់នៅកន្លែងសម្ភាសន៍ និងការពិនិត្យឡើងវិញនៅនឹងកន្លែងនូវរាល់ចម្លើយអង្កេតទាំងនោះនៅលើកម្រងសំណួរ។ មានអ្នកគ្រប់គ្រងតាមកន្លែងសម្ភាសន៍ពីរនាក់ពិនិត្យក្រុមសម្ភាសន៍ក្នុងការធានាថាបានប្រកាន់ខ្ជាប់ជានិច្ច នូវពិធីសាស្រសម្ភាសន៍ស្រាវជ្រាវ។ ពួកគេក៏បានធ្វើការពិនិត្យឡើងវិញជាលើកទី២លើកម្រងសំណួរអង្កេតនៅក្នុងមូលដ្ឋាន ដើម្បីកាត់បន្ថយការនាំមកនូវកំហុសឆ្គងពេលកែទិន្នន័យ។

## ៣.៣ ការកំណត់

គេបានប្រមើលឃើញថា ការសិក្សានេះមានលក្ខណៈជាទ្រង់ទ្រាយតូច និងពិនិត្យតាមដានការងារដែលអ្នកជំនាញនិងអ្នកធ្វើអត្ថាធិប្បាយពីមុនមកបានធ្វើឡើងដោយផ្អែកទៅលើប្រធានបទស្តីពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។ រាល់កិច្ចប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីសិក្សាឲ្យបានស៊ីជម្រៅអំពីការអនុវត្តវិធីសាស្ត្រ និងបច្ចេកទេសស្រាវជ្រាវដែលត្រូវបានសាកល្បងការប្រើប្រាស់ ក៏ដូចជាការផ្លាស់ប្តូរឲ្យមានការអនុវត្តល្អសម្រាប់ស្រាវជ្រាវជាក់លាក់ក្នុងប្រធានបទស្តីពីអំពើហិង្សាលើយេនឌ័រ ជាពិសេសក្នុងស្ថានភាពមានជម្លោះ និងក្រោយជម្លោះ។ ប៉ុន្តែ នៅតែមានដែនកំណត់ដែលត្រូវទទួលស្គាល់។



វគ្គបណ្តុះបណ្តាលទៅដល់អ្នកសម្ភាសន៍មុន
ការស្រាវជ្រាវត្រូវបានធ្វើ

ដូចដែលបានលើកឡើងខាងដើម ការសិក្សានេះត្រូវបានធ្វើឡើងផ្តោតលើទ្រង់ទ្រាយតូច និងដោយគ្មានលក្ខណៈជាតំណាង (ឧទាហរណ៍៖ មិនមែនប្រើប្រាស់សំណាកព្រាវៗនៃទំហំសំណាកគ្រប់គ្រាន់នោះទេ)។ ដូច្នេះគេមិនអាចយល់ឃើញថារបកគំហើញដែលត្រូវបានបង្ហាញនៅទីនោះ និងសេចក្តីសន្និដ្ឋានដែលបានមកពីរបកគំហើញទាំងនេះជាការបង្ហាញដ៏ទូលំទូលាយអំពីសហគមន៍នានា ដែលគេបានធ្វើការអង្កេតនៅទីនេះ ហើយក៏មិនមែនជាការបង្ហាញអំពីបទពិសោធន៍របស់

ប្រជាជនកម្ពុជាទូទៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

ព្រឹត្តិការណ៍ដែលការសិក្សានេះអង្កេតឃើញ ក៏បានកើតឡើងក្នុងអំឡុង៣០ឆ្នាំកន្លងមកនេះ។ វាជាការសមហេតុផល ដែលការចងចាំ និងព័ត៌មានដែលអ្នកឆ្លើយសំណួរបានផ្តល់នេះអាចរងផលប៉ះពាល់ ដោយសារតែពេលវេលាកន្លងផុតទៅ ឬធ្វើអន្តរាគមន៍ព្រឹត្តិការណ៍ ដែលនាំឲ្យនឹកឃើញកំហុស ឬការលម្អៀង។ ទោះជាយ៉ាងនោះក្តី សំណួរទាំងនេះត្រូវបានបង្កើតឡើង ដើម្បីផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងភាពស៊ីសង្វាក់គ្នានៃចម្លើយ ហើយទិន្នន័យស្តីពីជនសង្ស័យមិនត្រូវបានរាយការណ៍នៅទីនេះទេ។

រាល់កិច្ចប្រឹងប្រែងទាំងអស់ត្រូវបានធ្វើឡើង ដើម្បីសម្ភាសអ្នកឆ្លើយសំណួរឲ្យបានច្រើនតាមតែអាចធ្វើទៅបានរួមមាន អ្វីៗដែលត្រូវបានលើកឡើងដោយអ្នកឆ្លើយសំណួរនៅជុំទីមួយ។ ប៉ុន្តែសមត្ថភាពរបស់ក្រុមស្រាវជ្រាវក្នុងការគ្រោងរៀបចំបទសម្ភាសន៍ជុំទីពីរត្រូវបានកំណត់តាមពេលវេលា និងធនធានដែលមាន។ ក្នុងចំណោមក្រុមដែលមិនអាចសម្ភាសគឺភាគច្រើនជាបុគ្គលដែលអ្នកឆ្លើយសំណួរជឿថា ជាជនរងគ្រោះផ្ទាល់ដោយអំពើហិង្សាលើយេនឌ័រ។ ទោះបីជាមិនអាចដឹងអ្វីដែលបុគ្គលទាំងនេះបានរាយការណ៍ក៏ដោយ ក៏ការកំណត់នេះអាចមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសមាមាត្រនៃជនរងគ្រោះផ្ទាល់ ដែលត្រូវបានបង្ហាញនៅក្នុងការសិក្សានេះ និងគួរតែបានយកមកពិចារណា។ ជាចុងក្រោយនេះ ទោះបីជាគេយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបង្កើតសំណួរដែលងាយយល់ច្បាស់លាស់ និងសមស្របតាមវប្បធម៌ក៏ដោយ ក៏សំណួរសម្ភាសន៍ទាំងនេះមិនត្រូវបានយល់ច្បាស់ ឬត្រូវបានបកស្រាយដោយអ្នកឆ្លើយសំណួរខុសពីអត្ថន័យដែលអ្នកស្រាវជ្រាវចង់បាន។ សក្តានុពលនៃបញ្ហាទាំងនេះត្រូវបានកាត់បន្ថយតាមរយៈដំណើរការដ៏ប្រុងប្រយ័ត្នក្នុងការបង្កើត និងពិនិត្យមើលកម្រងសំណួរ ក៏ដូចជាលក្ខណៈបើកទូលាយនៃសំណួរជាច្រើន ដែលអនុញ្ញាតឲ្យអ្នកឆ្លើយសំណួរផ្តល់ចម្លើយឲ្យបានពេញលេញ និងកាន់តែលម្អិតថែមទៀត។ ក្នុងករណីដែលមានការភាន់ច្រឡំ កិច្ចពិភាក្សារយៈពេលវែងអំពីប្រធានបទនីមួយៗក្នុងលក្ខណៈបើកចំហនេះ អនុញ្ញាតឲ្យអ្នកនិពន្ធក្តាប់បានយ៉ាងច្បាស់លាស់នូវអត្ថន័យដែលអ្នកឆ្លើយសំណួរបាននិយាយយោងទៅសំណួរ និងវិភាគទិន្នន័យនោះតាមតែអាចធ្វើទៅបាន។

# ៤. សាវតា



## ៤.១ ពួកខ្មែរក្រហម និងកម្ពុជាប្រជាធិបតេយ្យ

ប្រជាជនកម្ពុជាបានឆ្លងកាត់អស្ថិរភាព និងអំពើហិង្សាដ៏ខ្លាំងក្លាដែលចាប់ផ្តើមនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ និងសម័យកាលដែលទីក្រុងភ្នំពេញបានធ្លាក់ចូលក្នុងរបបខ្មែរក្រហមកាលពីថ្ងៃទី១៧ មេសា ១៩៧៥។[៨] ខ្មែរក្រហម ជាពាក្យទូទៅដែលគេប្រើដើម្បីសំដៅចំពោះគណបក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានបង្កើតឡើងដោយប្រជាជនកម្ពុជាមួយក្រុមតូច និងសមាជិកដែលភាគច្រើនក្នុងចំណោមអ្នកទាំងនោះបានរស់នៅ និងសិក្សានៅប្រទេសបារាំង។ ពួកគេបានត្រឡប់មកប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាពីរលើកជាប់គ្នា និងបានបង្កើតរបបកុម្មុយនីស្តនៅកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានថ្ងៃដំបូងនៃរដ្ឋដែលទើបបង្កើតថ្មីរបស់ខ្មែរក្រហម គឺមានឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ ប្រជាជននៅរាជធានីភ្នំពេញត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុងទាំងអស់គ្នា និងបានវិលត្រឡប់ទៅភូមិកំណើតរបស់ពួកគេ ឬទិសដៅផ្សេងទៀតនៅជនបទ។ ក្នុងរយៈពេលប៉ុន្មានខែក្រោយមកដំណើរការស្រដៀងគ្នាមួយត្រូវបានអនុវត្តនៅតាមទីរួមខេត្តផ្សេងទៀត។[៩] ក្នុងអំឡុងរបបនោះភាគច្រើនអ្នកដែលគេស្គាល់អត្តសញ្ញាណថា ជាអ្នកមានទ្រព្យធន មានចំណេះខ្ពស់ជាប់ពាក់ព័ន្ធនឹងរបបពីមុនមក ឬអ្នកដែលត្រូវគេចាត់ទុកថាជាឧបសគ្គ ឬគំរាមកំហែងដល់របបថ្មីត្រូវបានសម្លាប់ចោលជាប្រព័ន្ធ។[១០] សមាជិកក្រុមជនជាតិភាគតិច ឬក្រុមសាសនា រួមមានជនជាតិវៀតណាម ចាមមូស្លីម និងចិនរងការធ្វើទុក្ខបុកម្នេញដោយសារតែអត្តសញ្ញាណនេះ។[១១] ក្នុងរយៈពេលដ៏ខ្លីមួយ ប្រជាជនកម្ពុជាទូទាំងប្រទេស ដែលប៉ាន់ស្មានទៅប្រហែល៧ ទៅ ៨លាននាក់ក្នុងពេលនោះ[១២] ត្រូវបានចាប់ជាចំណាប់ខ្មាំងនៅលើទឹកដីខ្លួនឯង និងបានធ្វើឲ្យជីវិតរស់នៅរបស់ពួកគេមានការផ្លាស់ប្តូរជាបន្តបន្ទាប់។

ខណៈពេលដែលរបបខ្មែរក្រហមមានផែនការផ្លាស់ប្តូរប្រទេសនេះឲ្យទៅជាប្រទេសកុម្មុយនីស្តដែលពឹងផ្អែកលើវិស័យកសិកម្ម ការប្រើប្រាស់រូបិយវត្ថុ ម្ចាស់អចលនទ្រព្យឯកជន និងការប្រកបរបរ

[៨] ចំពោះកិច្ចពិភាក្សាលម្អិតអំពីកត្តា និងស្ថានភាពនានាដែលរួមចំណែកនៅក្នុងព្រឹត្តិការណ៍ទាំងនេះ សូមមើល David Chandler, *The Tragedy of Cambodian History: Politics, Ware and Revolution Since 1945* (Chiang Mai: Silkworm Books, ១៩៩៤)។

[៩] David Chandler, *A History of Cambodia*, 4th ed. (Chiang Mai: Silkworm Books, ២០០៨) ២៥៦ - ២៥៧។

[១០] *សូមមើលជាទូទៅ* Ben Kiernan, *The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge, 1975-79* (New Haven: Yale University Press, ១៩៩៦) Elizabeth Becker, *When the War Was Over: Cambodia and the Khmer Rouge Revolution* (New York: Public Affairs, ១៩៩៨) និង Chandler, *History of Cambodia*។

[១១] សម្រាប់ព័ត៌មានបន្ថែមស្តីពីគោលនយោបាយខ្មែរក្រហមចំពោះក្រុមជនជាតិ *សូមមើល* Kiernan, *Pol Pot Regime,* ២៥១ - ៣០៩។ *សូមមើល* Becker, *When the War Was Over* ២២៨ ២៣៣ ២៤២ - ២៤៣ ២៤៥ *ផងដែរ*។

[១២] Kiernan, *Pol Pot Regime* ៤៥៦ - ៤៥៧។ Kiernan ប៉ាន់ស្មានចំនួនប្រជាជនមុនរបបខ្មែរក្រហមនៅឆ្នាំ១៩៧៥ ប្រហែល៧.៨៩ លាននាក់ ដោយលើកឡើងពី "ការគណនាចំនួនប្រជាជនមុនសង្គ្រាមនៃប្រជាសាស្ត្រនៃកម្ពុជា។" ប្រភពផ្សេងៗបានកំណត់ចំនួននេះក្នុងលក្ខណៈដូចគ្នា។ ប្រភពទាំងនេះត្រូវបានចងក្រងជាឯកសារនៅជួរ៦៤៧-៦៥៨ នៃតារាងដែលត្រូវបានបង្កើតឡើងដោយ R.J. Rummel បានចូលមើលនៅ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១ http://www.hawaii.edu/powerkills/SOD.TAB4.1B.GIF។

ចិញ្ចឹមជីវិតសម្រាប់គ្រួសារដោយឯករាជ្យ ត្រូវបានចាត់ទុកថាជារឿងមិនស្របច្បាប់ទាំងអស់។[១៣] ក្នុងអំឡុងពេលនោះ ប្រជាជនទូទាំងប្រទេសត្រូវបង្ខំឲ្យធ្វើស្រែចម្ការ កសាងហេដ្ឋារចនាសម្ព័ន្ធ និងបម្រើផលប្រយោជន៍ឲ្យអង្គការដែលជាពាក្យសម្រាលមិនប្រាកដប្រជា និងប្រកបដោយសព្វានុភាពសម្រាប់មេដឹកនាំរបបនេះ គណបក្ស និងគម្រោងរបស់ពួកគេ។[១៤] បន្តិចម្តងៗប្រជាជនទាំងមូលត្រូវបានចាត់ជាក្រុមនៅក្នុងសហករណ៍ ដែលក្នុងនោះការហូបចុក ការដេក ការធ្វើការ និងការរស់នៅប្រចាំថ្ងៃគ្រប់រូបភាពត្រូវបានដាក់កម្រិតយ៉ាងខ្លាំងនៅក្នុងសហគមន៍។ ចំនួនប្រជាជនស៊ីវិលភាគច្រើននៅក្នុងប្រទេសនេះ ត្រូវបានបង្ខំឲ្យធ្វើពលកម្មលើសកម្លាំង ត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទីលំនៅឬជម្លៀស ហើយជារឿយៗរស់នៅដោយគ្មានអាហារ គ្មានការព្យាបាល ឬគ្មានការសម្រាកគ្រប់គ្រាន់ដែលជាហេតុនាំឲ្យមានជំងឺរីករាលដាល កង្វះអាហារូបត្ថម្ភ និងមរណភាព។[១៥] លើសពីនេះទៅទៀត ទណ្ឌកម្មដ៏ឃោរឃៅ រួមមាន ការវាយដំ ការដាក់គុក ការធ្វើទារុណកម្ម ការកាប់សម្លាប់ និងការកាត់អវៈយវៈត្រូវបានប្រព្រឹត្តយ៉ាងសាហាវព្រៃផ្សៃ ដើម្បីគ្រប់គ្រងលើប្រជាជន និងស្វែងរកអ្នកដែលខ្លួនសង្ស័យថាជាសត្រូវបដិវត្ត។[១៦] ជារឿយៗ អ្នកជិតខាង កុមារ និងសមាជិកគ្រួសារនានាត្រូវបានលើកទឹកចិត្ត ហើយតែងតែត្រូវបានបង្ខំឲ្យរាយការណ៍អំពី "សមាសភាពមិនល្អ" ឬបណ្តាញវិទ្ធង្សនាដែលត្រូវបានអះអាងនៅក្នុងគ្រួសារ ក្រុមការងារ និងសហគមន៍របស់ពួកគេ។ បុគ្គលនិងគ្រួសារនីមួយៗរងផលប៉ះពាល់ធ្ងន់ធ្ងរដូចគ្នាដោយសារគោលនយោបាយដាច់ខាតនៃរបបនេះ។ ទំនាក់ទំនងសាសនា ទម្លាប់អនុវត្ត តាមវប្បធម៌ និងទំនាក់ទំនងគ្រួសារតាមប្រពៃណីត្រូវបានចាត់ទុកថាជាជនសង្ស័យ និងអាចឈានទៅដល់ការសម្លាប់ចោល។[១៧]

## ៤.២ ស្ត្រី និងគ្រួសារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ក្រោមការត្រួតត្រារបស់ខ្មែរក្រហម គ្រប់រូបភាពនៃជីវិតរស់នៅតាមគ្រួសារត្រូវបានដាក់កម្រិត

---

[១៣] Chandler, *History of Cambodia* ២៥៥ និង Chandler, *Tragedy of Cambodian History* ១។

[១៤] ការបកស្រាយលម្អិតអំពីការងាររបស់ អ៊ិត សារិន នៅក្នុងសៀវភៅនេះ *វិប្បដិសារីសម្រាប់ព្រលឹងខ្មែរ* Elizabeth Becker សរសេរថា "បុគ្គលម្នាក់ៗ ... ត្រូវដាក់ជូនទាំងស្រុងនូវការត្រួតត្រារបស់អង្គការ។ ហើយអង្គការទទួលបានការកោតសរសើរ ដោយមានអំណាចគ្រប់គ្រងស្ទើរតែអាថ៌កំបាំង ពាក្យនេះគឺជាច្បាប់ ហើយអ្នកប៉ុនប៉ងបំពានច្បាប់តែងតែត្រូវបានរកឃើញជានិច្ច។" Becker, *When the War Was Over* ១៩១។ Chandler បានចាត់ទុកអង្គការលើ ថាជា "អង្គការមិនជិតស្និទ្ធ អាថ៌កំបាំង ផ្តាច់ការ និងមិនអាចសួរសំណួរបាន ដូចដែលមហាក្សត្រកម្ពុជាអង្គណាមួយស្ថិតនៅក្នុងសម័យមុនអាណានិគម"។ Chandler, *Tragedy of Cambodian History* ២៩៦។

[១៥] *សូមមើល* Becker, *When the War Was Over* ១៩៨ - ១៩៩ Chandler, *Tragedy of Cambodian History* ២៩៦ - ២៩៧ ២៦០ និង *Chandler History of Cambodia* ២៥៥ ២៥៩ - ២៦០។

[១៦] ឧទាហរណ៍ ទណ្ឌកម្មដ៏ឃោរឃៅនេះត្រូវបានដឹងថា បានកើតឡើងនៅក្នុងគុកទួលស្លែង ក្នុងរាជធានីភ្នំពេញ។ *សូមមើល* Becker, *When the War Was Over* ២២៤ ២៦២ ២៨៥-២៨៧។

[១៧] នៅពេលលុបបំបាត់ចោលសាសនា ក្រោមរបបខ្មែរក្រហម និងការប្រព្រឹត្តចំពោះព្រះសង្ឃក្នុងអំឡុងសម័យនេះ *សូមមើល* Ian Harris, *Buddhism Under Pol Pot,* (Phnom Penh: DC-Cam, ២០០៧) ១០៥-១៣៨។ ដើម្បីពិភាក្សាអំពីផលប៉ះពាល់ទៅលើជីវិតគ្រួសារ និងទម្លាប់អនុវត្តតាមវប្បធម៌ *សូមមើល* Kalyanee Mam, "The Endurance of the Cambodian Family Under the Khmer Rouge: An Oral History" នៅក្នុង Susan E. Cook អ្នកកែសម្រួល *Genocide in Cambodia and Rwanda: New Perspectives* (New Brunswick, NJ: Transaction Publishers, ២០០៦)។ *សូមមើល* Becker, *When the War Was Over* ១៥៣ ("សាសនាត្រូវបានកៀបសង្កត់ក្នុងនាមអភិវក្សៗរាល់ការរៀបចំពិធីសាសនានិងសង្គមទាំងអស់ត្រូវបានហាមឃាត់ហើយព្រះពុទ្ធសាសនាត្រូវបានប្រមាថថា វិវត្តន៍ថយក្រោយ និងមានលក្ខណៈសក្តិភូមិ។ អាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងដោយខុសច្បាប់")*ផងដែរ*។

យ៉ាងខ្លាំង។ ជារឿយៗ ប្ដី ប្រពន្ធ ឪពុកម្ដាយ និងកូនត្រូវបានបំបែកឲ្យធ្វើការក្នុងក្រុមផ្សេងគ្នា ឬថែមទាំងត្រូវបានបញ្ជូនទៅតំបន់ភូមិសាស្ត្រផ្សេងគ្នាទៀតផង។[១៨] ជារឿយៗបន្ទាប់ពីកើតមកភ្លាម ទារកដែលទើបនឹងកើតនោះត្រូវបានប្រគល់ឲ្យអ្នកផ្សេងចិញ្ចឹម និងមើលថែ រីឯម្ដាយទារកនោះត្រូវវិលត្រឡប់ទៅធ្វើការជាមួយក្រុមវិញនៅពេលថ្ងៃ។[១៩] គេបានបង្រៀនកុមារថា ត្រូវគោរពស្រលាញ់ និងស្មោះត្រង់ជាមួយអង្គការជំនួសគ្រួសាររបស់ពួកគេ។[២០] មនុស្សក្នុងសម័យខ្មែរក្រហមតែងតែបរិភោគអាហារដោយឡែកពីគ្រួសារក្នុងសហគមន៍។ ជាទូទៅការសួរសុខទុក្ខសមាជិកគ្រួសារមិនត្រូវបានផ្ដល់ញឹកញាប់នោះទេ និងទាល់តែមានការអនុញ្ញាតពីអ្នកដឹកនាំមូលដ្ឋាន។[២១] ទោះបីជាមានការផ្លាស់ប្ដូរមួយចំនួនដ៏គួរឲ្យកត់សម្គាល់នៅក្នុងទម្លាប់អនុវត្តផ្អែកលើឋានៈរបស់បុគ្គលម្នាក់ៗនៅក្នុងរបបនោះ និងជួនកាលតំបន់ភូមិសាស្ត្រ និងជីវិតគ្រួសារដូចដែលប្រជាជនកម្ពុជាភាគច្រើនបានដឹងក៏ដោយ ក៏វាមានការផ្លាស់ប្ដូរយ៉ាងច្រើនក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។

## ៤.៣ ទស្សនាទានស្ដីពីអំពើហិង្សាលើយេនឌ័រនៅក្នុងស្ថានភាពមានជម្លោះ និងក្រោយជម្លោះ

ជាចំណុចចាប់ផ្ដើម ការសិក្សានេះសំដៅទៅរកអំពើហិង្សាលើយេនឌ័រ "ជាល័ក្ខខ័ណ្ឌរួមមួយស្ដីពីព្យសនកម្ម ដែលត្រូវបានបង្កមកលើឆន្ទៈរបស់បុគ្គលម្នាក់ៗ ពោលគឺលទ្ធផលនៃអតុល្យភាពអំណាចដែលឆ្លៀតយកប្រយោជន៍លើភាពខុសគ្នារវាងបុរស និងស្ត្រី"។[២២] ការសិក្សានេះផ្ដោតសំខាន់ទៅលើទិដ្ឋភាពផ្លូវភេទនៃអំពើហិង្សាលើយេនឌ័រ ដែលត្រូវបានទទួលស្គាល់ភាគច្រើន ថាជាការរាលដាលមួយនៅក្នុងតំបន់ដែលរងគ្រោះដោយជម្លោះ និងក្នុងពេលមានសង្គ្រាម។[២៣] វិធីសាស្ត្រដែលប្រើនៅទីនេះក៏ទទួលស្គាល់ថា "បុរស និងកុមារក៏អាចជាជនរងគ្រោះ ដោយសារអំពើហិង្សាលើយេនឌ័រនេះដែររួមមានអំពើហិង្សាផ្លូវភេទ។"[២៤] ដូច្នេះការសិក្សាស្រាវជ្រាវនេះបានស្វែងរកព័ត៌មាន

[១៨] *សូមមើលជាទូទៅ* Kalyanee Mam, "Democratic Kampuchea (1975 – 1979): Women as Tools for Social Change" (និក្ខេបបទ របស់និស្សិត Yale University ២០០០)។
[១៩] ដូចមានក្នុងសៀវភៅខាងលើទំព័រទី ១០-១៩។
[២០] Becker, *When the War Was Over* ២២៩។
[២១] ដូចមានក្នុងសៀវភៅខាងលើ និង Chandler, *History of Cambodia* ២៥៨។
[២២] "Gender-Based Violence," Reproductive Health Responses in Crisis Consortium បានចូលមើលថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១១ http://www.rhrc.org/rhr_basics/gbv.html។ *សូមមើល* Jeanne Ward, "If not now, when?: Addressing GBV in Refugee, Internally Displaced and Post-Conflict Settings, A Global Overview" (New York: RHRC, ២០០២) ៨-៩; និង Sally Engle Merry, Gender Violence: A Cultural Perspective (Malden: Blackwell, ២០០៩) ១៥ *ផងដែរ*។
[២៣] Jeanne Ward និង Mendy Marsh, "Sexual Violence Against Women and Girls in War and Its Aftermath: Realities, Responses and Required Resources" (ឯកសារសង្ខេបអំពីសន្និសីទនៃអ្នកជំនាញខាងអ្វីមួយស្ដីពីអំពើហិង្សាលើផ្លូវភេទក្នុងពេលមានជម្លោះ និងក្រោយជម្លោះ Brussels ប្រទេសប៊ែលហ្ស៊ិក ថ្ងៃទី២១-២៣ មិថុនា ២០០៦) ៣ និង Ward, "If Not Now" ៧។
[២៤] "GBV: Overview," Reproductive Health Responses in Crisis Consortium បានចូលមើលថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១១ http://www.rhrc.org/rhr_basics/gbv.html (មាតិកាដែលត្រូវបានកែសម្រួលពី Reproductive Health Responses in Crisis Consortium, Reproductive Health in Humanitarian Settings: An Inter-Agency Field Manual, Inter-agency Working Group on Reproductive Health in Crisis (New York: RHRC ២០១០))។

ស្តីពីអំពើហិង្សាលើយេនឌ័រ ដែលត្រូវបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនគិតពីភេទរបស់ជនរងគ្រោះឡើយ។[២៥]

ហេតុការណ៍ និងព្រឹត្តិការណ៍ដែលជាប្រធានបទនៃការសិក្សានេះបានកើតឡើងជាយូរមកហើយមុនពេលចាប់ផ្តើមមានពាក្យ អំពើហិង្សាលើយេនឌ័រ ឬការសិក្សាអំពីរបៀបដែលអំពើហិង្សាបែបនេះអាចពាក់ព័ន្ធនឹងសង្គ្រាម និងស្ថានភាពរងគ្រោះដោយជម្លោះ។ ដោយសង្កត់ធ្ងន់ទៅលើបទដ្ឋានយេនឌ័រសំខាន់ៗ និងអតុល្យភាពអំណាច រវាងបុរស និងស្ត្រី[២៦] បច្ចុប្បន្នអ្នកជំនាញនិងអ្នកគាំទ្រទទួលស្គាល់ថា អំពើហិង្សាលើយេនឌ័រអាចស្តែងចេញនូវលក្ខណៈផ្សេងៗ ក្នុងស្ថានភាពមានជម្លោះ៖

> កត្តាជំរុញឲ្យមានអំពើហិង្សាលើយេនឌ័រ ជាពិសេសឧក្រិដ្ឋកម្មផ្លូវភេទ ដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធមានលក្ខណៈខុសគ្នា។ អំពើហិង្សាផ្លូវភេទអាចមកពីចិត្តភ្លើតភ្លើន ឬធ្វើឡើងទៅតាមសាច់រឿង "ការបំផ្លាញដោយសង្គ្រាម" ដែលបណ្តាលមកពីប្រព័ន្ធសង្គម និងសីលធម៌មិនដំណើរការ។ ជាការពិតណាស់ វាទំនងថា ប្រភេទនៃអំពើហិង្សាលើយេនឌ័រ "ដោយមានវត្ថុធានា" គឺជាធាតុផ្សំនៃសង្គ្រាម។ លើសពីនេះទៅទៀត អំពើហិង្សាផ្លូវភេទអាចមានជាលក្ខណៈប្រព័ន្ធ ក្នុងគោលបំណងធ្វើឲ្យអស្ថិរភាពដល់ប្រជាជន និងបំផ្លាញចំនងទាក់ទងនៅក្នុងសហគមន៍ និង គ្រួសារនានា ជំរុញការបោសសម្អាតជនជាតិភាគតិចសម្តែងនូវការស្អប់ខ្ពើមចំពោះសត្រូវ ឬផ្គត់ផ្គង់ពួកយុទ្ធជននូវសេវាផ្លូវភេទ។[២៧]

អ្នកជំនាញក៏បានកត់សម្គាល់ថា ការសម្លាប់ស្ត្រីនៅក្នុងជម្លោះប្រដាប់អាវុធគឺជារឿងយេនឌ័រ "ដែលជារឿយៗមធ្យោបាយ និងវិធីសម្លាប់អាចបណ្តាលមកពីបញ្ហាផ្លូវភេទ ដូចជាតាមរយៈការកាត់ឬបំផ្ទុះប្រដាប់ភេទ ឬផ្នែកនៃរាងកាយការចាប់ទាញគត់ចេញពីស្បូន ឬការរំលោភសេពសន្ថវៈ ដោយប្រើអំបែងកែវ ឬអាវុធគ្រោតគ្រាត"។[២៨] ទោះបីជាមានទំនាក់ទំនងជិតស្និទ្ធទៅនឹងអំពើហិង្សាលើយេនឌ័រក្នុងសម័យសន្តិភាព ដែលត្រូវបានប្រព្រឹត្តនៅក្នុងស្ថានភាពមានជម្លោះដែលកាន់តែរាល

[២៥] ទោះបីជាអំពើហិង្សាលើយេនឌ័រភាគច្រើនត្រូវបានរាយការណ៍នៅក្នុងការសិក្សានេះថា បានប្រព្រឹត្តមកលើស្ត្រី និងកុមារីក៏ដោយ ក៏ករណីជាច្រើននៃអំពើហិង្សាមកលើកុមារាក៏ត្រូវបានលាតត្រដាង និងលើកមកពិភាក្សាផងដែរនៅក្នុងផ្នែកនៃលទ្ធផលរកឃើញនៅក្នុងរបាយការណ៍នេះ។

[២៦] ចំពោះកិច្ចពិភាក្សាលម្អិតអំពីរបៀបដែលតួនាទី និងអតុល្យភាពទាំងនេះបានបង្ហាញតាមរយៈអំពើហិង្សាលើយេនឌ័រនៅក្នុងជម្លោះប្រដាប់អាវុធ សូមមើល Margaret Urban Walker, "Gender and Violence in Focus: A Background for Gender Justice in Reparations" នៅក្នុង The Gender of Reparations: Unsettling Sexual Hierarchies while Redressing Human Rights Violations Ruth Rubio-Marin អ្នកកែសំរួល (Cambridge: Cambridge University Press, ២០០៩) ១៨-៦២។

[២៧] Ward, "If Not Now" ៧។ ចំពោះការចាត់ថ្នាក់ និងការបរិយាយអំពីអំពើហិង្សាលើយេនឌ័រ ក្នុងពេលមានជម្លោះសូមមើល Walker, "Gender and Violence។"

[២៨] Kelly Askin, "Prosecuting Wartime Rape and Other Gender-Related Crimes under International Law: Extraordinary Advances, Enduring Obstacles," *Berkeley Journal of International Law* ២១ (២០០៣): ២៩៨។

ដាល យោរយៅ និងជាសាធារណៈស្របគ្នានឹងភាពងាយរងគ្រោះកើនឡើងរបស់ស្រ្តី និងកុមារី ការបំផ្លាញរចនាសម្ព័ន្ធសង្គម ដែលស្ថិតក្នុងស្ថានភាពគ្មានជម្លោះ បានកំណត់ទៅលើទម្លាប់អនុវត្តអំពើហិង្សាលើយេនឌ័រ ហើយជនដៃដល់អាចមានអារម្មណ៍ប្រើប្រាស់ទម្រង់នៃអំពើហិង្សាដែលនាំឲ្យមានរបួសស្នាម ឬទណ្ឌកម្ម លើសត្រូវ។[២៩]

ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអនុម័តលើសេចក្តីសម្រេចសំខាន់ៗលើប្រធានបទនៃអំពើហឹង្សាលើយេនឌ័រ។ ទី១ សេចក្តីសម្រេចលេខ ១៣២៥ ដែលសង្កត់ធ្ងន់ទៅលើការតម្រូវឲ្យស្រ្តីចូលរួមក្នុងគ្រប់ដំណាក់កាលនៃដំណើរការសន្តិភាព និងបញ្ចប់និទណ្ឌភាពចំពោះអំពើហិង្សាលើយេនឌ័រនៅក្នុងជម្លោះប្រដាប់អាវុធនិង "អំពាវនាវឲ្យភាគីមានជម្លោះប្រដាប់អាវុធទាំងអស់គោរពគ្នា ចាត់វិធានការពិសេសដើម្បីការពារស្រ្តី និងកុមារីឲ្យរួចផុតពីអំពើហិង្សាលើយេនឌ័រ ជាពិសេសការរំលោភសេពសន្ថវៈ និងទម្រង់នៃការរំលោភបំពានផ្លូវភេទផ្សេងៗទៀត"។[៣០] ហើយក្នុងរយៈពេលជិតមួយទសវត្សរ៍



ក្រោយមកសេចក្តីសម្រេចលេខ ១៨២០ ដែលប្រើពាក្យសម្តីខ្លាំងៗ អំពាវនាវឲ្យបង្កើនវិធានការដើម្បីទប់ស្កាត់អំពើហិង្សាផ្លូវភេទដោយអះអាងថា អំពើហិង្សាផ្លូវភេទបានគំរាមកំហែងដល់សន្តិភាព និងសន្តិសុខអន្តរជាតិ និង សង្កត់ធ្ងន់អំពីសារៈសំខាន់នៃការបញ្ចប់និទណ្ឌភាពចំពោះទង្វើបែបនេះ ជាផ្នែកមួយនៃវិធីសាស្រ្តគ្រប់ជ្រុងជ្រោយ ក្នុងការស្វែងរកសន្តិភាព យុត្តិធម៌ សច្ចធម៌ និងការបង្រួបបង្រួមជាតិប្រកបដោយចីរភាព"។[៣១]

លើសពីនេះទៅទៀត ប្រធានបទស្តីពីអំពើហិង្សាលើយេនឌ័រក្នុងពេលមានសង្គ្រាម និងជម្លោះប្រដាប់អាវុធទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងច្បាប់អន្តរជាតិ។សាលាក្តីឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិ រួមមាន **ICTY, ICTR** និង **SCSL** បានផ្តន្ទាទោសចំពោះ អំពើហិង្សាលើយេនឌ័រជាឧក្រិដ្ឋកិច្ចផ្សេងៗ ក្រោមច្បាប់អន្តរជាតិរួមមាន អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម ប្រឆាំងនឹង

[២៩] *សូមមើល* Kristen Hagan, "The Nature and Psychosocial Consequences of War Rape for Individuals and Communities," *International Journal of Psychological Studies* ២ (២០១០): ២ (ការអះអាងថា "ទោះបីជាការចាប់រំលោភនេះនាំឲ្យមានវិបត្តិផ្លូវចិត្ត ទោះជាវាកើតឡើងនៅពេលណាក្តី ឬក្នុង អំឡុង ពេលមានសង្គ្រាមក្តី ក៏ការរំលោភសេពសន្ថវៈ នេះទំនងជាមានទំហំ ប្រេកង់ស៍ និងគោលបំណងកាន់តែធំផង")។ ចំពោះកិច្ចពិភាក្សាបន្ថែម អំពីភាពខុសគ្នារវាង អំពើហិង្សាលើយេនឌ័រក្នុងពេលមានសន្តិភាព និងក្នុងពេលមានសង្គ្រាម សូមមើល Walker, "Gender and Violence" ២៨-៣២។
[៣០] United Nations Security Council, Resolution 1325 ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០០០ S/RES/1325 (2000)។
[៣១] United Nations Security Council, Resolution 1820 ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០០៨ S/RES/1820 (2008)។

មនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ។[៣២] ការលើកឡើងពីយុទ្ធសាស្ត្រ និងការអនុវត្តដែលត្រូវបានបង្កើតឡើងនៅក្នុងតុលាការទាំងនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិ **(ICC)** ត្រូវបានផ្តល់អំណាចជាមួយនឹងលក្ខន្តិក: "ជឿនលឿន និង សំខាន់ដែលពិចារណាអំពីវិសាលភាពដ៏ធំធេងនៃឧក្រិដ្ឋកម្មលើយេនឌ័រ[៣៣] ប៉ុន្តែគេនៅតែយល់ឃើញថា តើតុលាការនឹងប្រើប្រាស់អំណាចទាំងនេះមានប្រសិទ្ធភាពយ៉ាងណាខ្លះ។[៣៤] ភាពរីកចម្រើនក្នុងការកាត់ទោសចំពោះឧក្រិដ្ឋកម្មលើយេនឌ័រនៅចំពោះមុខតុលាការដែលបានអនុវត្តបានឆ្លុះបញ្ចាំងរួចជាស្រេចអំពីវិធីសាស្ត្រជាប្រព័ន្ធ និងលម្អិតក្នុងការដោះស្រាយអំពើហិង្សាលើយេនឌ័រនៅក្នុងជម្លោះប្រដាប់អាវុធ និងការលើកកំពស់ការប្តេជ្ញាចិត្តជាអន្តរជាតិចំពោះគណនេយ្យភាពសម្រាប់អ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។

បន្ថែមពីលើការលៃលកដោះស្រាយស្ថានភាពក្រោយមានអំពើហិង្សាលើយេនឌ័រនៅក្នុងស្ថានភាពមានជម្លោះ ខណៈពេលដែលភស្តុតាងបង្ហាញថា អត្រាអំពើហិង្សាលើយេនឌ័របានកើនឡើងជាក់ស្តែងនៅក្នុងស្ថានភាពក្រោយជម្លោះ[៣៥] ផលវិបាករយៈពេលវែងនៃអំពើហិង្សាលើយេនឌ័រក្នុងពេលមានសង្គ្រាមនៅក្នុងសង្គម បានកើតឡើងជាក្តីកង្វល់ដ៏ធំមួយ។ លើសពីនេះទៅទៀត មុនពេលមានច្បាប់អន្តរជាតិស្តីពីអំពើហិង្សាលើយេនឌ័រ និងដំណើរការគណនេយ្យភាពផ្លូវការចំពោះឧក្រិដ្ឋកម្មលើយេនឌ័រដែលទទួលបានការយកចិត្តទុកដាក់ ត្រូវបានសំដៅចំពោះការផ្តល់សំណងជំងឺចិត្តដល់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។ សំខាន់ជាងនេះ ជនរងគ្រោះ និងអ្នកគាំទ្របានគូសបញ្ជាក់អំពីតម្រូវការក្នុងការទទួលស្គាល់នូវការធានាថា នឹងមិនកើតឡើងសាជាថ្មីតាមរយៈសំណងជម្ងឺចិត្ត ដើម្បីស្វះស្វែងផ្លាស់ប្តូរបទដ្ឋាន និងទម្លាប់វប្បធម៌ដែលធ្វើឲ្យអំពើហិង្សាលើយេនឌ័រមានលក្ខណៈទូទៅ ទោះបីក្នុងពេលមានសន្តិភាព ឬជម្លោះក្តី។ ក្នុងវិធីបែបនេះ ការធ្វើប្រព្រឹត្តកម្មអំពើហិង្សាលើយេនឌ័រនៅក្នុងដំណើរការយុត្តិធម៌អន្តរកាល បច្ចុប្បន្នត្រូវបានចាត់ទុកថា ជាកិច្ចប្រឹងប្រែងដែលពិនិត្យទៅក្រោយ និងទៅមុខ ។ ដូចដែលអ្នកចូលរួមម្នាក់បានលើកឡើងនៅក្នុងសន្និសីទអង្គការសហប្រជាជាតិថ្មីៗស្តីពីសំណងជំងឺចិត្តចំពោះអំពើហិង្សាលើយេនឌ័រៈ

[៣២] សម្រាប់ទិដ្ឋភាពទូទៅអំពីរបៀបដែលតុលាការទាំងនេះបានធ្វើប្រព្រឹត្តកម្មលើអំពើហិង្សាលើយេនឌ័រ *សូមមើល* Rashida Manjoo និង Calleigh McRaith, "Gender-Based Violence and Justice in Conflict and Post-Conflict Areas," *Cornell International Law Journal* ៤៤ (២០១០) ១១-៣១។

[៣៣] Laurie Green, "First-Class Crimes, Second-Class Justice: Cumulative Charges for Gender-Based Crimes at the International Criminal Court," *International Criminal Law Review* ១១ (២០១០): ៥៣០។

[៣៤] *សូមមើលដូចមានក្នុងសៀវភៅខាងលើ*(ការរិះគន់សេចក្តីសម្រេច ដូចជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមិនចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មលើយេនឌ័រ Prosecutor v. Jean-Pierre Bemba Gombo)។

[៣៥] *សូមមើល* Colleen Duggan និង Adila Abusharaf, "Reparations of Sexual Violence and Democratic Transition: In Search of Gender Justice" នៅក្នុង *The Handbook of Reparations* Pablo de Greiff អ្នកកែសំរួល (New York: Oxford University Press, ២០០៦) ៦២៣-៦៤៩។

ក្រោយពីអំពីហោរឃោដ៏ធំធេងនេះ រដ្ឋមានឱកាសពិនិត្យឡើងវិញ និងកែទម្រង់ប្រព័ន្ធ និង គោលនយោបាយនានា ដែលបណ្ដាលឲ្យមានការរើសអើង និងភាពងាយរងគ្រោះនៃក្រុមមួយចំនួន។ កម្មវិធីផ្ដល់សំណងជំងឺចិត្តដែលស្វះស្វែងដោះស្រាយទាំងបុព្វហេតុ និងផលវិបាកនៃការរំលោភបំពានក្នុងសម័យសង្គ្រាម និងអនុវត្តគោលការណ៍នៃសមភាពយេនឌ័រ ការមិនរើសអើង និងការចូលរួមរបស់ជនរងគ្រោះ និងការផ្ដល់អំណាចដែលអាចសម្រេចបានគោលដៅទាំងនេះនិងមានផលប៉ះពាល់ដែលធ្វើអោយមានការប្រែប្រួលទៅលើជនរងគ្រោះ សហគមន៍ និងប្រទេសនានា។[៣៦]

## ៤.៤ អំពើហិង្សាលើយេនឌ័រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

### ៤.៤.១ យេនឌ័រនៅកម្ពុជាមុនសម័យខ្មែរក្រហម

វប្បធម៌កម្ពុជានៅសម័យទំនើប ជាពិសេសក្នុងសម័យដឹកនាំដោយខ្មែរក្រហម បានដាក់ការរឹតបន្តឹងយ៉ាងខ្លាំងទៅលើស្ត្រី។[៣៧] នៅសម័យនោះ ទិដ្ឋភាពវប្បធម៌នៃតួនាទីរបស់ស្ត្រី និងទីកន្លែង និងអាកប្បកិរិយាដ៏សមស្របរបស់ស្ត្រីនៅក្នុងសង្គមត្រូវបានស្ដែងឲ្យឃើញនៅក្នុងសញ្ញាសម្គាល់ផ្នែកវប្បធម៌ ដូចជា ច្បាប់ស្រី[៣៨] និងសុភាសិតខ្មែរដ៏ល្បីមួយនៅតែប្រើមកទល់ពេលសព្វថ្ងៃ ដែលនិយាយថា "បុរសដូចជាមាស ឯស្ត្រីដូចជាក្រណាត់ពណ៌ស"។[៣៩] ដូចដែលបានលើកឡើងនៅក្នុងសុភាសិតនេះអញ្ចឹង "ស្ត្រីកាលណា "ខូច" គឺលែងមានន័យអ្វីទៀតហើយ ចំណែកឯបុរសវិញមិនថ្វីទេ ទោះបីជាខូចខិលយ៉ាងណាក៏ដោយ"។[៤០] នៅក្នុងទសវត្សរ៍ ឆ្នាំ១៩៦០ និង១៩៧០ ស្ត្រីកម្ពុជា

---

[៣៦] UN Women and UN Development Program, *Reparations, Development and Gender: Report of the Kampala Workshop, 1-2 December 2010* ៦ (ការដកស្រង់សម្ដីរបស់អ្នកចូលរួមសន្និសីទ Ruben Carranza អ្នកជំនាញដោះស្រាយសំណងមកពីមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល)។

[៣៧] គួរកត់សម្គាល់ផងដែរថាអ្នកសិក្សាស្រាវជ្រាវបានលើកហេតុផលថា តួនាទីរបស់ស្ត្រីនៅក្នុងសង្គមកម្ពុជាបាន ផ្លាស់ប្ដូរពីពេលមួយទៅពេលមួយ និងមិនត្រូវបានផ្លាស់ប្ដូរគ្រប់ពេលនោះទេ ពីព្រោះវាស្ថិតនៅក្នុងប្រវត្តិសាស្ត្របច្ចុប្បន្ន។ *សូមមើល ឧ.* Trudy Jacobsen, *Lost Goddesses: The Denial of Female Power in Cambodian History* (Copenhagen: NIAS Press, ២០០៨) (ការពិភាក្សាអំពីឋានៈខ្ពស់របស់ស្ត្រីនៅក្នុងសង្គមកម្ពុជា និងការធ្លាក់ចុះថ្មីៗ នៃឋានៈ និងអំណាចរបស់ស្ត្រី ចាប់តាំងពីពេលនោះមក)។

[៣៨] ច្បាប់ស្រី គឺជាកំណាព្យខ្មែរដ៏ល្បីមួយ ដែលត្រូវបានព្រាងនៅក្នុងសតវត្សរ៍ទី១៩ ដែលបានផ្ដល់ការណែនាំដល់កុមារី និងស្ត្រីវ័យក្មេងអំពីរបៀបសំដែងអាកប្បកិរិយារបស់ខ្លួនស្របតាមក្ដីរំពឹងក្នុងសង្គមកម្ពុជាចំពោះអាកប្បកិរិយារបស់ស្ត្រី។ នៅក្នុងសម័យមុនខ្មែរក្រហម ឯកសារនេះត្រូវបានសិក្សានៅសាលារៀន និងជាគំរូផ្នែកវប្បធម៌ដែលបង្ហាញពីឥរិយាបថដ៏ប្រពៃរបស់ស្ត្រី។ *សូមមើល* Jacobsen, *Lost Goddesses* ១១៩-១២២។ ដូចដែល Nakagawa បានកត់សម្គាល់អញ្ចឹង ប្រភពនៃចំណេះដឹងផ្នែកវប្បធម៌ទាំងនេះនៅតែឥទ្ធិពលដ៏សំខាន់នៅក្នុងសង្គមកម្ពុជា។ *សូមមើល* Kasumi Nakagawa, *More Than White Cloth?—Women's Rights in Cambodia* (Phnom Penh: CDP, ២០០៦) ១៣។

[៣៩] សុភាសិតនេះបង្ហាញពីការដាក់សម្ពាធទៅលើគុណធម៌របស់ស្ត្រីនៅក្នុងសង្គមកម្ពុជា។មិនដូចគ្នានឹងបុរសទេ លក្ខណៈសម្គាល់ប្រឆាំងនឹងគុណធម៌របស់ស្ត្រីគំរាមកំហែងដល់តម្លៃ និងកេរ្តិ៍ឈ្មោះរបស់នាង ក៏ដូចគ្នាគ្រួសាររបស់នាងផងដែរ។ សម្រាប់ការពិភាក្សាបន្ថែមអំពីសង្គមស្ដីពីបញ្ហាផ្លូវភេទនៅក្នុងសង្គមកម្ពុជា សូមមើល Nakagawa, *More Than White Cloth* ២៧។

[៤០] ដូចមានក្នុងសៀវភៅខាងលើទីព័រទី១៣។ពាក្យថាក្រណាត់សនេះមានន័យថាស្ត្រីណាដែលបំពាននឹងប្រពៃណីនិងទំនៀមទម្លាប់សង្គមយេនឌ័រ ដែលវប្បធម៌កម្ពុជាបានកំណត់នោះ ត្រូវគេជាប់ឈ្មោះថាជាស្រីដែលមិនគោរពប្រពៃណី និងទំនៀមទម្លាប់ជារៀងរហូត ចំណែកឯបុរសវិញ ទោះបីប្រព្រឹត្តអំពើបែបនេះក៏ដោយ ក៏មិន"ខូចឈ្មោះ" ដោយសារទង្វើរបស់គេដែរ ហើយអាចរំពឹងថា នៅតែរក្សាឋានៈ និងកេរ្តិ៍ឈ្មោះក្នុងសង្គមបានដដែល។

មានសេរីភាព និងស្វ័យភាពតិចតួចនៅក្នុងវប្បធម៌ ការរៀបចំអាពាហ៍ពិពាហ៍គឺជាបទដ្ឋានមួយ ហើយគឺជាឱកាសក្នុងការទទួលបានការអប់រំដោយឯករាជ្យ និងសិទ្ធិស្វ័យសម្រេចរបស់ស្ត្រីនៅមានកម្រិតនៅឡើយ។ ការចែចង់ និងការមានទំនាក់ទំនងរវាងភេទទាំងពីរត្រូវបានគ្រប់គ្រងដោយសមាជិកគ្រួសារ ហើយព្រហ្មចារីរបស់ស្ត្រីត្រូវបានចាត់ទុកថា ជាសម្បត្តិដ៏មានតម្លៃ និងជាការវាស់វែងដ៏សំខាន់មួយនូវតម្លៃរបស់ស្ត្រីក្នុងនាមជាប្រពន្ធដ៏ប្រពៃ។[៩១] ការរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍ ទោះដោយព្រមព្រៀង ឬមិនព្រមព្រៀងក្តី នឹងធ្វើឲ្យកូនក្រមុំបាត់បង់ឱកាសរៀបអាពាហ៍ពិពាហ៍ និង ជីវិតគ្រួសារ។[៩២]

### ៤.៤.២ អំពើហិង្សាលើយេនឌ័រនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ

បើប្រៀបនឹងព័ត៌មានស្តីពីប្រធានបទផ្សេងៗទាក់ទងនឹងអំពើឃោរឃៅ ដែលពួកខ្មែរក្រហមបានប្រព្រឹត្ត គេបានធ្វើការសិក្សាស្រាវជ្រាវតិចតួចអំពីអំពើហិង្សាលើយេនឌ័រនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងការសិក្សាមួយ ក្នុងចំណោមការសិក្សាលើកដំបូងជាច្រើនទាក់ទងនឹងប្រធានបទនេះ លោក រីឆាត ម៉ូលីកា និងសហការីមកពីកម្មវិធី **Harvard** នៅក្នុងការប៉ះទង្គិចផ្លូវចិត្តរបស់ជនភៀសខ្លួនបានសម្ភាសជនភៀសខ្លួនកម្ពុជាជិត១០០០នាក់នៅក្នុងជំរំព្រំដែនថៃ ស្តីពីបញ្ហាសុខភាពផ្លូវចិត្តនៅក្នុងឆ្នាំ១៩៩០។ នៅពេលប្រើវិធីសាស្ត្រអង្កេតទូទៅការសិក្សានេះបានរកឃើញថាអ្នកឆ្លើយសំណួរ១៧%ត្រូវបានរំលោភសេពសន្ថវៈ ឬការបំពានផ្លូវភេទ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ[៩៣] ក្រៅពីនេះការសិក្សាមិនទំនងថា ប្រធានបទនេះទទួលបានការចាប់អារម្មណ៍ក្រៅពីឯកសារយោងនៅក្នុងដំណើររឿងជាប្រវត្តិសាស្ត្រនយោបាយ និងជីវប្រវត្តិ ដែលត្រូវបានផលិតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ រហូតដល់រយៈពេលប៉ុន្មានឆ្នាំក្រោយមក។ ខណៈពេលដែលការចរចាអំពីសាលាក្តីព្រហ្មទណ្ឌអន្តរជាតិកំពុងដំណើរការ អ្នកអង្កេតការម្នាក់បានសុំឲ្យមានការស្រាវ ជ្រាវច្រើនបន្ថែម...អំពីប្រធានបទស្តីពីអំពើហិង្សាមកលើស្ត្រីក្នុងអំឡុងសម័យខ្មែរក្រហម។″[៩៤]

[៩១] *សូមមើល* Rebecca Surtees, "Rape and Sexual Transgression in Cambodia" នៅក្នុង *Violence Against Women in Asian Societies: Gender Inequality and Technologies of Violence*, L. Bennett និង L. Manderson អ្នកកែសំរួល (New York: Routledge, ២០០៣) ១០៥-១០៦។

[៩២] សម្រាប់កិច្ចពិភាក្សាលម្អិតអំពីឋានៈ និងទំនាក់ទំនងយេនឌ័ររបស់ស្ត្រីនៅក្នុងសម័យក្រោយអាណានិគម និងមុនរបបកម្ពុជាប្រជាធិបតេយ្យ សូមមើល Jacobsen, *Lost Goddesses* ១៩៨-១៩០។

[៩៣] Richard F. Mollica. ល. "The Effect of Trauma and Confinement on Functional Health and Mental Health Status of Cambodians Living in Thailand-Cambodia Border Camps" *Journal of the American Medical Association* (១៩៩៣): ៥៨១-៥៨៦។

[៩៤] Laura McGrew, "Cambodian Women at Year Zero" *On the Record: Women of Southeast Asia Fight Violence* ៥ (១៩៩៩) បានចូលមើលថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១១ www.advocacynet.org/resource/530#Camodian_Women_at _Year_Zero។

បន្ទាប់ពីបានអំពាវនាវឲ្យចាត់វិធានការមក **Kalyanee Mam** ជានិស្សិតមិនទាន់បញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ យែល បានធ្វើបទសម្ភាសន៍ និងសារណាដោយវិភាគអំពីការប្រើប្រាស់យេនឌ័រ ជាឧបករណ៍សម្រាប់រៀបចំសង្គមកម្ពុជាជាថ្មីតាមរយៈគោលនយោបាយខ្មែរក្រហម។ ការសិក្សាផ្អែកលើការធ្វើបទសម្ភាសន៍នៅក្នុងខេត្តកណ្តាលកាលពីឆ្នាំ១៩៩៩ និងឆ្នាំ ២០០០ រួមមានព័ត៌មានលម្អិតពីការបង្ខំឲ្យរៀបការ ការរំលោភសេពសន្ថវៈ និងការបំពានផ្លូវភេទ ដែលស្ត្រីជាច្រើនបានទទួលរងក្នុងរបបខ្មែរក្រហម។[៩៥] បន្ទាប់ពីនេះ **Katrina Anderson** ជានិស្សិតច្បាប់នៅសហរដ្ឋអាមេរិកបានរៀបចំការសិក្សាស្រាវជ្រាវ ដើម្បីគាំទ្រនិងលើកឡើងពីមធ្យោបាយក្នុងការដោះស្រាយអំពើហិង្សាផ្លូវភេទ និងឧក្រិដ្ឋកម្មលើយេនឌ័ររបស់ខ្មែរក្រហមតាមរយៈដំណើរការនីតិវិធីផ្លូវច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងយន្តការយុត្តិធម៌អន្តរកាលផ្សេងទៀត។[៩៦]

ដោយកំណត់មកលើស្ថានភាពបែបនេះ ការសិក្សាដ៏មានមហិច្ឆិតា សំដៅចំពោះអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម ត្រូវបានធ្វើឡើងនៅឆ្នាំ២០០៦ដោយក្រុមអ្នកស្រាវជ្រាវនៅក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលត្រូវបានដឹកនាំដោយ **Kasumi Nakagawa**។ កម្រងសំណួរស្រាវជ្រាវលើកដំបូង ត្រូវបានបំពេញដោយអ្នកឆ្លើយសំណួរដែលត្រូវបានជ្រើសរើសមិនមែនព្រាវៗ ប្រហែល ១៥០០នាក់ នៅក្នុងខេត្តចំនួន៥ក្នុងចំណោមខេត្តនានានៅប្រទេសកម្ពុជា។ បន្ទាប់មកបទសម្ភាសន៍ស៊ីជម្រៅចំនួន៩៦ករណីបន្ថែមទៀត (បុរស២៨នាក់ និងស្ត្រី៦៨នាក់)បានពិនិត្យតាមដានទៅលើកម្រងសំណួរដែលទទួលបានជោគជ័យបំផុត។ គម្រោងនេះបានព្យាយាមសាកល្បងថា តើជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រគ្រប់រូបពិតជាត្រូវបានសម្លាប់មែនឬយ៉ាងណា និងថា តើវប្បធម៌កម្ពុជានឹងរារាំងជនរងគ្រោះមិនឲ្យចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនដែរឬយ៉ាងណា នៅពេលដែលគេបានពិចារណាជារួម។[៩៧] ការស្រាវជ្រាវនេះបានបង្ហាញរបាយការណ៍ ដែលលម្អិត អំពីរបកគំហើញអំពីអំពើហិង្សាលើយេនឌ័រនៅក្នុងតំបន់ដែលមានការបង្ខំឲ្យរៀបការ និងការរំលោភសេពសន្ថវៈ ការរំលោភសេពសន្ថវៈក្រៅចំណងអាពាហ៍ពិពាហ៍ និងទម្រង់នៃការរំលោភបំពានខាងផ្លូវភេទក្រោមរូបភាពផ្សេងទៀត រួមមាន ការបំពានខាងផ្លូវភេទ ការធ្វើឲ្យអាម៉ាស់ខាងផ្លូវភេទ ការកាត់អវៈយវៈភេទ

[៩៥] *សូមមើលជាទូទៅ* Mam, *Democratic Kampuchea*។ និក្ខេបបទនេះត្រូវបានកែសម្រួល និងបោះពុម្ពផ្សាយ៖ “The Endurance of the Cambodian Family Under the Khmer Rouge Regime: an Oral History” នៅក្នុង *Genocide in Cambodia and Rwanda: New Perspectives*, Susuan E. Cook អ្នកកែសំរួល (New Brunswick: Transaction Publishers, ២០០៦) ១១៩-១៦២។

[៩៦] Katrina Anderson, “Turning Reconciliation on Its Head: Responding to Sexual Violence Under the Khmer Rouge,” *Seattle Journal of Social Justice* ៣ (២០០៥): ៧៨៥-៨៣២។

[៩៧] Kasumi Nakagawa, *Gender-Based Violence During the Khmer Rouge Regime: Stories of Survivors from the Democratic Kampuchea (1975-1979)* (Phnom Penh: CDP, ២០០៨) ១៩។

និងការបង្ខំឲ្យដោះសំលៀកបំពាក់។[៤៨] របាយការណ៍មួយក្នុងចំណោមរបាយការណ៍ទាំងនេះក៏បានអំពាវនាវឲ្យមានកិច្ចប្រឹងប្រែងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម បានស្វែងរកលទ្ធភាព ដែលនាំមកនូវឧក្រិដ្ឋកម្មទាំងនេះដែលត្រូវបានផ្តន្ទាទោសនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបានផ្តល់អនុសាសន៍ជាច្រើនដល់តុលាការដើម្បីឲ្យមានការយល់ដឹងច្រើនជាងមុនអំពីបញ្ហារសើបនេះ និងទទួលដោះស្រាយចំពោះជនរងគ្រោះនិងសាក្សីនៃអំពើហិង្សាលើយេនឌ័រ។[៤៩]

ការសិក្សារបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាឆ្នាំ២០០៦មិនត្រឹមតែបានបញ្ជាក់ថា តើការសិក្សាលើកដំបូងបានរកឃើញអ្វីខ្លះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបង្កើនការយល់ដឹងអំពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម ដែលត្រូវបានបង្កើតឡើងមកដល់ពេលនេះ។ លទ្ធផលទាំងនេះបានបញ្ជាក់បន្ថែមថា ទោះបីជាមានការហាមឃាត់ "ទង្វើខុសសីលធម៌"នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏អំពើហិង្សាលើយេនឌ័រតែងតែកើតមាននូវនិទណ្ឌភាពនេះដែរ។[៥០] ការសិក្សានេះ ក៏បានបង្ហាញថា ក្រៅពីរបាយការណ៍ជាច្រើនស្តីពីការរំលោភសេពសន្ថវៈ និងការរំលោភសេពសន្ថវៈមុនសម្លាប់ ក៏មានការរំលោភសេពសន្ថវៈនៅក្នុងពន្ធនាគារនៅមណ្ឌលអប់រំកែប្រែ នៅការិយាល័យខ្មែរក្រហម និងនៅមូលដ្ឋាននានា ដែលមិនបានបណ្តាលឲ្យជនរងគ្រោះស្លាប់នោះទេ។[៥១] ជាការពិតណាស់ជនរងគ្រោះមួយចំនួនក្នុងចំណោមជនរងគ្រោះដែលនៅរស់ទាំងនេះ បានចែករំលែករឿងរ៉ាវរបស់ពួកគេដល់ការសិក្សាស្រាវជ្រាវនេះ។[៥២]

ផ្នែកមួយនៃអំពើហិង្សាលើយេនឌ័រ ដែលទទួលបានការចាប់អារម្មណ៍បំផុតនោះគឺការបង្ខំឲ្យរៀបការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការសិក្សាជាច្រើនបានពិនិត្យទៅលើទិដ្ឋភាពផ្សេងៗនៃការបង្ខំឲ្យរៀបការ រួមមានភាពយូរអង្វែងនៃអាពាហ៍ពិពាហ៍ទាំងនេះ[៥៣] និងផលប៉ះពាល់ផ្សេងៗទៅលើការអប់រំរបស់កុមារដែលបណ្តាលមកពីសមូហកម្មទាំងនេះ[៥៤] នៅក្នុងប្រធានបទផ្សេងទៀត។ ក្នុងចំណោមការសិក្សាដ៏លម្អិតទាំងនេះ **Peg Le Vine** ជាអ្នកចិត្តវិទូនៅគ្លីនិកមួយ ជាអ្នកឯកទេស

[៤៨] *សូមមើលជាទូទៅ* Nakagawa, *Gender-Based Violence* និង Bridgette Toy-Cronin, *"I Want to Tell You": Stories of Sexual Violence During Democratic Kampuchea (1975-1979)* (Phnom Penh: CDP, ២០០៦)។

[៤៩] *សូមមើល* Bridgette Toy-Cronin, *"I Want to Tell You*។*"*

[៥០] ដូចមានក្នុងសៀវភៅខាងលើ ទំព័រទី ១១។

[៥១] ដូចមានក្នុងសៀវភៅខាងលើ ទំព័រទី ៨-១០។

[៥២] ដូចមានក្នុងសៀវភៅខាងលើ ទំព័រទី ៨-១៥ (ការលើកឡើងពីភស្តុតាងរបស់ស្ត្រីបួននាក់ ដែលរួចជីវិតពីការរំលោភសេពសន្ថវៈ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ)។

[៥៣] Patrick Heuveline និង Bunnak Poch, "Do Marriages Forget Their Past? Marital Stability in post-Khmer Rouge Cambodia" *Demography* ៤៣ (២០០៦) ៩៩-១២៥។

[៥៤] Katsuo Kogure, "Impacts of Forced Marriages in Cambodia under the Pol Pot Regime," Discussion Paper No. 805, Institute of Social and Economic Research, Osaka University, March 2011 បានចូលមើលថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១១ http://www.iser.osaka-u.ac.jp/library/dp/2011/DP0805.pdf។

ផ្នែកសុខភាពផ្លូវចិត្តនៅជនបទ និងសាស្ត្រាចារ្យបានបោះពុម្ពផ្សាយសៀវភៅមួយដែលផ្តោតមួយផ្នែកទៅលើអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម និងបានលើកឡើង អំពីការសិក្សារយៈពេលមួយទសវត្សរ៍របស់អ្នកនិពន្ធអំពីបុរស និងស្ត្រីចំនួន១៩២នាក់ដែលបានរៀបអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម។[៥៥] នៅក្នុងអាជីពការងារ អ្នកស្រី **LeVine** បានសរសេរលម្អិតអំពីបទពិសោធន៍ផ្សេងៗនៃអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម និងមធ្យោបាយផ្សេងៗ ដែលអ្នកចូលរួមបានយល់ដឹងអំពីបទពិសោធន៍នេះប៉ុន្តែអ្នកស្រីប្រឆាំងនឹងការយល់ឃើញថាអាពាហ៍ពិពាហ៍ទាំងនេះជា"ការបង្ខំ"។[៥៦] ទោះបីជាអ្នកស្រីទទួលស្គាល់នូវស្ថានភាពដ៏លំបាក ដែលប្រជាជនភាគច្រើនត្រូវបានខ្មែរក្រហមរៀបអាពាហ៍ពិពាហ៍ឲ្យ រួមមានកង្វះសិទ្ធិតាមប្រពៃណី ការរស់នៅជាប្រពន្ធប្តីគ្មានសុភមង្គល និងការរួមភេទតាមបញ្ជា អ្នកស្រីបានគូសបញ្ជាក់អំពីលក្ខណៈផ្លាស់ប្តូរផ្សេងៗនៃទម្លាប់រៀបអាពាហ៍ពិពាហ៍ក្នុងរបបខ្មែរក្រហម និងវិធីដែលពួកគេមានបទពិសោធន៍អំពីការរៀបអាពាហ៍ពិពាហ៍។[៥៧]

## ៤.៥ អំពើហិង្សាលើយេនឌ័រនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ថ្វីបើមានការស្រាវជ្រាវ មានលក្ខណៈដែលអាចកើតឡើងនៃអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម និងការអំពាវនាវឲ្យគេដាក់បញ្ចូលលក្ខណៈនៃអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហមទៅក្នុងឧក្រិដ្ឋកម្ម ដែលត្រូវយកមកពិចារណានៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដោយក៏មកទល់ពេលនេះអំពើហិង្សាលើយេនឌ័របានដើរតួនាទីតិចតួចនៅក្នុងតុលាការ។ សំណុំរឿងទីមួយរបស់តុលាការប្រឆាំងនឹងលោក កាំង ហ្គិចអ៊ាវ (ហៅ ឌុច) ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅស២១ ស២៤ និងបឹងជើងឯកជាទីតាំងដែល គេប្រើសម្រាប់ឃុំខ្លួនធ្វើទារុណកម្ម និងសម្លាប់សត្រូវនិងគ្រួសារជាច្រើននៅក្នុងរបបនេះ។ នៅក្នុងករណីនេះចុងចោទម្នាក់ត្រូវបានចោទប្រកាន់អំពីការរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៥៨] ហើយចុងចោទនោះត្រូវបានកាត់ឲ្យជាប់ទោសពីបទឧក្រិដ្ឋកម្មនោះ។[៥៩]



[៥៥] Peg LeVine, *Love and Dread in Cambodia: Weddings, Births, and Ritual Harm under the Khmer Rouge* (Singapore: NUS Press, ២០១០)។

[៥៦] ដូចមានក្នុងសៀវភៅខាងលើ ទំព័រទី ១៦-៣៥។

[៥៧] ដូចមានក្នុងសៀវភៅខាងលើ ទំព័រទី ១៦-៣៥ ៨៨-៨៩។

[៥៨] ករណីរំលោភសេពសន្ថវៈ ដែលត្រូវបានចាត់ទុកជា "ការបំពានផ្លូវភេទដោយបង្ខំ" ត្រូវបានប្រព្រឹត្តឡើងដោយអ្នកសួរចម្លើយ នៅគុកស២១ ប្រឆាំងនឹងអតីតគ្រូបង្រៀនរបស់ ឌុច។ ដីកាដំណោះស្រាយ (ឯកសារបោះពុម្ពផ្សាយជា សាធារណៈ) សំណុំរឿងលេខ ០០២/១៤-០៨-២០០៦/ អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ D99 ថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៨, ពីកថាខណ្ឌ ១០៥ ១៣៧។

[៥៩] សាលដីកា សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/ អ.វ.ត.ក/អ.ជ.ស.ជ ឯកសារលេខ E188 ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១០ ពីកថាខណ្ឌ ៣៦៦ ៥៥៩។

## សាវតា

សំណុំរឿង០០២ ដែលបច្ចុប្បន្ននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានលើកឡើងពីវិសាលភាពដ៏ធំធេងនៃឧក្រិដ្ឋកម្ម និងតំបន់ភូមិសាស្ត្រនានា។[៦០] ក្នុងចំណោមឧក្រិដ្ឋកម្ម និងតំបន់ភូមិសាស្ត្រទាំងនេះ ដីកាចោទប្រកាន់មកលើចុងចោទ រួមមាន ការចោទប្រកាន់ពីបទការបង្ខំឲ្យរៀបការ[៦១] ប៉ុន្តែមិនមែនការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍នោះទេដែលរងផលប៉ះពាល់ពីការចោទប្រកាន់របស់អង្គបុរេជំនុំជម្រះ។[៦២] ដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែល អំពាវនាវសុំឲ្យធ្វើការណែនាំជាថ្មីអំពីឧក្រិដ្ឋកម្មរំលោភសេពសន្ថវៈ បច្ចុប្បន្នស្ថិតនៅក្នុងអង្គជំនុំជម្រះ។[៦៣] ជាពិសេសការដាក់បញ្ចូលឧក្រិដ្ឋកម្មលើយេនឌ័រ ដែលភាគច្រើនផ្តើមចេញពីកិច្ច ប្រឹងប្រែងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលធានាថា ឧក្រិដ្ឋកម្មទាំង នេះត្រូវបានពិចារណាដោយតុលាការ។[៦៤] ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណី ២១២២នាក់[៦៥] បានទទួលស្គាល់នៅពេលមានដីកាដំណោះស្រាយមាន ៦៦៤នាក់ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ត្រូវបានទទួលស្គាល់ជាលើកដំបូងផ្អែកលើ "បទប្បញ្ញត្តិរៀប

[៦០] ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងលេខ ០០២ រួមមាន៖ ១)ចលនារបស់ប្រជាជន (ត្រូវបានបែង ចែកបណ្តោះអាសន្នជា៣ឃ្លា) ២)កន្លែងការដ្ឋាន និងសហករ (សរុប៦កន្លែង រួមមាន ស២១ ដែលស្ថិតនៅក្នុងវិសាល ភាពនៃសំណុំរឿង០០១) ៣)មជ្ឈមណ្ឌលសន្តិសុខ និងកន្លែងពិឃាដ (សរុប១៤កន្លែង) ៤)ក្រុមជាក់លាក់ (សរុប៤ រួមមានពុទ្ធសាសនិក ជនជាតិវៀតណាម ចាម និងអាពាហ៍ពិពាហ៍បង្ខំ) និង៥)ស្ថានភាព៣ផ្សេងទៀតត្រូវបានចាត់ទុកថា ជា"ករណីផ្សេងទៀត។" *សូមមើល* សំណុំរឿង០០២ ដីកាដំណោះស្រាយ។

[៦១] សំណុំរឿង០០២ ដីកាដំណោះស្រាយ ពីកថាខណ្ឌ ១៦១៣។

[៦២] នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង០០២ បានទទួលយក ទឡ្ហីករណ៍ដែលត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ និងនួន ជា និងបានចាត់ទុកអំពើរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្រៅ សំណុំរឿង០០២ ដីកាដំណោះស្រាយ។ *សូមមើល* សាធារណៈ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/ អ.វ.ត.ក/អ.ជ.ស.ដ (អបជ១៤៥ និងអបជ១៤៦) ឯកសារលេខ D427/2/12 ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ពីកថាខណ្ឌ ១១(២)។

[៦៣] ចាប់តាំងពីពេលនោះមកទាំងសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអំពាវនាវឲ្យការចាត់ថ្នាក់ជាថ្មីនូវអំពើរំលោភទាំងនេះថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនមែនចាត់ថ្នាក់ក្រោមប្រភេទរងនៃ "អំពើអមនុស្សធម៌ផ្សេងទៀតនោះទេ។" *សូមមើល* សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិសំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក-អ.ជ.ស.ដ ឯកសារលេខ E99 ចុះថ្ងៃទី១៦ មិថុនា ២០១១។ នៅខែមិថុនា ឆ្នាំ២០០៩ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ហើយមេធាវីក៏បានធ្វើការដាក់ជូនដែលស្រដៀងគ្នា និងដោយសំងាត់ផងដែរទៅកាន់តុលាការ។

[៦៤] *សូមមើល ឧ.* សំណើទីពីរសុំឲ្យមានវិធានការស៊ើបអង្កេតអំពីអាពាហ៍ពិពាហ៍ដោយបង្ខំនិងទំនាក់ទំនងផ្លូវភេទដោយបង្ខំ(ឯកសារបោះពុម្ពផ្សាយជាសាធារណៈ) សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក-អ.ជ.ស.ដ ឯកសារលេខ D188 ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ និង សំណើលើកទីបួនរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យមានកិច្ចស៊ើបសួរ ពាក់ព័ន្ធអាពាហ៍ពិពាហ៍ដោយបង្ខំ និងឧក្រិដ្ឋកម្មផ្លូវភេទសំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក-អ.ជ.ស.ដ ឯកសារលេខ D268 ចុះ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០០៩។ ប៉ុន្តែមានឧទាហរណ៍ចំនួន ២ស្តីពីសំណើជាច្រើនសុំឲ្យមានវិធានការស៊ើបអង្កេត ព្រមទាំងការដាក់ជូនឯកសារស្តីពីអំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យបន្ថែមនៅក្នុងសំណុំរឿងនេះ។

[៦៥] ដើមបណ្តឹងរដ្ឋប្បវេណីគឺជាជនរងគ្រោះ ឬជាសាច់ញាតិរបស់ជនរងគ្រោះដោយអំពើឃោរឃៅរបស់ខ្មែរក្រហមដែល ត្រូវបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលថា ពួកគេបានទទួលរងនូវរបួសផ្លូវកាយ ឬផ្លូវចិត្ត "ជាផលវិបាកផ្ទាល់ យ៉ាងហោចឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើន ដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទ។" មាត្រា ២៣*bis*(១)(ក), វិធានផ្ទៃក្នុងនៃ អ.វ.ត.ក (Rev. 8)។ នៅពេលដែលតុលាការអនុញ្ញាតអាណត្តិរបស់អ.វ.ត.កអនុញ្ញាតឲ្យជនរងគ្រោះចូលរួមក្នុងដំណើរការនីតិវិធីនៅចំពោះមុខតុលាការ ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែង នៃការចោទប្រកាន់ និងស្នើសុំសំណងជំងឺចិត្តដល់ការខូចខាតរបស់ជនរងគ្រោះ។ *សូមមើល* មាត្រា២៣(១), វិធានផ្ទៃក្នុង (Rev. 8) នៃ អ.វ.ត.ក។

អាពាហ៍ពិពាហ៍។"[៦៦] ចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះកាលពីថ្ងៃទី២៣ មិថុនា ២០១០ ទៅលើការទទួលបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសល់ និងការទទួលស្គាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ១៧៤៨ បន្ថែមទៀត ចំនួននេះទំនងជាកើនឡើងយ៉ាងខ្លាំង។[៦៧]

ខណៈពេលលើកឡើងពីទម្រង់ផ្សេងទៀតនៃអំពើហិង្សាលើយេនឌ័ររួមមានការចាប់រំលោភក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ ការចោទប្រកាន់មិនត្រូវបានបង្ហាញនោះទេ។ បើនិយាយពីការរំលោភសេពសន្ថវៈវិញ សហចៅក្រមស៊ើបអង្កេត "បានអង្កេតឃើញថា គោលនយោបាយរបស់គណបក្សកុម្មុយនីស្តកម្ពុជាផ្លូវការពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ គឺត្រូវទប់ស្កាត់នូវការកើតមានទាំងនេះនិងផ្តន្ទាទោសជនដែលដល់"។[៦៨] ផ្អែកលើមូលដ្ឋាននេះការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវដកចេញពីដីកាចោទប្រកាន់លើកដំបូង ហើយវាទំនងថា ការកាត់ទោសឧក្រិដ្ឋកម្មលើយេនឌ័រ ដូចជាការកាត់អវៈយវៈភេទ និងការធ្វើទារុណកម្មមិនត្រូវបានតុលាការស៊ើបអង្កេតនោះទេ។


បន្ទប់សវនាការធំរបស់ អ.វ.ត.ក: រូបភាពដែលផ្តល់អោយដោយផ្នែកកិច្ចការសាធារណៈ អ.វ.ត.ក

ការកាត់ទោសសំណុំរឿង០០២គ្រោងនឹងចាប់ផ្តើមនៅចុងខែវិច្ឆិកា ២០១១ ហើយគេនៅតែយល់ឃើញថា តើភាពលេចធ្លោអ្វីខ្លះដែលឧក្រិដ្ឋកម្មលើយេនឌ័រនឹងត្រូវបានផ្តល់។ ប៉ុន្តែប្រសិនបើមកទល់ពេលនេះការអភិវឌ្ឍន៍គឺជាការគូសបញ្ជាក់មួយ វាទំនងថាឧក្រិដ្ឋកម្មលើយេនឌ័រភាគច្រើន ដែលត្រូវបានប្រព្រឹត្តដោយភ្នាក់ងាររបស់ខ្មែរក្រហមនឹងមិនត្រូវបានយកមកផ្តន្ទាទោសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ទោះបីជាចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង មានអំណាចចាត់ថ្នាក់ឧក្រិដ្ឋកម្មទាំងនេះជាថ្មី និងទទួលស្គាល់នូវភស្តុតាងថ្មីស្តីពីគំនិតផ្តួចផ្តើមផ្ទាល់របស់ពួកគេក៏ដោយ[៦៩] ក៏កិច្ចប្រឹងប្រែងក្នុងការលើកទឹកចិត្តឲ្យមានអភិក្រមបែបនេះ នៅខាងអ្នកតំណាងជនរងគ្រោះមិនបានទទួលជោគជ័យនោះទេមកទល់ពេលនេះ។

[៦៦] សំណុំរឿង០០២ ដីកាដំណោះស្រាយ D427 ពីកថាខណ្ឌ ៨៦១ (ថែងថា ដើមបណ្តឹងរដ្ឋប្បវេណី៦៦៩នាក់ត្រូវបានអង្គបុរេជំនុំជម្រះទទួលស្គាល់ដោយសម្អាងលើអាពាហ៍ពិពាហ៍ដោយបង្ខំ)។ សំណុំរឿងនេះបានឲ្យដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីទាំង៦៦៩នាក់មិនមែនសុទ្ធតែជាជនរងគ្រោះផ្ទាល់ដោយអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ។ មួយចំនួនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាដើមបណ្តឹងរដ្ឋប្បវេណីផ្អែកលើមូលដ្ឋានទំនាក់ទំនងជិតស្និទ្ធជាមួយជនរងគ្រោះ។

[៦៧] តួលេខដែលមានបង្ហាញនៅទីនេះ ត្រូវបានបុគ្គលិកអង្គភាពគាំទ្រជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខនៃ អ.វ.ត.ក បង្កើតជាតារាង ប៉ុន្តែបច្ចុប្បន្នមិនមានតួលេខគួរឲ្យទុកចិត្ត ដែលបញ្ជាក់ពីចំនួនសរុបនៃដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ ដោយសម្អាងលើអាពាហ៍ពិពាហ៍ដោយបង្ខំ("ការដាក់កម្រិតឲ្យរៀបអាពាហ៍ពិពាហ៍") នៅក្នុងសំណុំរឿង០០២។

[៦៨] ដីកាដំណោះស្រាយ បណ្តឹង ០០២ ពីកថាខណ្ឌ ១៤២៩។

[៦៩] វិធាន៩៣, វិធានផ្ទៃក្នុង (Rev. 8) (ការផ្តល់អំណាចឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការស៊ើបអង្កេតបន្ថែម ក្នុងករណីចាំបាច់ និងវិធាន ៩៨(២) វិធានផ្ទៃក្នុង (Rev. 8) (ការផ្តល់អំណាចឲ្យអង្គជំនុំជម្រះសាលាដំបូងផ្លាស់ប្តូរការចាត់ថ្នាក់ផ្លូវច្បាប់នូវឧក្រិដ្ឋកម្មនានា ដូចមានចែងនៅក្នុងដីកាបណ្តោះអាសន្ន ដរាបណាធាតុផ្សំសំខាន់ៗមិនត្រូវបានណែនាំ")។

# សាវតា

ក្រៅពីលទ្ធភាពនៃការកាត់ឲ្យជាប់ទោស អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏បានបើកឱកាសឲ្យជនរងគ្រោះដោយឧក្រិដ្ឋកម្មដែលត្រូវបានផ្តន្ទាទោសដោយតុលាការ ទាមទារសំណងជំងឺចិត្ត ទី១នៅក្នុងសាលាក្តីអន្តរជាតិដែលកំពុងផ្តន្ទាទោសជនដៃដល់ទាំងនោះ។[៧០] ការផ្លាស់ប្តូរថ្មីៗនៅក្នុងវិធានផ្ទៃក្នុងរបស់តុលាការបានបង្កើតឲ្យមានមធ្យោបាយបន្ថែមក្នុងទម្រង់នៃវិធីការក្រៅប្រព័ន្ធតុលាការ ដើម្បីដោះស្រាយព្យសនកម្មដែលជនរងគ្រោះក្នុងរបបខ្មែរក្រហមគ្រប់រូបបានទទួលរងដោយមិនគិតពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងឋានៈដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ នៅក្នុងករណីនេះ ទោះបីជាឧក្រិដ្ឋកម្មលើយេនឌ័រមិនត្រូវបានកាត់ទោសក្តី ក៏ជនរងគ្រោះដោយឧក្រិដ្ឋកម្មទាំងនេះ នៅតែអាចទទួលផលប្រយោជន៍ពីគម្រោងផ្តល់សំណងជំងឺចិត្តក្នុងគោលបំណងដោះស្រាយការឈឺចាប់របស់ពួកគេ ដែលអាចត្រូវបានអនុវត្តនៅក្នុងសាលក្រមណាមួយដែលត្រូវធ្វើនៅក្នុងករណីទាំងនេះនៅចំពោះមុខតុលាការ។[៧១]

ទោះបីមិនមែនជាការជំនួសនូវសាលក្រមលើសំណងជំងឺចិត្តដែលអាចអនុវត្តបានតាមផ្លូវច្បាប់ប្រឆាំងនឹងជនជាប់ចោទក៏ដោយ ក៏វិធីសាស្ត្រនេះផ្តល់ឱកាសថ្មីគួរឲ្យចាប់អារម្មណ៍ និងសំខាន់សម្រាប់ដោះស្រាយតម្រូវការរបស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។ គម្រោងមួយនេះត្រូវបានបង្កើតឡើង និងបានទទួលមូលនិធិរួចជាស្រេច។[៧២]

[៧០] វិធាន២៣ វិធានផ្ទៃក្នុង (Rev. 8) (ការផ្តល់សិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណងជំងឺចិត្ត "ផ្នែកសីលធម៌ និងសមូហភាព" នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខតុលាការ) វិធាន២៣*quinquies*(១) (ចែងថា សំណងជំងឺចិត្តមិនអាចផ្តល់ជូនជា "រូបិយវត្ថុ" ដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ) និងវិធាន២៣*quinquies*(៣) (ការផ្តល់ជូននេះអាចផ្តល់ជា លក្ខណៈបណ្តឹងទាមទារប្រឆាំងនឹងជនជាប់ចោទ ឬក្នុងទម្រង់ជាគម្រោងដែលទទួលស្គាល់តាមផ្លូវតុលាការ) វិធានផ្ទៃក្នុង (Rev. 8)។

[៧១] វិធានផ្ទៃក្នុងចែងថា "អង្គភាពគាំទ្រជនរងគ្រោះនឹងត្រូវទទួលខុសត្រូវចំពោះការអភិវឌ្ឍ និងការអនុវត្តកម្មវិធី និងវិធានការក្រៅប្រព័ន្ធតុលាការដោយលើកឡើងពីផលប្រយោជន៍ដ៏ធំធេងរបស់ជនរងគ្រោះ។ កម្មវិធីទាំងនេះអាចត្រូវបានបង្កើតឡើង និងអនុវត្តដោយមានការសហការជាមួយអង្គការរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល នៅក្រៅ អ.វ.ត.ក ក្នុងករណីសមស្រប"។ មាត្រា១២*bis*(៣), វិធានផ្ទៃក្នុង (Rev. 8)។

[៧២] អង្គភាពគាំទ្រជនរងគ្រោះនៃ អ.វ.ត.ក ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា(CDP) និងអង្គការចិត្តសាស្ត្រសង្គម និងអន្តរវប្បធម៌ (TPO) បានរួមគ្នាអនុវត្តមូលនិធិ UN Trust ដើម្បីបញ្ចប់អំពើហិង្សាលើគម្រោងផ្តល់ហិរញ្ញវត្ថុដល់ស្ត្រី ដែលមានបំណងលើកកម្ពស់ដំណើរការយុត្តិធម៌អន្តរកាលសំដៅចំពោះស្ត្រី ដោយដាក់បញ្ចូលវិធានការយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ ផ្នែកស្តារឡើងវិញ ផ្នែកសេដ្ឋកិច្ច និងផ្នែកសំណងជំងឺចិត្តសម្រាប់ស្ត្រីរងគ្រោះដោយខ្មែរក្រហមរួមមាន ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។ គម្រោងនេះដំណើរការទៅស្របគ្នានឹងដំណើរការនីតិវិធីនៅអ.វ.ត.ក និងឯករាជ្យពី សំណងជំងឺចិត្ត ដែលតុលាការអាចផ្តល់ជូន។

# ៥. របកគំហើញ



## ៥.១ ប្រជាសាស្ត្រ

### តារាងទី១៖ លក្ខណៈសម្គាល់ប្រជាសាស្ត្ររបស់អ្នកឆ្លើយសំណួរ

*[ទំហំសំណាក (n) = ១០៨]*

| ភេទ | | អាយុ | | សក្រ(ខេត្ត) | |
|---|---|---|---|---|---|
| ស្ត្រី | ៥១.០% | ៤០ - ៤៩ | ១៣.៥% | បាណន់ (បាត់ដំបង) | ២៦.៩% |
| បុរស | ៤៩.០% | ៥០ - ៥៩ | ៤៥.២% | សង្កែ(បាត់ដំបង) | ២៧.៩% |
| | | ៦០ - ៦៩ | ២៦.៩% | ចន្ទ្រា (ស្វាយរៀង) | ១៧.៣% |
| | | ៧០ - ៧៩ | ១០.៦% | ស្វាយជ្រំ (ស្វាយរៀង) | ២៧.៩% |
| | | ៨០ - ៨៩ | ៣.៨% | | |

| ស្ថានភាព | | ជាតិពន្ធ | | ការងារ | |
|---|---|---|---|---|---|
| ប្រជាជនថ្មី | ៦៥.០% | ខ្មែរ | ៨៣.៧% | ស្រែចម្ការ/សំណង់ | ៧៤.០% |
| ប្រជាជនមូលដ្ឋាន | ២៥.០% | ខ្មែរ-ចិន | ៦.៧% | តួនាទីសេវា | ៦.៨% |
| ខ្មែរក្រហម | ៣.៨% | កម្ពុជាក្រោម | ៤.៨% | ក្រុម/ប្រធានភូមិ | ៤.៨% |
| បេក្ខជន | ២.៩% | ខ្មែរ-វៀតណាម | ១.០% | អ្នកឃ្វាលគោ ក្របី | ៣.៨% |
| មិនដឹង | ៣.០% | ផ្សេងៗ | ៣.៨% | គិលានុប្បដ្ឋយិកា/ឆ្មប/គ្រូថ្នាំបុរាណ | ៣.៨% |
| | | | | ផ្សេងៗ | ៦.៨% |

### ៥.១.១ ភេទ និងអាយុ

បទសម្ភាសន៍សម្រាប់ការសិក្សានេះ ត្រូវបានធ្វើឡើងជាមួយអ្នកឆ្លើយសំណួរ១០៨នាក់ ដែលបានរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកឆ្លើយសំណួរ៥១%ជាស្ត្រី និង៤៩%ជាបុរស។ អាយុមធ្យមរបស់អ្នកឆ្លើយសំណួរដែលត្រូវបានសម្ភាស នៅក្នុងការអង្កេតនេះភាគច្រើនគឺ៥៩ឆ្នាំ ហើយអ្នកសម្ភាសន៍ដែលមានអាយុក្មេងបំផុតគឺ៤២ឆ្នាំនៅពេលសម្ភាស និងចាស់បំផុតគឺ៨៤ឆ្នាំ។ ៧២.១% ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់ភាគច្រើនមានអាយុចន្លោះពី៥០ ទៅ៦៩ឆ្នាំនៅពេលសម្ភាស

# របកគំហើញ

បើរាប់ទៅកាលសម័យកម្ពុជាប្រជាធិបតេយ្យពួកគាត់មានអាយុចន្លោះប្រហែល១៥ទៅ៣៤ឆ្នាំ កាលពីខែមេសា ឆ្នាំ១៩៧៥។

## ៥.១.២ តំបន់ភូមិសាស្ត្រ និងការនៅជិតអគារខ្មែរក្រហម

អ្នកឆ្លើយសំណួរទាំងនេះមកពីស្រុកពីរនៅខេត្តបាត់ដំបង មានស្រុកបាណន់ និងស្រុកសង្កែ និង ស្រុកពីរទៀតនៅខេត្តស្វាយរៀង មានស្រុកស្វាយជ្រុំ និងស្រុកចន្ទ្រា។ បទសម្ភាសន៍ សរុប ៤៦(៤៤.២%) ត្រូវបានបញ្ចប់នៅខេត្តបាត់ដំបង រីឯបទសម្ភាសន៍៥៨(៥៥.៨%)ត្រូវបានបញ្ចប់នៅខេត្តស្វាយរៀង។

អ្នកឆ្លើយសំណួរជាង៨០% ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់អាចស្គាល់ពន្ធនាគារមន្ទីរសន្តិសុខ និង/ឬទីតាំងសម្លាប់មនុស្ស ដែលនៅជិតបំផុតនឹងតំបន់ ដែលពួកគាត់បានរស់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកឆ្លើយសំណួរ ៣ នាក់ (២.៩%) បានរាយការណ៍ថា បានធ្វើការនៅទីតាំងទាំងនេះ រីឯ១២%ទៀត បានរាយការណ៍ថា ធ្លាប់ត្រូវគេដាក់គុកនៅទីតាំងទាំងនេះ ឬធ្លាប់រស់នៅជិតគុក មន្ទីរសន្តិសុខឬកន្លែងសំលាប់មនុស្សក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។




ពន្ធនាគារ មន្ទីរសន្តិសុខ និងកន្លែងសំលាប់មនុស្សជាច្រើនដែលអ្នកឆ្លើយសំណួរស្គាល់ឈ្មោះមានជាអាទ៍វត្តធ្លក និងវត្តគិរីរម្យគឺជាកន្លែងរក្សាឯកសារដ៏ត្រឹមត្រូវស្តីពីការរំលោភជាក្រុមរួមទាំងធ្វើទារុណកម្ម និងការសម្លាប់ដែលគេស្គាល់ថា បានកើតឡើងក្នុងសម័យនោះ។[៧៣] កន្លែងឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានរៀបរាប់ខាងលើ ត្រូវបានដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយសម្រាប់សំណុំរឿង ០០២ ដែលបច្ចុប្បន្ននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ព័ត៌មានដែលប្រមូលបានពីបទសម្ភាសន៍ទាំងនេះបានលើកឡើងថា សកម្មភាពនានាដែលខ្មែរក្រហមបានប្រព្រឹត្តនៅពន្ធនាគារ មន្ទីរសន្តិសុខ និងកន្លែងពិឃាដពាក់ព័ន្ធនឹងបទសម្ភាសន៍របស់អ្នកឆ្លើយសំណួរ

[៧៣] *សូមមើល ខ.* ដីកាដំណោះស្រាយ បណ្តឹង ០០២ ឯកសារលេខ ៤២៧ ពីកថាខណ្ឌ ៥៥១-៥៧១ និង ៦៤៤-៦៦៦។

គឺស្រដៀងគ្នា នឹងសកម្មភាពដែលខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងទីតាំង ដែលមានឈ្មោះនៅក្នុងដីកាដំណោះស្រាយ។

### ៥.១.៣ ស្ថានភាពក្រោមរបបខ្មែរក្រហម

ដូចដែលបានកត់សម្គាល់ខាងដើមអញ្ចឹង ខ្មែរក្រហមត្រូវបានគេស្គាល់ថា បានចាត់ក្រុម និងពិនិត្យមើលបុគ្គលទាំងនេះទាក់ទងនឹងសម្បថដែលត្រូវបានមើលឃើញនៅក្នុងរបបនេះ និងសារតាផ្ទាល់ខ្លួន ក៏ដូចជាកត្តាផ្សេងទៀតផងដែរ។ នៅក្នុងការអង្កេតនេះ គេបានសុំឲ្យអ្នកឆ្លើយសំណួរកំណត់ឋានៈដែលខ្មែរក្រហមបានចាត់ចែងឲ្យពួកគេ។ អ្នកឆ្លើយសំណួរជិត២ភាគ៣ (៦៥.៣%) បានគូសបញ្ជាក់ថា ពួកគេត្រូវបាន ចាត់ទុកជា "ប្រជាជនថ្មី"[៧៤] ក្រោមរបប នេះ រីឯអ្នកឆ្លើយសំណួរ១ភាគ៤ ទៀត (២៥.០%) ត្រូវបានចាត់ទុកជា "ប្រជាជនមូលដ្ឋាន"។[៧៥] អ្នកឆ្លើយសំណួរ៤ នាក់ (៤.៨%) បានកំណត់ខ្លួនឯង ថាជា សម្ព័ន្ធភាពរបស់ខ្មែរក្រហមដែលតាមធម្មតា មានតួនាទីតូចតាចដូចជាទាហាន ឬអ្នកបើកបរ រីឯអ្នកឆ្លើយសំណួរ២.៩%ទៀតបានរាយការណ៍ថា ពួកគេត្រូវបានខ្មែរក្រហមចាត់ទុកជា "ប្រជាជនត្រៀម"។[៧៦] ៣%ចុងក្រោយបានគូសបញ្ជាក់ថា ពួកគេមិនបានដឹងអំពីការចាត់តាំងឋានៈនៅក្នុងរបបនោះទេ។

### ៥.១.៤ ជាតិពន្ធ

អ្នកឆ្លើយសំណួរច្រើនជាង៨នាក់ក្នុងចំណោមអ្នកឆ្លើយសំណួរ១០នាក់ (៨៣.៧%) បានរាយការណ៍ថា ពួកគេជាជនជាតិខ្មែរ។ ជាតិពន្ធដែលត្រូវបានរាយការណ៍ញឹកញាប់បំផុត គឺជនជាតិខ្មែរ-ចិន មានចំនួន៦.៧% និងកម្ពុជាក្រោម[៧៧] មានចំនួន៤.៨%។ អ្នកឆ្លើយសំណួរម្នាក់ក៏បានស្គាល់ខ្លួនឯង ថាជាខ្មែរ-វៀតណាម ហើយអ្នកឆ្លើយសំណួរ៣.៨%បានស្គាល់ខ្លួនឯងថា ជាជនជាតិផ្សេង

[៧៤] "ប្រជាជនថ្មី" គឺជាការចាត់ថ្នាក់ចំពោះមនុស្សដែលមិនបានរស់នៅក្នុងតំបន់ដែលត្រួតត្រាដោយខ្មែរក្រហម មុនថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ និងជាប្រជាជនថ្មីនៅក្នុងបដិវត្តន៍។ *សូមមើល* Becker, *When the War Was Over* ២២៦។ "និរទេសជន" ត្រូវបានរាប់បញ្ចូលនៅក្នុងប្រភេទប្រជាជនថ្មីក្នុងគោលបំណងកត់សម្គាល់ និងចាត់ថ្នាក់នៅទីនេះ។ អ្នកទាំងនេះគឺជាមនុស្សដែលត្រូវបានផ្លាស់លំនៅមកពីតំបន់ផ្សេងៗ ហើយជារឿយៗត្រូវបានតាំងលំនៅនៅតំបន់ដាច់ស្រយាល ឬតំបន់គ្មានការកាន់កាប់ ឬត្រូវបានអនុញ្ញាតឲ្យស្នាក់នៅបណ្តោះអាសន្ននៅក្នុងសហករណ៍ មុននឹងផ្លាស់ទៅធ្វើការនៅកន្លែងផ្សេងទៀត។

[៧៥] "ប្រជាជនមូលដ្ឋាន" ឬ "អ្នកចាស់" ជាទូទៅសំដៅលើមនុស្សដែលបានរស់នៅក្នុងតំបន់ដែលត្រួតត្រាដោយខ្មែរក្រហម មុនការដួលរលំនៃរាជធានីភ្នំពេញ និងត្រូវគេចាត់ទុកថា បាន រួមចំណែកក្នុងបដិវត្តន៍។ *សូមមើល* ដូចមានក្នុងសៀវភៅខាងលើ។

[៧៦] "ប្រជាជនត្រៀម" គឺជាអ្នកកាន់តួនាទីថ្នាក់កណ្តាល រវាងប្រជាជនថ្មីនិងអ្នកមូលដ្ឋាន ក្រោមរបបខ្មែរក្រហម។ ជាពិសេស ពួកគេជាប្រជាជនថ្មីដែលមានអាចចូលរួមក្នុងការគ្រប់គ្រងសហករណ៍ និងទទួលបានឋានៈខ្ពស់ជាងគេបន្តិច។ ដូចដើងទំព័រខាងលើ ២២៧។

[៧៧] កម្ពុជាក្រោម សំដៅដល់ជនជាតិខ្មែរដែលរស់នៅតាមតំបន់ដងទន្លេមេគង្គ ដែលពេលនេះស្ថិតនៅភាគខាងត្បូងប្រទេសវៀតណាម ដែលជាតំបន់មួយផ្នែករបស់ប្រទេសកម្ពុជា មុននឹងត្រូវបានប្រគល់អោយវៀតណាមដោយ អំណាចអាណានិគមបារាំង ក្នុងឆ្នាំ១៩៤៩។

ទៀត ដែលគេស្គាល់អត្តសញ្ញាណថា ជា"ជនជាតិផ្សេងទៀត" នៅក្នុងតារាងទី១ខាងលើ។ ក្នុងចំណោមអ្នកឆ្លើយសំណួរនៅក្នុងប្រភេទ "ផ្សេងទៀត" គឺជាអ្នកឆ្លើយសំណួរដែលគេស្គាល់អត្តសញ្ញាណថា ជាខ្មែរ-ថៃ ខ្មែរ-ឡាវ និងខ្មែរ-វៀតណាម-ចិន។

### ៥.១.៥ ការងារក្នុងរបបខ្មែរក្រហម

អ្នកឆ្លើយសំណួរជិតពាក់កណ្ដាល? — 

អ្នកឆ្លើយសំណួរជិតពាគ៤ (៧៤%) បានស្គាល់ការងាររបស់ពួកគេក្នុងរបបខ្មែរក្រហមថា ជា ការងារធ្វើស្រែចម្ការ ឬធ្វើសំណង់ ឬធ្វើទាំងពីរតែម្ដង។ ចម្លើយដ៏គួរឲ្យកត់សម្គាល់ផ្សេងទៀតរួមមានការបម្រើការជាប្រធានក្រុមការងារ ឬប្រធានភូមិ ឃ្វាលគោក្របី ធ្វើជាគិលានុបដ្ឋាយិកា ឆ្មប ឬគ្រូថ្នាំបុរាណ និងមានតួនាទីជាចុងភៅ អ្នកកាត់ដេរ ឬអ្នកនេសាទ។ អ្នកឆ្លើយសំណួរជាច្រើនបានគូសបញ្ជាក់ថា ពួកគេត្រូវបានផ្ដល់កិច្ចការថ្មីក្នុងរបបនោះ ជាពិសេស ជាអ្នកឆ្លើយសំណួរវ័យក្មេង និងត្រូវបានផ្លាស់ប្ដូរពីក្រុមកុមារទៅក្រុមចល័តរបស់មនុស្សវ័យក្មេង។ ទិន្នន័យដែលប្រមូលបានពីការងារទាំងនេះឆ្លុះបញ្ចាំងពីតួនាទីរបស់អ្នកឆ្លើយសំណួរនៅពេលចាប់ផ្ដើមរបបកម្ពុជាប្រជាធិបតេយ្យ។

## ៥.២ របកគំហើញទូទៅអំពីអំពើហិង្សាលើយេនឌ័រ

### ៥.២.១ ប្រភពនៃការយល់ដឹង

តារាងទី២៖ ការយល់ដឹងអំពីអំពើហិង្សាលើយេនឌ័ររបស់អ្នកឆ្លើយសំណួរដែលត្រូវបានរាយការណ៍

*[ទំហំសំណាក (n) = ១០៤]*

| ការយល់ដឹងទូទៅដែលត្រូវបានរាយការណ៍ (៨៦.៥%) | | សាក្សីផ្ទាល់ (៥១.៩%) | | បទពិសោធន៍ផ្ទាល់ខ្លួន (៥.៨%) | |
|---|---|---|---|---|---|
| ការរំលោភសេពសន្ថវៈ | ៦៥.៤% | ការរំលោភសេពសន្ថវៈ | ២៨.៨% | ការរំលោភផ្លូវភេទ និងការកាត់អវៈយវៈភេទ | ៤.៨% |
| ការកាត់អវៈយវៈភេទ | ២៤.0% | ការកាត់អវៈយវៈភេទ | ១៦.៣% | ការរំលោភសេពសន្ថវៈ | ១.0% |
| ការរំលោភផ្លូវភេទ និងការកាត់អវៈយវៈភេទ | ២0.២% | ការរំលោភផ្លូវភេទ និងការកាត់អវៈយវៈភេទ | ១៣.៥% | ការកាត់អវៈយវៈភេទ | -- |

អ្នកឆ្លើយសំណួរនៅក្នុងការសិក្សានេះត្រូវបានកំណត់តាមរយៈវិធីសាស្ត្រ **"snowball"** មិនមែនព្រាវៗ ឬមិនមែនតំណាង[៧៨] ដែលស្វះស្វែងកំណត់បេក្ខជនសម្ភាសន៍ដែលមានការយល់ដឹងអំពី

[៧៨] អ្នកនិពន្ធកត់សម្គាល់ថា ដោយសារតែបច្ចេកទេសសំណាកដែលគ្មានលក្ខណៈជាតំណាង ដែលត្រូវបានប្រើដើម្បីកំណត់អ្នកឆ្លើយសំណួរសម្រាប់ការអង្កេតនេះ អត្រាយល់ដឹងអំពីអំពើហិង្សាលើយេនឌ័រ នៅក្នុងក្រុមនេះ មិនមែន តំណាងឲ្យប្រជាជន ហើយក៏មិនមែនតំណាងឲ្យសហគមន៍ដែលអ្នកឆ្លើយសំណួររស់នៅដែរ។ ផ្ទុយទៅវិញ ពួកគេត្រូវបានរាយការណ៍នៅទីនេះថា ជាសូចនាករដ៏សំខាន់នៃប្រភេទការយល់ដឹង ដែលបុគ្គលទាំងនេះមានភាពជោគជ័យ និងភាពងាយស្រួលជាមួយអ្នកឆ្លើយសំណួរណាម្នាក់ ដែលអាចរាយការណ៍អំពីអំពើហិង្សាលើយេនឌ័រត្រូវបានគេឃើញ។

អំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម។ ទិន្នន័យដែលត្រូវបានប្រមូលនេះបានបង្ហាញថា ទិដ្ឋភាពនៃគម្រោងសិក្សានេះទទួលបានជោគជ័យយ៉ាងខ្លាំង ខណៈពេលដែលអ្នកឆ្លើយសំណួរ ជិត៩០%ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់រាយការណ៍ថាបានយល់ដឹងខ្លះៗអំពីអំពើហិង្សាលើយេនឌ័រដែលបានកើតឡើងនៅចន្លោះថ្ងៃទី ១៧ មេសា ១៩៧៥ និង ០៧ មករា ១៩៧៩។ ការនេះរួមមានការយល់ដឹងដែលទទួលបានពីការទទួលរងដោយផ្ទាល់នូវភាពក្លាយជាជនរងគ្រោះជាសាក្សីដែលបានឃើញអំពើហិង្សានេះផ្ទាល់ ដោយជនរងគ្រោះប្រាប់អំពីអំពើហិង្សានេះផ្ទាល់ និងអ្នកផ្សេងទៀតប្រាប់។

នៅពេលឈ្វេងយល់ឲ្យបានស៊ីជម្រៅថែមទៀតអំពីប្រភពនៃការយល់ដឹងនេះ គេបានរកឃើញថា ជាង៥០%នៃអ្នកឆ្លើយសំណួរទាំងអស់បានធ្វើជាសាក្សីផ្ទាល់ចំពោះ អំពើហិង្សាលើយេនឌ័រ ហើយនៅក្នុងករណីមួយចំនួន ពួកគាត់បានធ្វើជាសាក្សីដែលបានឃើញឧប្បទ្ទវហេតុជាច្រើន និង/ឬប្រភេទជាច្រើននៃអំពើហិង្សានេះ។ ទីណាមានករណីនេះកើតឡើង សាក្សីបានយល់ដឹងអំពីអំពើហិង្សាលើយេនឌ័រ ដោយបានឃើញសកម្មភាពនោះដោយផ្ទាល់ភ្នែក និងបានស្តាប់ឮសកម្មភាពនោះដោយផ្ទាល់ត្រចៀក ខណៈពេលវាកំពុងកើតឡើង ឬបានឃើញភស្តុតាង បន្ទាប់ទង្វើនោះហើយ ក្នុងករណីខ្លះបានឃើញសាកសពត្រូវបានគេកាត់អវៈយវៈភេទទៀតផង។ លើសពីនេះទៅទៀត អ្នកឆ្លើយសំណួរជិត៦%នៅក្នុងការសិក្សានេះរាយការណ៍ថា បានក្លាយជាជនរងគ្រោះផ្ទាល់ដែលបានឃើញទម្រង់មួយចំនួននៃអំពើហិង្សាលើយេនឌ័រនេះ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ជនរងគ្រោះភាគច្រើន (៥នាក់ក្នុងចំណោម៦នាក់)រាយការណ៍ថា បានទទួលរងការរំលោភសេពសន្ថវៈ ឬការកាត់អវៈយវៈភេទ រីឯជនរងគ្រោះម្នាក់រាយការណ៍ថា ខ្លួនអ្នកស្រីផ្ទាល់ត្រូវគេរំលោភបូក។

ក្រៅពីប្រភេទលើកដំបូងពីរនៃការយល់ដឹងនេះ អ្នកឆ្លើយសំណួរទាំងនេះក៏បានដឹងអំពីអំពើហិង្សាលើយេនឌ័រ ដោយសារតែជនរងគ្រោះបានចែករំលែករឿងរ៉ាវរបស់ពួកគេជាមួយគ្នាដោយផ្ទាល់ ឬជនរងគ្រោះផ្សេងទៀតបានប្រាប់ពួកគេ។ នៅក្នុងករណីបន្ទាប់ ជួនកាលការយល់ ដឹងបែបនេះទទួលបានមកពីអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយជនរងគ្រោះ ដូចជាសមាជិកគ្រួសារ រីឯពេលខ្លះទៀត ការយល់ដឹងនេះ ជាទូទៅបា នមកពីព័ត៌មានស្តីពីអំពើហិង្សាលើយេនឌ័រ ដែលជា "ការយល់ដឹងទូទៅ" មួយនៅក្នុងសហគមន៍ ឬក្រុមការងារ ឬជាព័ត៌មានដែលបានដឹងតាមរយៈប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានពិភាក្សាគ្នាក្រោយការដួលរលំនៃរបបនេះ។

អ្វីដែលកើតឡើងបន្ទាប់មកទៀតគឺបទបង្ហាញ ដែលបរិយាយលម្អិតអំពីទិន្នន័យស្តីពីអំពើហិង្សាលើយេនឌ័រដែលត្រូវបានប្រមូល តាមរយៈបទសម្ភាសន៍នានាសម្រាប់ការសិក្សានេះ។ ទិន្នន័យត្រូវបានរៀបចំទៅតាមប្រភេទរបស់វា ក្នុងគោលបំណងដើម្បីបង្ហាញឲ្យបានច្បាស់មិនត្រឹមតែអំពើហិង្សាលើយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសេណារីយ៉ូ និងកាលៈទេសៈ ដែលមានជាទូទៅនៅក្នុងទិន្នន័យ

ដែលអ្នកឆ្លើយសំណួរបានផ្តល់។ ឯកសារយោងជាច្រើនត្រូវបានធ្វើឡើង នៅក្នុងសេចក្តីលម្អិត និងភាសាជាក់លាក់ដែលអ្នកឆ្លើយសំណួរបានប្រើនៅក្នុងការរាយការណ៍អំពី ព្រឹត្តិការណ៍ទាំងនេះ។ ប៉ុន្តែក្នុងករណីដែលគេប្រើភាសាជាក់លាក់នេះ វាអាចជាការដកស្រង់សម្តី ដើម្បីរក្សាការសម្ងាត់របស់អ្នកឆ្លើយសំណួររបស់យើង ការដកស្រង់សម្តីនៅក្នុងបទសម្ភាសន៍របស់ពួកគេមិនត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារបោះពុម្ពផ្សាយអំពីរបាយការណ៍នេះ។ ផ្នែកមួយដោយឡែកដែលវិភាគអំពីប្រធានបទគន្លឹះ និងបញ្ហាសំខាន់ៗដែលត្រូវបានលើកឡើងតាមរយៈរបាយការណ៍របស់អ្នកឆ្លើយសំណួរអំពីអំពើហិង្សាលើយេនឌ័រត្រូវបានលើកឡើងនៅពេលក្រោយ។

### ៥.២.២ ការរំលោភសេពសន្ថវៈ

#### ៥.២.២.១ សេចក្តីផ្តើម

ជាទូទៅ ការរំលោភសេពសន្ថវៈគឺជាប្រភេទនៃ អំពើហិង្សាលើយេនឌ័រដែលត្រូវបានរាយការណ៍ច្រើនបំផុតដោយអ្នកចូលរួមនៅក្នុងការសិក្សានេះ។ អ្នកឆ្លើយសំណួរលើសពី ៦នាក់ក្នុងចំណោមអ្នកឆ្លើយសំណួរ១០នាក់(៦៥.៥%) រាយការណ៍អំពីការយល់ដឹង អំពីការរំលោភសេពសន្ថវៈនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៅទៀត អ្នកឆ្លើយសំណួរច្រើនជាង១/៤ (២៨.៨%)រាយការណ៍ថាបានឃើញការរំលោភសេពសន្ថវៈនោះដោយផ្ទាល់ រីឯអ្នកឆ្លើយសំណួរម្នាក់រាយការណ៍ថា ខ្លួនត្រូវបានគេរំលោភសេពសន្ថវៈដោយផ្ទាល់ក្នុងរបបខ្មែរក្រហម។ នៅក្នុង ៦ករណី (៥.៨%) អ្នកឆ្លើយសំណួរតែម្នាក់គត់បានឃើញការរំលោភសេពសន្ថវៈជាច្រើនក្នុងរបបនោះ។ លើសពីនេះទៅទៀត អ្នកឆ្លើយសំណួរជាច្រើនរាយការណ៍អំពីសេណារីយ៉ូដែលការរំលោភសេពសន្ថវៈនោះបានកើតឡើង។

ដើម្បីរៀបចំកិច្ចពិភាក្សានេះ អ្នកនិពន្ធបានអនុម័តលើនិយមន័យនៃការរំលោភសេពសន្ថវៈដែលប្រើនៅពេលបច្ចុប្បន្ននៅក្នុងច្បាប់អន្តរជាតិ។តាម និយមន័យនេះការរំលោភសេពសន្ថវៈកើតឡើនៅកន្លែងដែល៖

> ជនដៃដល់បានបំពានលើរាងកាយរបស់បុគ្គលម្នាក់តាមរយៈការចូលបំពានលើផ្នែកណាមួយនៃរាងកាយរបស់ជនរងគ្រោះ ឬជនដៃដល់យកប្រដាប់ភេទទៅដាក់ចូលក្នុងរន្ធគូទ ឬយកវត្ថុណាមួយទៅដាក់ក្នុងប្រដាប់ភេទ ឬផ្នែកណាមួយផ្សេងទៀតនៃរាងកាយរបស់ជនរងគ្រោះ។[៧៩]

[៧៩] Article7(1)(g)-1(1), Crime Against Humanity of Rape, Elements of Crimes, International Criminal Court បានចូលមើល ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១១ http://www.icc-cpi.int/NR/rdonlyres/336923D8-A6AD-40EC-AD7B-45BF9DE73D56/0/ElementsOfCrimesEng.pdf. ទោះបីជាមាត្រាដែលត្រូវបានលើកឡើងនៅទីនេះ សំដៅចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈក៏ដោយ ក៏ធាតុផ្សំនៃបទល្មើសស្របគ្នាទៅនឹងការចាត់ថ្នាក់គ្រប់ប្រភេទនៃឧក្រិដ្ឋកម្មនេះ(ពោលគឺ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម)។

និង

> ការបំពាននេះត្រូវបានធ្វើឡើងដោយបង្ខំ ឬគំរាមកំហែងដោយកម្លាំង ឬបង្ខំ ដូចជាការបំពានដែលបង្កឲ្យមានការភ័យខ្លាចដោយអំពើហិង្សា ការបង្ខិតបង្ខំការឃុំខ្លួន ការកៀបសង្កត់ផ្លូវចិត្ត ឬការរំលោភដោយប្រើអំណាចមកលើបុគ្គលនោះ ឬបុគ្គលផ្សេងទៀត ឬដោយឆ្លៀតយកប្រយោជន៍ពីបរិយាកាសបង្ខំ ឬការបំពាននេះត្រូវបានប្រព្រឹត្តមកលើបុគ្គល ដែលអសមត្ថភាពក្នុងការផ្តល់ការព្រមព្រៀងពិតប្រាកដ។[៨០]

តាមរយៈនិយមន័យនេះ ការស៊ិកបញ្ចូលក្នុងប្រដាប់ភេទ ឬរន្ធគូទរបស់ជនរងគ្រោះដោយវត្ថុខាងក្រៅត្រូវបានចាត់ថ្នាក់ជាសកម្មភាពរំលោភសេពសន្ថវៈ។ ការកេងប្រវ័ញ្ចផ្លូវភេទដែលឮជារឿយៗត្រូវបានអ្នកឆ្លើយសំណួរបានរៀបរាប់ថាមាន ពាក់ព័ន្ធនឹង ជនរងគ្រោះ ដែលបាន ផ្តល់ការរួមភេទ "ជាថ្នូរ នឹង" អាហារ ផលប្រយោជន៍ ឬដើម្បីឲ្យខ្លួនឯង ឬគ្រួសាររបស់ខ្លួនបាន រស់រានមានជីវិត និងទាសភាពផ្លូវភេទពាក់ព័ន្ធនឹងស្ត្រី ដែលមន្ត្រីខ្មែរក្រហម បានឃុំពួកគេដើម្បីបម្រើផ្លូវភេទដែលត្រូវបានដាក់បញ្ចូលក្នុងនិយមន័យអំពីការរំលោភសេពសន្ថវៈត្រូវ បានពិភាក្សានៅក្នុងចំណងជើងនេះ។

ព័ត៌មានលម្អិតដែលត្រូវបានរាយការណ៍នៅទីនេះ ត្រូវបានដកស្រង់ចេញពីដំណើររឿងផ្ទាល់ខ្លួននិងសាក្សីផ្ទាល់ភ្នែក ហើយសាច់រឿងរំលោភសេពសន្ថវៈដែលជនរងគ្រោះបានរាយការណ៍ដោយផ្ទាល់ទៅអ្នកឆ្លើយសំណួរមានតិចតួចប៉ុណ្ណោះ។ អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍អំពីសេណារីយ៉ូ ដែលពួកគេបានឃើញការរំលោភសេពសន្ថវៈជាបន្តបន្ទាប់ ឬបានស្គាល់ជនរងគ្រោះដែលបានប្រាប់រឿងរ៉ាវដែលបានកើតឡើងចំពោះពួកគេ។ ការបរិយាយអំពីការរំលោភសេពសន្ថវៈដែលមានបង្ហាញនៅទីនេះត្រូវបានរៀបចំជាប្រភេទរួម ដែលបានមកពីបទសម្ភាសន៍ដែលត្រូវបានធ្វើឡើងសម្រាប់ការសិក្សានេះ។

### ៥.២.២.២ ការរំលោភបូកនិងការរំលោភជាក្រុម

នៅក្នុងសាច់រឿងផ្ទាល់មួយនិយាយអំពីការរំលោភសេពសន្ថវៈជាក្រុម ឬរំលោភបូក ស្ត្រីអ្នកឆ្លើយសំណួរម្នាក់បានរៀបរាប់អំពីរបៀបដែលអ្នកស្រីត្រូវបានអ្នករំលោភសេពសន្ថវៈម្នាក់ក្នុងចំណោមអ្នកចាប់រំលោភច្រើននាក់នាំចេញពីបន្ទប់ទឹកចងមុខរួចនាំយកទៅរំលោភនៅក្នុងព្រៃគ្រាន់តែរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីគូដណ្តឹង និងគ្រួសារដែលនៅសល់របស់នាងត្រូវបានគេសម្លាប់។ អ្នកស្រីរាយការណ៍ថា បុរសបួននាក់បានរំលោភអ្នកស្រីនៅជិតវត្តមួយ ម្នាក់ក្នុងចំណោមនោះអ្នកស្រីស្គាល់

[៨០] Article 7(1)(g)-1(2) ដូចមានក្នុងសៀវភៅខាងលើ។ ទោះបីជាមាត្រាដែលត្រូវបានលើកឡើងនៅទីនេះ សំដៅចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈក៏ដោយ។

ថា ជាប្រធានក្រុមរបស់អ្នកស្រី តាមរយៈសម្លេងរបស់គាត់។ ជនរងគ្រោះនេះដែលបានធ្វើការជាគិលានុប្បដ្ឋយិកានៅក្នុងរបបនោះ ក៏បានព្យាបាលស្ត្រីវ័យក្មេងម្នាក់ដែលមុនពេលស្លាប់ នាងបានប្រាប់អ្នកស្រីថា នាងត្រូវបានប្រធានក្រុមរបស់នាង និងមនុស្ស៩នាក់ផ្សេងទៀតចាប់រំលោភ។ វាមិនច្បាស់នោះទេដែលថា ជនរងគ្រោះនេះស្លាប់ដោយសារការរងរបួសពីការរំលោភសេពសន្ទវៈទាំងនោះ។

អ្នកឆ្លើយសំណួរជាច្រើននៅក្នុងការអង្កេតនេះក៏បានរាយការណ៍ថា បានឃើញដោយផ្ទាល់ ឬត្រូវបានជនរងគ្រោះប្រាប់អំពីការរំលោភសេពសន្ថវៈដែលជនដៃដល់ទាំងនោះបានប្រព្រឹត្ត។ នៅក្នុងករណីខ្លះការរំលោភសេពសន្ថវៈទាំងនេះមានលក្ខណៈជាការរំលោភបូកមកលើជនរងគ្រោះម្នាក់ ឬរំលោភជាក្រុមដោយជនដៃដល់ច្រើននាក់មកលើក្រុមស្ត្រី ឬគ្រួសារជាច្រើន មុនពេលសម្លាប់ចោល។ នៅក្នុងករណីរំលោភបូកអ្នកឆ្លើយសំណួរភេទស្រីម្នាក់ដែលមានអាយុ១៣ ឬ១៤ឆ្នាំ នៅសម័យនោះបានឃើញគេរំលោភសេពសន្ថវៈស្ត្រីនៅក្នុងសហករណ៍របស់ខ្លួននៅផ្ទាល់ដីដែលមានរុក្ខជាតិដុះពេញនៅអតីតសាលារៀនមួយ។ នៅទីនោះមានសម្លេងយំស្រែក នាងបានឃើញកម្មាភិបាលខ្មែរក្រហមបីនាក់ជាមួយអ្នក ដែលនាងស្គាល់ត្រូវបានគេស្រាតសម្លៀកបំពាក់ រួចញុកមាត់នឹងក្រមា។[៨១] នាងបានរំលឹកថា ស្ត្រីនោះបានវាយតប់ជាមួយបុរសទាំងនោះ នៅពេលដែលពួកគេកំពុងរំលោភសេពសន្ថវៈគាត់ ហើយដុតស្បែករបស់គាត់។ ក្នុងរយៈពេលតែប៉ុន្មានថ្ងៃក្រោយមក ស្ត្រីវ័យក្មេងម្នាក់ទៀតមកពីសហករណ៍របស់ស្ត្រីដដែលនោះ បានប្រាប់អ្នកឆ្លើយសំណួរថា គាត់ត្រូវបានទាហានខ្មែរក្រហមរំលោភសេពសន្ថវៈរហូតដល់មានគតិ។ អ្នកឆ្លើយសំណួរនោះបានរាយការណ៍ថា ដោយសំណាងល្អជនរងគ្រោះ ដោយការរំលោភសេពសន្ថវៈនោះមិនត្រូវបានគេសម្លាប់ និងបានសម្រាលកូនបន្ទាប់ពីការរំដោះ។

> "ខ្ញុំជាក្រមុំព្រហ្មចារីដែលទើបតែមានអាយុ១៨ឆ្នាំ.... ខ្ញុំបានស្រែកហៅគេជួយ (ប៉ុន្តែ) ពួកគេបានវាយទាត់ធាក់ខ្ញុំ រហូតដល់ខ្ញុំយល់ព្រមរួមភេទជាមួយពួកគេ។ ខ្ញុំឈឺចាប់ណាស់។ ពួកគេបានអូសជើងខ្ញុំទៅម្ខាង...ខ្ញុំខឹងអាពួករំលោភសេពសន្ថវៈនោះណាស់។ នៅពេលដែលខ្ញុំនឹកឃើញរឿងឡើង ខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់។ ចាប់តាំងពីពេលនោះមក ខ្ញុំស្គមរីងរៃ"។
>
> *--អ្នកឆ្លើយសំណួរភេទស្រីម្នាក់ដែលបានរៀបរាប់ពីរបៀបដែលអ្នកស្រីត្រូវបានប្រធានក្រុមរបស់ខ្លួន និងមនុស្សបីនាក់ផ្សេងទៀតរំលោភសេពសន្ថវៈ*

នៅក្នុងករណីមួយទៀត អ្នកឆ្លើយសំណួរភេទស្រីម្នាក់នៅខេត្តបាត់ដំបង ដែលបានធ្វើការជាអ្នកដឹកជញ្ជូនស្រូវនៅក្នុងរបបនោះ បានរៀបរាប់អំពីការចាប់រំលោភស្ត្រីវ័យក្មេងម្នាក់ ដែលគាត់បានធ្វើការជាមួយគ្នា។ នៅពេលអ្នកស្រីបានឃើញកម្មាភិបាលខ្មែរក្រហមពីរ ឬបីនាក់បាននាំនាងម្នាក់នោះទៅឆ្ងាយ។ អ្នកស្រីបានរាយការណ៍ថា អ្នកស្រី និងអ្នកផ្សេងទៀតបានតាមទៅមើលនិងបាន

[៨១] ក្រមាគឺជាសំពត់អំបោះតាមប្រពៃណី ជាធម្មតាគេត្បាញក្នុងលក្ខណៈក្រឡាខ្វែង។ ក្រមានេះស្លៀកក៏បានប្រើប្រាស់ ផ្សេងទៀតក៏បាននៅតាមគ្រួសារនីមួយៗ ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ក្រមាជាផ្នែកមួយនៃឯកសណ្ឋានដែល របបនេះតម្រូវប្រើសម្រាប់ទាំងទាហាន និងជនស៊ីវិល។

ឃើញគេរំលោភសេពសន្ថវៈនាងម្នាក់នោះ ហើយសម្លាប់ចោល។ នៅពេលដែលមនុស្សពីរនាក់ក្នុងចំណោមអ្នកផ្សេងទៀតដែលបានឃើញការរំលោភសេពសន្ថវៈនោះ ត្រូវបានចាប់ខ្លួន ខណៈពេលកំពុងព្យាយាមចាកចេញពីកន្លែងកើតហេតុ ពួកគេក៏ត្រូវបានគេសម្លាប់ចោលហើយ កប់នៅក្នុងផ្នូរតែមួយជាមួយនឹងជនរងគ្រោះដោយការរំលោភសេពសន្ថវៈនោះ។

អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍អំពីហេតុការណ៍នៃការរំលោភជាក្រុម ដែលគេបានប្រព្រឹត្តមកលើគ្រួសារ និងនៅក្នុងការធ្វើការបោសសម្អាតមនុស្ស និងជនជាតិវៀតណាម។ នៅគ្រប់ករណីដែលត្រូវបានរាយការណ៍អំពីការរំលោភជាក្រុម នៅក្នុងការសិក្សានេះ ជនរងគ្រោះត្រូវបានសម្លាប់បន្ទាប់ពីរំលោភរួច។ របាយការណ៍ពីក្នុងចំណោមរបាយការណ៍ទាំងនេះត្រូវបានធ្វើឡើងក្នុងអំឡុងពេលដែលអ្នកឆ្លើយសំណួរជាច្រើនហៅថា"ភាពចលាចល" នៃថ្ងៃចុះខ្សោយនៃរបបនេះ។ នៅក្នុងករណីមួយ អ្នកឆ្លើយសំណួរបានរៀបរាប់ថា "នៅកន្លែងមួយចំនួនដែល (កងកម្លាំងខ្មែរក្រហម និងវៀតណាម) មិនទាន់បានប្រយុទ្ធគ្នាមុនដំបូងពួកគេរំលោភសេពសន្ថវៈ បន្ទាប់មកសម្លាប់ចោល។ ក្មេងៗភាគច្រើនគឺជា...ក្មេងស្រីស្អាតៗ។"គាត់បានបន្តរៀបរាប់អំពីអ្វីដែលគាត់បានឃើញហេតុការណ៍ដូចគ្នាយ៉ាងហោចណាស់ប្រាំដង រហូតដល់របបនេះចប់។ ការសម្លាប់ដែលកម្មាភិបាល ខ្មែរក្រហមវ័យក្មេងបានធ្វើនេះបានកើតឡើងដដែលៗជារៀងរាល់ថ្ងៃ ចាប់ផ្តើមឡើងនៅម៉ោងពារសៀល។ "បុរសត្រូវបានសម្លាប់ជាជួរៗប៉ុន្តែស្ត្រីដែលស្លៀកតែខោខ្លីត្រូវបាននាំចេញពីជួរនោះ ហើយនាំមកវិញ(បន្ទាប់ពីរំលោភរួច)។"

> "ខ្ញុំបានឃើញរឿងនេះច្រើនលើកច្រើនសាមកហើយនៅភ្នំបាណន់។ នៅឆ្នាំ១៩៧៥ ស្ត្រីស្រស់ស្អាតម្នាក់ត្រូវបានគេនាំមករំលោភនៅទីនោះ រួចសម្លាប់ចោល។"
>
> *--អ្នកឆ្លើយសំណួរភេទប្រុសម្នាក់ដែលបានរៀបរាប់អំពីការរំលោភសេពសន្ថវៈជាក្រុម រួចសម្លាប់ចោល នៅក្នុងខេត្តបាត់ដំបង*

នៅក្នុងការរំលោភសេពសន្ថវៈជាក្រុមមួយផ្សេងទៀតនៅក្នុងខេត្តបាត់ដំបង អ្នកឆ្លើយសំណួររាយការណ៍ថាបានទទួលរងការរំលោភសេពសន្ថវៈ និងការសម្លាប់គ្រួសារទាំងមូល ដោយចៃដន្យនៅពេលដែលនាងបានទៅដងទឹកត្រពាំងក្នុងមូលដ្ឋាន។ "ខ្ញុំបានឮមុនពេលពួកគេស្លាប់ថា ពួកគេបានព្យាយាមសុំអង្វរទាហានទាំងនោះកុំឲ្យសម្លាប់ពួកគេ។ ខ្ញុំបានឮស្ត្រីម្នាក់នោះ ស្រែយំនិង អង្វរថា "កុំរំលោភខ្ញុំអី"។" នៅពេលត្រឡប់មកកន្លែងវិញ គាត់បានឃើញសាកសពទាំងអស់នៅក្នុងរណ្តៅសពរួម ហើយខ្ញុំរន្ធត់ណាស់ ដែលឃើញស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំងនេះមានផ្ទៃពោះ នៅពេលរំលោភនិងសម្លាប់។ អ្នកឆ្លើយសំណួរភេទប្រុសម្នាក់ មកពីខេត្តបាត់ដំបងក៏បានរាយការណ៍ថា បានឃើញការរំលោភសេពសន្ថវៈស្ត្រីមួយក្រុមដែលជាប្រពន្ធរបស់ អតីតទាហាន និង មន្ត្រី លន់ នល់ នៅចុងឆ្នាំ១៩៧៥។ "ពួកគេយកតែកូន និងប្រពន្ធរបស់ទាហានប៉ុណ្ណោះ ហើយខ្ញុំបានមើលអ្វីដែល

ពួកគេបានធ្វើយ៉ាងហោច១៥នាទី...ពួកគេបានឃើញខ្ញុំ (ពីចម្ងាយ) និង ស្រែកគំហកដាក់ខ្ញុំ ប៉ុន្តែខ្ញុំនិយាយថា ខ្ញុំកំពុងបត់ជើងតូច។"

ព្រឹត្តិការណ៍ស្រដៀងគ្នាជាច្រើនត្រូវបានរាយការណ៍ថា បានកើតឡើងក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយអ្នកឆ្លើយសំណួរដែលត្រូវបានជម្លៀសទៅខេត្តពោធិ៍សាត់ និងព្រៃវែង។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់ ដែលបានវិលត្រឡប់ទៅស្រុកកំណើតរបស់អ្នកស្រីនៅខេត្តស្វាយរៀងពីតំបន់រំដោះ ទៅភាគខាងលិចជាមួយជនរងគ្រោះផ្សេងទៀត បានចងចាំថា បានជួបម្តាយ និងកូនរបស់គាត់ដោយចៃដន្យនៅជិតវត្តមួយនៅខេត្តពោធិ៍សាត់។ អ្នកស្រី និង អ្នកផ្សេងទៀតត្រូវបានខ្មែរក្រហមចាប់ខ្លួនម្តងទៀតនៅទីនោះ ហើយបានឃើញស្ត្រីម្នាក់នេះកំពុងត្រូវគេរំលោភ និងកូនស្រីរបស់គាត់ក៏ត្រូវបានពួកគេទាញចូលក្នុងព្រៃ ជាទីដែលអ្នកស្រី ជឿថា ពួកគេក៏ត្រូវរំលោភ ហើយសម្លាប់ចោល។

### ៥.២.២.៣ការរំលោភសេពសន្ថវៈនៅក្នុងកន្លែងធ្វើការនិងសហករណ៍របស់ខ្មែរក្រហម

អ្នកឆ្លើយសំណួរជាច្រើនបាននិយាយយោងទៅដល់ការរំលោភសេពសន្ថវៈ ដែលបានកើតឡើងនៅក្នុងមូលដ្ឋានខ្មែរក្រហម ដូចជា ពន្ធនាគារ ការិយាល័យស្រុក និងផ្ទះបាយក្នុងសហគមន៍។ ទោះបីជាកន្លែងទាំងនេះជាទីតាំងដែលគណនេយ្យភាពស្ថាប័នកម្រិតខ្ពស់ និងការប្រកាន់ខ្ជាប់នូវគោលនយោបាយប្រឆាំងនឹងអំពើហិង្សាលើយេនឌ័រ[៨២] ត្រូវបានរំពឹងទុកយ៉ាងណាក៏ដោយ ក៏របាយការណ៍ទាំងនេះបានលើកឡើងថា ផ្ទុយទៅវិញបានបង្ហាញតំបន់ដែលអាជ្ញាធរខ្មែរក្រហមកាន់តែមានសេរីភាព និងសិទ្ធិផ្ទាល់ខ្លួនក្នុងការធ្វើអ្វីៗតាមតែពួកគេចង់ធ្វើ។ កន្លែងទាំងនេះគឺជាទីតាំងដែលជនរងគ្រោះគ្មានអំណាចក្នុងការរត់គេចឬរកនរណាម្នាក់ជុំវិញខ្លួនឲ្យជួយនោះទេ។ អ្នកឆ្លើយសំណួរម្នាក់ ដែលបានធ្វើការជាអ្នកបើកបរ និងឆ្មាំគុកក្នុងរបបខ្មែរក្រហម បានរៀបរាប់ពីករណីមួយចំនួនពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈដោយកត់សម្គាល់ឃើញថា បុគ្គលិកពន្ធនាគារបានរំលោភសេពសន្ថវៈស្ត្រីនៅក្នុងពន្ធនាគារខាងក្រោយរាំងននចាស់មួយហើយ "នៅចំពោះមុខពួកយើង...ពួកគេរីករាយមែនទែន។" គាត់បានរំលឹកថា ជួនកាលការរំលោភសេពសន្ថវៈបានបន្តអស់រយៈពេល

> "ពួកគេបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈដោយបើកចំហនៅចំពោះមុខពួកយើង...ពួកគេសប្បាយចិត្តណាស់។"
>
> *--អ្នកឆ្លើយសំណួរភេទប្រុសមកពីខេត្តបាត់ដំបងបានរៀបរាប់អំពីការចាប់ រំលោភស្ត្រីជាច្រើន ដែលគាត់បានឃើញ ខណៈពេលដែលជាប់ពន្ធនាគារនៅក្នុងមណ្ឌលសន្តិសុខ មូលដ្ឋានមួយ*

[៨២] ជាការពិតណាស់ ពាក្យថា អំពើហិង្សាលើយេនឌ័រមិនត្រូវបានប្រើនៅសម័យខ្មែរក្រហមនោះទេ។ ប៉ុន្តែ ដូចដែលបានពិភាក្សានៅក្នុងផ្នែកបន្ទាប់អំពី "កំហុសផ្នែកសីលធម៌"ដែលយ៉ាងហោចណាស់ របបនេះបានហាមឃាត់ការទំនាក់ទំនងផ្លូវភេទណាមួយក្រៅចំណងអាពាហ៍ពិពាហ៍ដែលរបបនេះបានទទួលស្គាល់ ឬដាក់ទណ្ឌកម្ម។

យូរ និងបានកត់សម្គាល់ដោយក្តីរន្ធត់ថា ជនរំលោភសេពសន្ថវៈទាំងនោះដូចជាមិនមានអារម្មណ៍ខ្មាសអៀនចំពោះទង្វើរបស់ពួកគេនោះទេ។

នៅក្នុងសហគមន៍ផ្សេងទៀត អ្នកឆ្លើយសំណួរ៥នាក់បានរៀបរាប់អំពីហេតុការណ៍ដូចគ្នាទាក់ទងនឹងស្ត្រីវ័យក្មេងជាច្រើន ដែលត្រូវបានចាត់តាំងឲ្យធ្វើការឲ្យគណៈស្រុក ហើយត្រូវបាន ថៅគណៈស្រុកនោះរំលោភសេពសន្ថវៈនៅការិយាល័យស្រុករហូតដល់មានផ្ទៃពោះ។ នៅទីបញ្ចប់ជនរងគ្រោះទាំងបីនាក់ត្រូវបានប្រទះឃើញថាស្លាប់នៅក្នុងវត្តមួយនៃមូលដ្ឋាននោះ។ សាច់ញាតិម្នាក់របស់ជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះទាំងនេះបានរៀបរាប់ "បងប្អូនជីដូនមួយដ៏ស្រស់ស្អាតរបស់គាត់ដែលត្រូវបានគេនាំមកធ្វើការនៅជិតគណៈស្រុក។ ពួកគេបាននិយាយថា ពួកគេបាននាំនាងទៅធ្វើការ និងបម្រើពួកគេ។ តែតាមការពិតពួកគេបានរួមភេទជាមួយនាងរហូតដល់នាងមានផ្ទៃពោះ។ ពួកគេបានសម្លាប់នាង។ នាងផឹកថ្នាំពុល ហើយក៏ស្លាប់បាត់ទៅ។ ពួកគេបានរាយការណ៍ នាងពុលអាហារ តែតាមពិតនាងត្រូវគេសម្លាប់សោះ។"

ស្ត្រីម្នាក់ដែលបានដឹកនាំកងចល័តមួយ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបានរំលឹកថា សមាជិកម្នាក់ក្នុងចំណោមសមាជិកក្រុមការងាររបស់គាត់ដែលជាប់ពន្ធនាគារ បានប្រាប់គាត់ថា ស្ត្រីមិនថាក្មេង ឬចាស់នោះទេសុទ្ធតែត្រូវឆ្មាំគុកដែលធ្វើការនៅទីនោះរំលោភនៅក្នុងពន្ធនាគារនេះ។ អ្នកឆ្លើយសំណួរដដែលនោះក៏បានរាយការណ៍ថា ឆ្មាំគុកម្នាក់ទៀតដែលធ្វើការនៅទីនោះបានប្រាប់គាត់ថា "ទាហានអាចរំលោភសេពសន្ថវៈនារីតាមតែពួកគេចង់" ហើយ "ពួកគេ មិនខ្វល់អ្វីនោះទេ។" លើសពីនេះទៅទៀត អ្នកឆ្លើយសំណួរភេទស្រីម្នាក់មកពីខេត្តស្វាយរៀងបានរាយការណ៍ថា ក្មួយប្រុសរបស់គាត់បានឃើញគេបង្ខំឲ្យបង/ប្អូនស្រីពីរនាក់របស់វាស្រាតខោអាវ រួចរំលោភបំពានផ្លូវភេទដែលវាបានឃើញពីលើដើមស្វាយមួយដើមនៅជិតមណ្ឌលសន្តិសុខមូល ដ្ឋាន។ គាត់បានរំលឹក ដល់កាលដែលគាត់ត្រឡប់ទៅជាមួយក្មួយប្រុសដើម្បីរកមើលបង/ប្អូនស្រីទាំងពីរដែលត្រូវបុគ្គលិកពន្ធនាគារ ចាប់រំលោភប្ញក។

> "ប្តីរបស់គាត់បានឡើងលើពំនូកចំបើង ហើយបានស្តាប់ឮនៅពេលដែលប្រពន្ធរបស់ខ្លួនបានសុំអង្វរពួកទាហានកុំឲ្យរំលោភសេពសន្ថវៈ។ គ្មាននរណាម្នាក់ហ៊ាននិយាយ ឬធ្វើអ្វីមួយ ដើម្បីជួយនាងទេ...ពួកគេខ្លាចគេយកទៅសម្លាប់ចោល។ នៅពេលដែលខ្ញុំបានជួបនាងនៅពេលព្រឹក នាងស្រែកយំយ៉ាងខ្លាំង។"
>
> *--អ្នកឆ្លើយសំណួរភេទស្រីបានរៀបរាប់ពីការរំលោភសេពសន្ថវៈអ្នកជិតខាងរបស់គាត់នៅខេត្តបាត់ដំបង*

អ្នកឆ្លើយសំណួរជាច្រើនបានរៀបរាប់អំពីការរំលោភសេពសន្ថវៈ ដែលបានកើតឡើងនៅពេលដែលមានឱកាសរៀបរាប់អំពីស្ថានភាពនៅក្នុងសហករណ៍ ដូចជានៅពេលដែលកំពុងងូតទឹក ឬចេញដើរខាងក្រៅផ្ទះពេលយប់ដើម្បីបន្ធូរអារម្មណ៍។ អ្នកឆ្លើយសំណួរម្នាក់រាយការណ៍ថា បានឃើញស្ត្រីមូលដ្ឋានម្នាក់ត្រូវគេរំលោភសេពសន្ថវៈនៅថ្ងៃពេញបូណ៌មី៖ "នៅពេលដែលខ្ញុំកំពុងបត់ជើងតូចស្រាប់

តែឃើញឈ្លបខ្មែរក្រហម កំពុងរំលោភសេពសន្ថវៈស្ត្រីនៅកណ្តាលវាលស្រែ។ ខ្ញុំបានឮសម្លេងស្រែកយ៉ាងគ្រលួច ពេលនោះខ្ញុំក៏បានរត់ចេញពីកន្លែងនោះ ពីព្រោះប្រសិនបើពួកគេដឹងថា ខ្ញុំបានឃើញពួកគេ ពួកគេមុខជាសម្លាប់ខ្ញុំចោលមិនខាន។”

អ្នកឆ្លើយសំណួរជាច្រើនក៏បានរៀបរាប់អំពីករណីមួយចំនួន ដែលជនរំលោភសេពសន្ថវៈនោះបានចាប់រំលោភស្ត្រីម្នាក់នៅចំពោះមុខប្តីនាង ឬសមាជិកគ្រួសារផ្សេងទៀត សូម្បីនៅពេលដែលការរំលោភសេពសន្ថវៈត្រូវបានរាយការណ៍ទៅថ្នាក់លើក៏ដោយក៏នៅតែមានការលើកលែងដែរ។ អ្នកឆ្លើយសំណួរពីរនាក់នៅខេត្តស្វាយរៀងបានរាយការណ៍ដោយឯករាជ្យអំពីករណីដែលគេដឹងច្រើន នៅក្នុងភូមិរបស់ពួកគេដែលមានឈ្លបខ្មែរក្រហម ដែលបានទៅផ្ទះប្តីប្រពន្ធពីរនាក់ហើយដេក នៅជាន់លើជាមួយប្រពន្ធ នោះ ខណៈពេលដែលប្តីនោះកំពុងលង់លក់នៅលើកន្ទេលក្រោមផ្ទះ។នៅក្នុងករណីនេះអ្នកឆ្លើយសំណួរជាច្រើនបានកត់សម្គាល់ថា“ប្តីនោះបានឃើញផ្ទាល់នឹងភ្នែកថា ប្រពន្ធរបស់ខ្លួនត្រូវគេបង្ខំឲ្យរួមភេទជាមួយឈ្លប” ហើយបានរាយការណ៍អំពីស្ថានភាពទៅប្រធានមូលដ្ឋាន។ អ្នកឆ្លើយសំណួរចងចាំថា “កិច្ចប្រជុំវិនិច្ឆ័យ” ត្រូវបានរៀបចំនៅក្នុងផ្ទះបាយសហគមន៍ ភ្លាមនោះបន្ទាប់ពីអ្នកភូមិទាំងមូលបានដឹងពីស្ថានភាពនោះ ប៉ុន្តែទីបញ្ចប់អ្នកដែលពាក់ព័ន្ធ ទាំងនោះមិនត្រូវបានដាក់ទោសឡើយ។

អ្នកឆ្លើយសំណួរជាច្រើនបានគូសបញ្ជាក់ថា ស្ត្រីរៀបការរួច ហើយនៅម្នាក់ឯងក្នុងសហករណ៍ងាយរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ ពីព្រោះប្តីរបស់ពួកគាត់ត្រូវបានបញ្ជាឲ្យទៅធ្វើការនៅក្នុងក្រុមចល័តបានស្លាប់ ឬត្រូវគេសម្លាប់។ អ្នកឆ្លើយសំណួរមួយចំនួនបានលើកឡើងថា ប្រធានមូលដ្ឋានមានចេតនាបញ្ជូនបុរសឲ្យទៅឆ្ងាយ ដើម្បីងាយស្រួលក្នុងការទៅរកប្រពន្ធរបស់គេ។នៅក្នុងករណីមួយទៀត អ្នកឆ្លើយសំណួរភេទប្រុសម្នាក់ មកពីខេត្តបាត់ដំបងបានរាយការណ៍ថា “គាត់ធ្លាប់ឮថា មេទាហានបានបង្ខំឲ្យបុរសទាំងនោះចេញទៅមុន បន្ទាប់មករួមភេទជាមួយប្រពន្ធរបស់គេ”ហើយគាត់បានរំលោភសេពសន្ថវៈ “ស្ត្រីជាច្រើន”។ អ្នកឆ្លើយសំណួរភេទប្រុសម្នាក់ទៀត ជាអតីតមេភូមិម្នាក់ ក្រោមរបបខ្មែរក្រហមបានរំលឹកដល់រឿងរបស់ស្ត្រីរៀបការវ័យក្មេងម្នាក់ ដែលប្តីទាហានរបស់ខ្លួនត្រូវបានបញ្ជូនទៅឆ្ងាយ។ ក្រោយមកនៅពេលដែលគេឃើញនាងមានផ្ទៃពោះជាមួយមន្ត្រីខ្មែរក្រហមមូលដ្ឋាន នាងត្រូវគេសម្លាប់ចោល។ នៅក្នុងករណីមួយផ្សេងទៀត ប្តីរបស់ជនរងគ្រោះបានប្តឹងនៅក្នុងកិច្ចប្រជុំសាធារណៈ អំពីការដែលប្រធានសហករណ៍រំលោភសេពសន្ថវៈប្រពន្ធរបស់គាត់នៅពេលដែលគាត់នៅឆ្ងាយ ប៉ុន្តែវាមិនច្បាស់ថា តើការប្តឹងរបស់គាត់នាំឲ្យមានការផ្តន្ទាទោសជនដៃដល់ ឬយ៉ាងណាទេ។

អ្នកឆ្លើយសំណួរផ្សេងទៀតបានកត់សម្គាល់អំពីភាពងាយរងគ្រោះរបស់ស្ត្រីវ័យក្មេង ដែលបានធ្វើការនៅក្នុងក្រុមចល័ត ឬនៅឆ្ងាយពីភូមិ។ នៅក្នុងករណីមួយនោះ អ្នកឆ្លើយសំណួរភេទស្រីម្នាក់នៅក្នុងខេត្តស្វាយរៀង ដែលត្រូវបានបញ្ជូនឲ្យឃ្វាលគោក្របីជាមួយយុវជនផ្សេងទៀត បាននឹកឃើញដល់ពេលដែលគាត់បានឃើញស្ត្រីម្នាក់ត្រូវទាហានខ្មែរក្រហមពីរនាក់ដេញចាប់។ គាត់និងបងស្រីរបស់គាត់ឃ្លាំមើល នៅពេលដែលស្ត្រីនោះជំពប់ជើងដួលទៅលើដី ហើយ ត្រូវទាហាននោះចាប់បាន រួចចងនឹងក្រមា ហើយរំលោភនៅកណ្ដាលវាលតែម្ដង។ ពេលរំលោភរួច គាត់ចាំថាពួកគេបានសម្លាប់ក្មេងស្រីនោះនឹងពូថៅ ហើយក្រោយមកមនុស្សជាច្រើនបាន ឃើញសាកសពរបស់នាង មុនពេល "អង្គការយកចេញទៅ។"

នៅក្នុងករណីមួយទៀត អ្នកឆ្លើយសំណួរភេទស្រីម្នាក់មកពីខេត្តស្វាយរៀងបានប្រាប់អ្នកសម្ភាសន៍ថា គាត់អាចចាំបានថា នៅពេលដែលគាត់ដើរកាត់វាលល្ហឹងល្ហើយ គាត់គិតថាខ្មោចហៅគាត់ នៅពេលនោះគាត់ឮគេហៅឈ្មោះគាត់។ ផ្ទុយទៅវិញគាត់បានឃើញមិត្តភក្ដិមកពីក្រុមការងាររបស់គាត់កំពុងសម្រាកនៅក្នុងរណ្ដៅរាក់មួយ ដែលមួយផ្នែកនៃរណ្ដៅនោះគ្របដោយស្លឹកត្នោត។ ពេលនោះមិត្តភក្ដិម្នាក់នោះមានរបួសស្នាចេញឈាម រយៈយ៉ាងជ្រៅ។ ជនរងគ្រោះបានប្រាប់អ្នកឆ្លើយសំណួរថា "ប្រធានអង្គភាពបានហៅខ្ញុំមកធ្វើការ ប៉ុន្តែតាមពិតទៅ គាត់ហៅខ្ញុំមករំលោភសោះ។ បន្ទាប់ពីរំលោភរួច គាត់យកខ្ញុំមកសម្លាប់ចោលនៅទីនេះ។ ពួកគេរំលោភខ្ញុំបែបនេះ។" ជាង៣០ឆ្នាំក្រោយមក អ្នកឆ្លើយសំណួរបានរាយការណ៍ថា ហេតុការណ៍នោះតែងតែនៅជិតជាប់ក្នុងអារម្មណ៍ខ្ញុំជានិច្ច ដែលកាលណោះគាត់មិនអាចជួយមិត្តភក្ដិរបស់គាត់បាន ហើយមួយថ្ងៃក្រោយមក នៅពេលដែលគាត់ត្រឡប់ទៅរកមើលមិត្តភក្ដិនោះ ស្រាប់តែជនរងគ្រោះបានបាត់ខ្លួនទៅហើយ។

### ៥.២.២.៤ ការរំលោភសេពសន្ថវៈដោយប្រើឧបករណ៍ណាមួយ

ដូចដែលបានកត់សម្គាល់នៅដើមផ្នែកនេះ និយមន័យអំពីការរំលោភសេពសន្ថវៈ ដែលត្រូវបានប្រើនៅក្នុងច្បាប់អន្តរជាតិ បានបញ្ចូលមិនត្រឹមតែអំពើរំលោភសេពសន្ថវៈ ដែលត្រូវបានប្រព្រឹត្តតាមរយៈ ការដាក់ចូលអង្គជាតិទៅលើជនរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដាក់បញ្ចូលដោយឧបករណ៍ណាមួយ។ អ្នកឆ្លើយសំណួរច្រើនជាងម្នាក់ក្នុងចំណោមអ្នកឆ្លើយសំណួរ១០នាក់ (១២.៥%) រាយការណ៍ថា បានដឹងអំពីទម្រង់នៃការរំលោភសេពសន្ថវៈនេះ ចំណែកឯជាងពាក់កណ្ដាលទៀត(៦.៧%)រាយការណ៍ថាបានឃើញដោយផ្ទាល់ភ្នែកនូវសាកសពដែលមានវត្ថុផ្សេងៗនៅជាប់ប្រដាប់ភេទរបស់ពួកគេ។

# របកគំហើញ

របាយការណ៍នៅក្នុងការសិក្សានេះ ដែលពាក់ព័ន្ធជាទូទៅបំផុតទៅនឹងសាកសពដែលត្រូវគេកាត់ ឬអារប្រដាប់ភេទនឹងឫស្សី ឬមែកឈើ។ របាយការណ៍ស្តីពីការរំលោភដោយប្រើឧបករណ៍នៅក្នុងការសិក្សានេះ តែងតែមានទំនាក់ទំនងនឹងការសម្លាប់ជនរងគ្រោះ។ នៅគ្រប់ករណីដែលត្រូវបានរាយការណ៍ដោយសាក្សីផ្ទាល់ ពួកគេបានជួបប្រទះជនរងគ្រោះម្នាក់ដោយចៃដន្យ នៅពេលនោះគាត់ស្លាប់បាត់ទៅហើយ។ ប៉ុន្តែអ្នកឆ្លើយសំណួរភេទស្រីម្នាក់បានរាយការណ៍ថា គាត់បានឮពីអ្នកផ្សេងទៀតថា ស្ត្រីរងគ្រោះត្រូវបានរំលោភដោយភ្នាក់ងារខ្មែរក្រហម "ដោយយកកាំបិតមុខស្រួចទៅចាក់ប្រដាប់ភេទរបស់ស្ត្រី។ បន្ទាប់មកពួកគេសួរថា មានអារម្មណ៍ស្រួលអត់។ ប្រសិនបើមិនស្រួលពួកគេនឹងចាក់ឲ្យជ្រៅថែមទៀត។"

អ្នកឆ្លើយសំណួរភេទប្រុសនៅខេត្តបាត់ដំបង បានរៀបរាប់អំពីការជីករណ្តៅសាកសពជាមួយអ្នកភូមិ ជាមួយគ្នា បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ និងរកឃើញថា "ខ្មែរក្រហមបានយកឈើចាក់ក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ... ឃើញបែបនេះយើងមានអារម្មណ៍អាណិតអ្នកដែលស្លាប់ទៅណាស់។" អ្នកឆ្លើយសំណួរដែលនៅជាព្រះសង្ឃនៅខេត្តបាត់ដំបងកាលពីដើមឆ្នាំ១៩៧៦ ចាំថាបានជួបទាហានខ្មែរក្រហម មួយក្រុមដោយចៃដន្យនៅតាមផ្លូវនៅក្បែរនឹងជួរសាកសពទាំងនោះដែរ។ គាត់ថាគាត់មានការរន្ធត់យ៉ាងខ្លាំងនៅពេលដែលបានឃើញទាហានទាំងនេះយកមែកដើមក្រូចមកចាក់ទ្វារមាសរបស់សាកសពស្ត្រី។

> "ពួកគេបានយកស្នូកកាំភ្លើងវាយកំប៉េះគូទស្ត្រី ហើយជួនកាល ពួកគេយកកាំភ្លើង នោះញាត់ចូលរន្ធគូទស្ត្រី រហូតដល់ស្លាប់ក៏មានដែរ។"
>
> *--ស្ត្រីបានរាយការណ៍អំពីអ្វីដែលគាត់បានឃើញនៅពេលជាប់ពន្ធនាគារក្នុងរបបខ្មែរក្រហម*

លើសពីនេះទៅទៀត អ្នកឆ្លើយសំណួរភេទស្រីម្នាក់ត្រូវបានផ្តាំគុកប្រាប់អំពីរបៀបដែលអ្នកទោសភេទស្រីវ័យក្មេងម្នាក់ត្រូវបានសម្លាប់ដោយយកត្បូងចបវាយទ្វារមាសរបស់នាង។ នៅពេលដែលអ្នកឆ្លើយសំណួរប្រទះឃើញសាកសពនោះដោយចៃដន្យ គាត់បានរៀបរាប់ពីការឃើញជនរងគ្រោះ៖ "ឈាមជោគសំពត់របស់នាង។ មេយភ្លៀងជោគដីលាយឡំទៅដោយពណ៌ឈាមរបស់នាង។" អ្នកឆ្លើយសំណួរភេទប្រុសម្នាក់ទៀតមកពីខេត្តបាត់ដំបងបានរាយការណ៍ថា បានឃើញសាកសពស្រាតននលគកមួយគំនរ៖ "សាកសពទាំងនោះគ្មានសម្លៀកបំពាក់ទេ មើលទៅដូចដើមចេកអញ្ចឹង។ គេដាក់ឲ្យបុរស និងស្ត្រីនៅដាច់ដោយឡែកពីគ្នា... ស្ត្រីមិនត្រឹមតែត្រូវខ្មែរក្រហមសម្លាប់នោះទេ ប៉ុន្តែថែមទាំងត្រូវពួកគេយកដំបងឈើបុកចូលក្នុងប្រដាប់ភេទរបស់ស្ត្រី...ខ្ញុំពិតជាមានអារម្មណ៍ព្រឺព្រួច និងរន្ធត់ញាប់ញ័រមែនទែន។"

### ៥.២.២.៥ ការរំលោភសេពសន្ថវៈដោយការកេងប្រវ័ញ្ចផ្លូវភេទ និងទាសភាពផ្លូវភេទ

អ្នកឆ្លើយសំណួរជិតពាក់កណ្តាល ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់(៤៦%) រាយការណ៍ថា បានដឹងអំពីការកេងប្រវ័ញ្ចផ្លូវភេទ ឬទាសភាពផ្លូវភេទរួមមាន ២០.២% ជាសាក្សីផ្ទាល់។ គោលគំនិតនៃការកេងប្រវ័ញ្ចផ្លូវភេទមាននៅក្នុងនិយមន័យនៃពាក្យរំលោភសេពសន្ថវៈ ដូចបានរៀបរាប់ខាងលើមានជាអាទិ៍ការរំលោភដែលបានរៀបរាប់នៅក្នុងនិយមន័យ។ ភាពខុសគ្នាដែលអ្នកឆ្លើយសំណួរបានលើកឡើងដើម្បីរៀបរាប់អំពីទង្វើទាំងនេះដោយប្រៀបធៀបនឹងការរំលោភសេពសន្ថវៈផ្សេងទៀត ដែលត្រូវបានរាយការណ៍នៅទីនេះគឺជាការបង្ខិតបង្ខំការកៀបសង្កត់ ឬការប្រើអំណាចជំនួសកម្លាំងកាយដែលត្រូវជនដៃដល់ប្រើដើម្បីរំលោភឲ្យបានសម្រេច។ ដូចដែលអ្នកឆ្លើយសំណួរបានរៀបរាប់នៅទីនេះអញ្ចឹង ជនរងគ្រោះនៅក្នុងករណីទាំងនេះ គ្មានជម្រើសអ្វីក្រៅពីបំពេញបំណងរបស់ជនដៃដល់នោះទេ។ ពួកគេត្រូវបានបង្ខំឲ្យធ្វើបែបនោះជាចាំបាច់ ហើយការធ្វើបែបនេះគឺដើម្បីរស់ប៉ុណ្ណោះ។ ពួកគេបានទទួលរងនូវស្ថានភាពបង្អត់អាហារ ជម្ងឺ ការធ្វើការហួសកម្រិត អំពើហិង្សា និងការកាប់សម្លាប់សព្វបែបយ៉ាងនៅក្នុងរបបនេះ។

> "ខ្ញុំមិនប្រាកដថា គាត់មានស្ត្រីប៉ុន្មាននាក់នោះទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា ស្ត្រីទាំងនោះ មិនចង់ធ្វើអញ្ចឹងទេ ពួកគេធ្វើនេះគឺដើម្បីជួយសង្គ្រោះជីវិតរបស់ពួកគេប៉ុណ្ណោះ។"
>
> *--អ្នកឆ្លើយសំណួរភេទស្រីនៅខេត្តស្វាយរៀង បានរៀបរាប់ថា ស្ត្រីគ្មានសមត្ថភាពតវ៉ាប្រឆាំងនឹងការរំលោភសេពសន្ថវៈរបស់មន្ត្រីខ្មែរក្រហមមូលដ្ឋាននោះទេ*

អ្នកឆ្លើយសំណួរភេទស្រីម្នាក់នៅខេត្តបាត់ដំបង បានរាយការណ៍ថា បងប្អូនជីដូនមួយរបស់គាត់ដែលបានរៀបការ ហើយមានកូនបីនាក់នៅពេលនោះបានរួមភេទជាមួយមេទាហានមូលដ្ឋាន ដោយមេទាហាននោះផ្តល់អាហារបាយបន្ថែម និងរបស់របរចាំបាច់ផ្សេងទៀតដល់នាង។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់ទៀតបានរាយការណ៍ថា ស្ត្រីម្នាក់ដែលគាត់បានធ្វើការជាមួយបានប្រាប់គាត់ថា នាងយល់ព្រមរួមភេទជាមួយប្រធានក្រុមការងារ ដើម្បីបានអាហារបន្ថែម។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់ទៀតមកពីខេត្តស្វាយរៀងបានរៀបរាប់ថា គាត់បានដឹងថា ស្ត្រីប្រធានក្រុមរបស់គាត់បានរួមភេទជាមួយបុរសថ្នាក់លើម្នាក់ ដើម្បីទទួលបានអាហារឆ្ងាញ់។ អ្នកឆ្លើយសំណួរភេទស្រីដែលមានវ័យ ៧០ឆ្នាំបានរំលឹកថា គាត់បានប្រទះឃើញអនុប្រធានផ្ទះបាយសហករណ៍ដោយចៃដន្យ ខណៈពេលដែលគាត់កំពុងតែរួមភេទជាមួយស្ត្រីរៀបការវ័យក្មេងដែលប្តីរបស់នាងត្រូវបានបញ្ជូនទៅធ្វើការនៅក្នុងក្រុមចល័ត។ ស្ត្រីម្នាក់នេះក៏បានរៀបរាប់ផងដែរថា ស្ត្រីវ័យក្មេងនោះក៏បានទទួលអាហារបន្ថែមដែរ។

អ្នកឆ្លើយសំណួរភេទប្រុសម្នាក់បានរៀបរាប់ពីរបៀបដែលប្រពន្ធមិត្តភក្តិរបស់គាត់នៅក្នុងក្រុមការងារចល័តបានរួមភេទជាមួយប្រធានអង្គភាពជាថ្នូរនឹងអាហារ ដែលនាងបានចែកឲ្យប្តីរបស់

នាង។ គាត់ក៏បានកត់សម្គាល់ផងដែរថា ប្រធានអង្គភាពនេះមានទំនាក់ទំនងស្រដៀងគ្នាជាមួយស្ត្រីជាច្រើននៅក្នុងភូមិ។ អ្នកឆ្លើយសំណួរភេទប្រុសម្នាក់នៅខេត្តស្វាយរៀងបានរាយការណ៍ថា សាច់ញាតិម្នាក់ក្នុងចំណោមសាច់ញាតិស្ត្រីវ័យក្មេងរបស់គាត់បានរួមភេទជាមួយថ្នាក់ដឹកនាំដើម្បី "ឲ្យបានរស់រានមានជីវិត និងកុំឲ្យគេជម្លៀសទៅកន្លែងណាទៀត។" អ្នកឆ្លើយសំណួរ ភេទប្រុសទី៣ នៅខេត្តបាត់ដំបងបានចាំថា បានឮប្រធានក្រុមនៅក្នុងសហករណ៍របស់គាត់និយាយថា "គាត់ចង់បានស្រីណាក៏បាន...ហើយនិយាយទៀតថា ស្រីទាំងអស់មិនស្ទាក់ស្ទើរនឹងទៅជាមួយគាត់នោះទេ ពីព្រោះពួកគេឃ្លានបាយ។"

នៅក្នុងករណីមួយចំនួនដែលត្រូវបានរៀបរាប់នៅទីនេះ ជាពិសេសករណីដែលស្ត្រីត្រូវខ្មែរក្រហម "ឃុំខ្លួន"ទុកបម្រើផ្លូវភេទ ការរំលោភដែលស្ត្រីទាំងនេះបានទទួលរង ឬឆ្លងកាត់ក៏អាចត្រូវចាត់ថ្នាក់ជាទាសភាពផ្លូវភេទបានដែរ។ គេយល់ពាក្យទាសភាពផ្លូវភេទនេះនៅក្នុងច្បាប់អន្តរជាតិជាស្ថានភាពមួយដែល៖

> "ជនដៃដល់បានប្រើប្រាស់អំណាចណាមួយ ឬទាំងអស់ភ្ជាប់នឹងសិទ្ធិគ្រប់គ្រងលើបុគ្គលម្នាក់ ឬច្រើននាក់ ដូចជា តាមការទិញ លក់ ឲ្យខ្ចី ឬការដោះដូរ ដូចជាមនុស្សម្នាក់ ឬច្រើននាក់ ឬដោយការដកហូតសេរីភាពពីបុគ្គលម្នាក់ៗ" ហើយជនដៃដល់បានបណ្ដាលឲ្យបុគ្គលម្នាក់ ឬច្រើននាក់ចូលរួមក្នុងទង្វើមួយ ឬច្រើននៃការរួមភេទ។"[៨៣]

ឧទាហរណ៍ អ្នកឆ្លើយសំណួរភេទប្រុសម្នាក់នៅខេត្តបាត់ដំបងបានរៀបរាប់អំពីរបៀបដែលស្ត្រីមួយក្រុម ដែលក្នុងនោះមានបងប្អូនជីដូនរបស់គាត់ផងដែរ ត្រូវបានដាក់ឲ្យនៅក្នុងអគារមួយដាច់ពីគេនៅក្នុងសហករណ៍។ជាញឹកញាប់ប្រធានសហករណ៍ត្រូវបានគេប្រទះឃើញនៅកន្លែងដែលស្ត្រីទាំងនោះឃុំទុក។ ក្រោយមកប្អូនជីដូនមួយរបស់គាត់ប្រាប់គាត់ថា នាង និងស្ត្រីផ្សេងទៀតត្រូវបានគេយកទៅឲ្យរួមភេទជាមួយប្រធានសហករណ៍ ដែលបានឲ្យពួកគេទទួលទានអាហារជាថ្នូរវិញ។

### ៥.២.២.៦ ការប៉ុនប៉ងរំលោភសេពសន្ថវៈ

អ្នកឆ្លើយសំណួរបួននាក់បានរាយការណ៍ថា ពួកគេ ឬអ្នកផ្សេងទៀតរត់គេចចេញពីការរំលោភសេពសន្ថវៈបានតិចតួចប៉ុណ្ណោះក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់

[៨៣] Article 7(1)(g)-2, Crime Against Humanity of Sexual Slavery, Elements of Crimes, International Criminal Court បានចូលមើលថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១១ http://www.icc-cpi.int/NR/rdonlyres/336923D8-A6AD-40EC-AD7B-45BF9DE73D56/0/ElementsOfCrimesEng.pdf។ ទោះបីជាមាត្រាដែលត្រូវបានលើកឡើងនៅទីនេះ សំដៅចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈក៏ដោយ ក៏ធាតុផ្សំនៃបទល្មើសស្របគ្នាទៅនឹងការចាត់ថ្នាក់គ្រប់ប្រភេទនៃឧក្រិដ្ឋកម្មនេះ(ពោលគឺ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មសង្គ្រាម)។

មកពីខេត្តស្វាយរៀងបានរៀបរាប់អំពីរបៀបដែលក្រុមចល័តរបស់គាត់ត្រូវបានដាក់នៅក្នុងមូលដ្ឋាន ដើម្បីច្រូតស្រូវ រហូតដល់យប់ជ្រៅ នៅពេលនោះ កម្មាភិបាលខ្មែរក្រហមដែលគ្រប់គ្រងលើពួកគេ បានចាប់ច្បាមសក់របស់នាង ហើយព្យាយាមអូសនាងចូលក្នុងព្រៃសម្រាប់រំលោភសេពសន្ថវៈចំពោះ គាត់មុនពេលកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលផ្សេងទៀតបានបញ្ឈប់គាត់។ អ្នកឆ្លើយសំណួរ ភេទស្រីម្នាក់ទៀត បានរៀបរាប់ពីរឿងរ៉ាវរបស់គិលានុបដ្ឋាយិកាម្នាក់ ដែលរស់នៅក្នុងសហករណ៍ របស់គាត់ដែលបានវិលត្រឡប់ពីធ្វើការ មើលទៅសម្លៀកបំពាក់រហែករយ៉េរយ៉ៃ។ ស្ត្រីវ័យក្មេងនោះ បានប្រាប់ឪពុកម្តាយរបស់នាង និងគ្រួសារអ្នកឆ្លើយសំណួរថា កម្មាភិបាលខ្មែរក្រហមបានឲ្យនាងចុះ ពីលើកង់ និងព្យាយាមរំលោភនាង ប៉ុន្តែនាងបានរត់ទៅឆ្ងាយ។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់នៅ ខេត្តបាត់ដំបង បានរៀបរាប់អំពីរបៀបដែលមេឃុំ "បានកោះហៅបងប្អូនថ្លៃស្រីរបស់ខ្ញុំ និងបាន ព្យាយាមបង្ខំឲ្យនាងរួមភេទជាមួយគាត់ ប៉ុន្តែមិនបានសម្រេចនោះទេ ដោយសារតែបងប្រុសរបស់ ខ្ញុំទៅយកនាងមកវិញនៅពេលគាត់ទៅរកនាងមិនឃើញនៅផ្ទះ។" ទោះបីជាសម័យនោះនាងនៅ ក្មេងក៏ដោយ ក៏អ្នកឆ្លើយសំណួរភេទស្រីម្នាក់មកពីខេត្តស្វាយរៀងបានរៀបរាប់ពីរបៀបដែលឈ្លប ក្មេងម្នាក់បានចាប់ទាញអាវរបស់នាង ហើយគំរាមរំលោភនៅពេលដែលនាងយកអាហារទៅឲ្យ ឪពុករបស់នាងនៅឯពន្ធនាគារ។ នាងបានរត់គេចនៅពេលដែលឪពុករបស់នាងចាប់ផ្តើមវាយតប់ ជាមួយក្មេងប្រុសនោះហើយនាងក៏បានរត់ទៅឆ្ងាយ។

### ៥.២.២.៧ ការរំលោភសេពសន្ថវៈ និងការប៉ុនប៉ងរំលោភមកលើបុរស

ក្នុងអំឡុងពេលស្រាវជ្រាវនេះ អ្នកឆ្លើយសំណួរពីរនាក់បានលើកយកបញ្ហាអំពីការចាប់រំលោភ ដែលប្រធានក្រុមខ្មែរក្រហមភេទស្រី បានប្រព្រឹត្តមកលើបុរសវ័យក្មេងដែលពួកគេរ៉ាប់រង។ អ្នក ឆ្លើយសំណួរទីមួយជាបុរសមកពីខេត្តស្វាយរៀងបានរាយការណ៍ថា គាត់បានដឹងពីមិត្តភក្តិម្នាក់ ដែលស្ត្រីម្នាក់បានស្គាល់គាត់ជាប្រធានក្រុមនោះបានរំលោភក្មេងប្រុសម្នាក់។ "នៅពេលដែលក្មេង ប្រុសម្នាក់ក្នុងចំណោមក្មេងប្រុសជាច្រើននៅក្នុងក្រុមរបស់ស្ត្រីនោះវិលត្រឡប់មកវិញនៅពេលយប់ ស្ត្រីនោះបានបង្ខំឲ្យក្មេងប្រុសរួមភេទជាមួយខ្លួន ប៉ុន្តែដោយសារតែក្មេងនោះនៅក្មេងពេក មិនចេះ រួមភេទនោះទេ។ ក្មេងប្រុសនោះខ្លាចណាស់ ហើយគេក៏បានសម្លាប់វានៅព្រឹកស្អែកតែម្តង។" អ្នក ឆ្លើយសំណួរទីពីរមកពីខេត្តបាត់ដំបង បានរៀបរាប់ពីរបៀបដែលប្រធានក្រុមផ្ទាល់របស់គាត់បានប៉ះ ពាល់ គាត់ក្នុងលក្ខណៈគំរាមកំហែង និងសុំឲ្យគាត់ទៅប្រជុំនៅពេលយប់។ ទោះបីជាគាត់ធូរទ្រូង ដែលបានរួចផុតពីការរំលោភរបស់ស្ត្រីនោះក៏ដោយ ក៏គាត់បានរំលឹកថា នៅពេលដែលគាត់បដិសេធ ស្ត្រីម្នាក់នោះយំ និងគាត់បារម្ភថា ស្ត្រីម្នាក់នោះដាក់ទណ្ឌកម្មគាត់ ដោយរាយការណ៍ជូនទៅថ្នាក់លើ។

### ៥.២.២.៨ ការរំលោភសេពសន្ថវៈមុន និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

កម្រងសំណួរអង្កេតដែលគេយកមកប្រើដើម្បីធ្វើបទសម្ភាសន៍ស្រាវជ្រាវនៅក្នុងការសិក្សានេះបានសួរយ៉ាងច្បាស់លាស់អំពីសម័យកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី០៧ មករា ១៩៧៩។ ទោះជាយ៉ាងនោះក្តី អ្នកឆ្លើយសំណួរជាច្រើនបាននិយាយអំពីអំពើហិង្សាលើយេនឌ័រនៅក្នុងសម័យ លន់ នល់ មុនសម័យកម្ពុជាប្រជាធិបតេយ្យ ឬក្នុងអំឡុងពេលវៀតណាម "រំដោះ"កម្ពុជា។ នៅក្នុងករណីមួយនេះ អ្នកឆ្លើយសំណួរបានរាយការណ៍ថា មេដឹកនាំខ្មែរក្រហមតាមមូលដ្ឋានបានរំលោភសេពសន្ថវៈ និងបំពានលើស្ត្រីវ័យក្មេងដែលចាប់ផ្តើមមុនការដួលរលំនៃទីក្រុងភ្នំពេញ និងបន្តអស់រយៈពេលជាច្រើនឆ្នាំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកឆ្លើយសំណួរភេទស្រីវ័យចំណាស់ម្នាក់ដែលបានរស់នៅក្នុងតំបន់ដែលត្រួតត្រាដោយខ្មែរក្រហមកាលពីឆ្នាំ ១៩៧៤ បានរាយការណ៍ថា បានឃើញស្ត្រីវ័យក្មេងម្នាក់ត្រូវគេចងមុខ ហើយនាំចេញពីមណ្ឌលសន្តិសុខមូលដ្ឋាននៅពេលយប់។ គាត់រំលឹកថា ស្ត្រីវ័យក្មេងម្នាក់ដែលត្រូវបានឃុំខ្លួននៅឯមណ្ឌលនោះបានសារភាពថា គាត់ត្រូវបានគេនាំចេញពីក្រុមយកទៅរំលោភ ហើយនាំមកវិញ ប៉ុន្តែមិនព្រមប្រាប់អ្នកផ្សេងទៀត ដោយសារតែគាត់ជឿថា គាត់អាចត្រូវគេដាក់ទណ្ឌកម្មចំពោះការពាក់ព័ន្ធនេះ។ អ្នកឆ្លើយសំណួរម្នាក់ទៀតបាននិយាយយោងទៅដល់អំពើហិង្សាផ្លូវភេទមកលើស្ត្រី និងកុមារីដែលប្រព្រឹត្តដោយកងកម្លាំងវៀតណាម ដែលបានចូលក្នុងទឹកដីកម្ពុជានៅចុងឆ្នាំ ១៩៧៨ និងដើមឆ្នាំ១៩៧៩។

### ៥.២.៣ ការកាត់អវៈយវៈភេទ និងទារុណកម្មផ្លូវភេទ

សម្រាប់គោលបំណងនៃការសិក្សានេះ ការកាត់អវៈយវៈភេទសំដៅលើទង្វើណាមួយ ដែលបង្កឲ្យមានរបួសស្នាម ឬការបំផ្លាញប្រដាប់ភេទប្រដាប់បន្តពូជ សុដន់ ឬរន្ធគូទរបស់ជនរងគ្រោះ។ នៅក្នុងករណីខ្លះ ការកាត់អវៈយវៈភេទជនរងគ្រោះក៏អាចរាប់បញ្ចូលសកម្មភាពដាក់ទណ្ឌកម្មផ្លូវភេទ។ គេឈ្វេងយល់អំពីឧក្រិដ្ឋកម្មសង្គ្រាម(ចំពោះទារុណកម្ម)នៅក្នុងច្បាប់អន្តរជាតិនៅពេលដែល៖

១. ជនដៃដល់បង្កការឈឺចាប់ផ្លូវកាយ ឬផ្លូវចិត្តឬធ្វើឲ្យបុគ្គលម្នាក់ ឬច្រើននាក់រងទុក្ខវេទនា។

២.ជនដៃដល់បានបង្កការឈឺចាប់ ឬទុក្ខវេទនាក្នុងគោលបំណងដូចជា៖ ការទទួលព័ត៌មាន ឬចម្លើយសារភាពទណ្ឌកម្ម ការបំភិតបំភ័យ ឬការបង្ខិតបង្ខំ ឬសម្រាប់ហេតុផលណាមួយផ្អែកលើការរើសអើងប្រភេទណាមួយ។[៨៩]

[៨៩] Article 8(2)(a)(ii)-1, War Crime of Torture, Element of Crimes, International Criminal Court បានចូលមើលថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១១ http://www.icc-cpi.int/NR/rdonlyres/336923D8-A6AD-40EC-AD7B-45BF9DE73D56/0/ElementsofCrimesEng.pdf។

ការស៊កបញ្ចូលក្នុងប្រដាប់ភេទដោយប្រើវត្ថុខាងក្រៅដែលកើតឡើងមុន ឬក្រោយពេលស្លាប់ មិនត្រូវបានដាក់បញ្ចូលនៅទីនេះទេ។ ផ្ទុយទៅវិញទង្វើបែបនេះត្រូវបានចាត់ថ្នាក់ជាការរំលោភសេពសន្ថវៈ ដូចដែលបានកត់សម្គាល់នៅក្នុងផ្នែកពីមុនមក។

អ្នកឆ្លើយសំណួរជាង១៥%ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់បានរាយការណ៍ថា ពួកគេបានរងការកាត់អវៈយវៈភេទមួយចំនួន នៅពេលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ លើសពីនេះទៅទៀត អ្នកឆ្លើយសំណួរភាគច្រើនបានរាយការណ៍ថា បានដឹងពីករណីជាច្រើន ឬទម្រង់ជាច្រើននៃអំពើហិង្សាលើយេនឌ័រប្រភេទនេះ។ ទោះបីជារបាយការណ៍ភាគច្រើន និយាយថាបានឃើញភស្តុតាងនៃអំពើហិង្សានេះនៅលើខ្លួនប្រាណសាកសព ឬសាកសពត្រូវគេកាត់ប្រដាប់ភេទចោលក៏ដោយ ក៏អ្នកឆ្លើយសំណួរមួយចំនួនតូចក៏បានរាយការណ៍ផងដែរថា បានឃើញទង្វើទាំងនេះកើតឡើងក្នុងសម័យនោះ។


គ្រែអ្នកទោសនៅសារមន្ទីរទួលស្លែង: ផ្តល់ដោយ Nicolas Pascarel

របាយការណ៍រួមមួយនៅក្នុងប្រភេទនេះពិនិត្យទៅលើសាកសព ដែលគេបានរកឃើញដោយផ្ទាល់នៅកន្លែងសំលាប់មនុស្ស ឬរណ្តៅសព។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់ដែលជារឿយៗ ត្រូវបានបញ្ជូនទៅឃ្វាលគោក្របីនៅខេត្តព្រៃវែង ចងចាំថាបានឃើញសាកសពស្ត្រីជាច្រើនត្រូវបានគេ "ក្តិចមូល ហើយយកដែកកាត់សុដន់" បណ្តែតទឹកជំនន់នៅតាមផ្លូវ។ អ្នកឆ្លើយសំណួរភេទស្ត្រីម្នាក់នៅខេត្តស្វាយរៀង ដែលបានឃើញបងប្អូនបង្កើត និងគូដណ្តឹងរបស់ខ្លួនត្រូវគេសម្លាប់ចោលបានរាយការណ៍ ថា "ពួកគេបានអាករមនុស្សបន្តិចម្តងៗ ក្នុងគោលបំណងមិនចង់ឲ្យស្លាប់ភ្លាមៗនោះទេ"។ ស្ត្រីម្នាក់បានរាយការណ៍ទៀតថា ពួកទាហានទាំងនោះបានធ្វើទារុណកម្ម បន្ទាប់មកកាត់លិង្គគូដណ្តឹងរបស់គាត់។ នៅក្នុងករណីភាគច្រើនអ្នកឆ្លើយសំណួរនេះបានរៀបរាប់ថា ស្ត្រីត្រូវបានគេវះពោះយកកូនក្នុងផ្ទៃចេញដោយបើកចំហ ហើយសម្លាប់ចោល។

លើសពីនេះទៅទៀត អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍អំពីការកាត់អវៈយវៈភេទ ដែលបានកើតឡើង ខណៈពេលដែលជនរងគ្រោះជាប់ពន្ធនាគារ ឬត្រូវគេរំលោភសេពសន្ថវៈ។ អ្នកឆ្លើយសំណួរភេទប្រុសនៅខេត្តស្វាយរៀង ដែលបានជាប់ពន្ធនាគារអស់រយៈពេលមួយឆ្នាំបានរាយការណ៍ថា គាត់ស្តាប់ឮបុរសៗត្រូវគេឆក់ខ្សែភ្លើង និងវាយដំលិង្គនៅក្នុងពន្ធនាគារ ប៉ុន្តែរូបគាត់មិនបានទទួលរងអំពើបែបនេះទេ។ ស្រដៀងគ្នានេះដែរ ស្ត្រីម្នាក់ដែលជាប់ពន្ធនាគារនៅខេត្តបាត់ដំបងដែលបានរាយការណ៍ថាត្រូវបានបង្ខំឲ្យកប់សាកសពដែលត្រូវគេកាត់អវៈយវៈភេទចោលជាច្រើនក៏បានរំលឹកផងដែរអំពីហេតុការណ៍មួយនៅពេលដែលគាត់ពិតជាបានឃើញពួកទាហានខ្មែរក្រហម

ជេរ ហើយហៅជនរងគ្រោះថា ស្រីពេស្យាទៀតផង។ ពួកគេកាត់សុដន់របស់នាង ហើយបង្ខំឲ្យនាងសើច ពួកគេគំរាមនាងមិនឲ្យយំ។" នៅក្នុងករណីរំលោភមួយដែលបានរៀបរាប់ខាងដើមនៅក្នុងរបាយការណ៍នេះ សាក្សីក៏បានរំលឹកផងដែរថា ខណៈពេលបុរសកំពុងរំលោភជនរងគ្រោះ ពួកគេបានដុតស្បែករបស់នាង។

អ្នកឆ្លើយសំណួរជាច្រើន ដែលភាគច្រើននៅខេត្តស្វាយរៀង បានរាយការណ៍ថាបានឃើញប្រដាប់បន្តពូជ ឬប្រដាប់ភេទ និងគូទ ដែលត្រូវបានគេវះចេញពីរាងកាយជនរងគ្រោះ ហើយព្យួរលើដើមឈើ ឬដាក់បង្ហាញជាសាធារណៈ ដែលរឿយៗនៅមុខមូលដ្ឋានខ្មែរក្រហម ដូចជាការិយាល័យស្រុក ពន្ធនាគារ និងការិយាល័យឃុំ។ អ្នកឆ្លើយសំណួរម្នាក់បានឃើញកំប៉េះគូទមនុស្សត្រូវគេចងព្យួរលើដើមក្រសាំងជិតវត្តក្នុងមូលដ្ឋាន ដែលគេប្រើប្រាស់ជាពន្ធនាគារនៅសម័យនោះ។ ខ្ញុំភ្ញាក់ផ្អើលមែនទែនដែលបានឃើញប្រដាប់ភេទរបស់ស្ត្រីត្រូវគេចងព្យួរនឹងខ្សែល្អួសលើដើមឈើ។ គាត់បាននិយាយថា គាត់ស្គាល់ ជនរងគ្រោះ ហើយថានាងមិនបានធ្វើអ្វីខុសនោះទេ។" បុរសម្នាក់ដែលបានធ្វើការជាគ្រូថ្នាំបុរាណខ្មែរក្នុងរបបខ្មែរក្រហមបានរំលឹកថា បន្ទាប់ពីមន្ត្រីពន្ធនាគាររំលោភសេពសន្ថវៈរួច ពួកគេបានសម្លាប់ស្ត្រី៤នាក់ ដែលគាត់ឃើញកាលពីមួយថ្ងៃមុន។ គាត់បានរាយការណ៍ថា "ពួកគេបានកាត់ប្រដាប់ភេទរបស់ស្ត្រីទាំងនោះ រួចយកទៅហាលថ្ងៃឲ្យស្ងួត។ បន្ទាប់មកពួកគេយកទៅឲ្យគ្រូថ្នាំបុរាណខ្មែរនៅក្នុងឃុំពិនិត្យមើល។"

### ៥.២.៤ ការរំលោភបំពានខាងផ្លូវភេទ និងការធ្វើអោយអាម៉ាស់ខាងផ្លូវភេទ

អ្នកឆ្លើយសំណួរជិត២០%រាយការណ៍ថា ខ្លួនជាសាក្សីផ្ទាល់(១៣.៥%) ឬបានឃើញផ្ទាល់នូវការរំលោភបំពានខាងផ្លូវភេទ និងការកាត់អវៈយវៈភេទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកឆ្លើយសំណួរអង្កេតទាំងនេះបានរៀបរាប់អំពីការអនុវត្តប្រភេទផ្សេងគ្នា មានចាប់ពីការប្រើសម្ដីបំពាន និងការបៀតបៀនរហូតដល់ការដែលត្រូវគេបង្ខំឲ្យការរំលោភសេពសន្ថវៈ មិត្តរួមការងារ។ នៅក្នុងបរិបទនៃការត្រួតត្រា និងធ្វើអោយភ័យខ្លាចដែលញុាំងឲ្យមានសកម្មភាពអំពើហិង្សាដែលមិនអាចព្យាករណ៍បាន កើតមានជាញឹកញាប់ និងជារឿយៗនៅក្នុងរបបខ្មែរក្រហម ជនរងគ្រោះជាច្រើនមានអារម្មណ៍ថា អំពើហិង្សាលើយេនឌ័រ ជាសញ្ញានៃជោគវាសនាដ៏អាក្រក់ដែល រង់ចាំពួកគេ។ ទិន្នន័យដែលអ្នកឆ្លើយសំណួរបានផ្ដល់ឲ្យនៅក្នុងប្រភេទនេះ ត្រូវបានចាត់ជាក្រុមទៅតាមប្រភេទនៃអំពើដែលពាក់ព័ន្ធ។

> *"ខ្ញុំមិនដឹងច្បាស់ថា គាត់បានធ្វើអ្វីខ្លះទេ។ ខ្ញុំគ្រាន់តែដឹងថា គាត់ទៅទីនោះនៅពេលយប់ដើម្បីប្រើពាក្យចំអេសចំអាសជាមួយស្ត្រីប៉ុណ្ណោះ។"*
> *--អ្នកឆ្លើយសំណួរភេទស្រី ដែលបានធ្វើការនៅក្នុងសហករណ៍តម្បាញនៅខេត្តបាត់ដំបងបានរៀបរាប់ពីសកម្មភាពនានារបស់ទាហានខ្មែរក្រហម*

### ៥.២.៤.១ ការប្រើសម្ដីបំពាន និងការចំអក

អ្នកឆ្លើយសំណួរជាច្រើនបានស្ដាប់ឮពួកមន្ត្រី និងទាហានខ្មែរក្រហម ដែលប្រើសម្ដីបំពាន និងចំអកឲ្យស្ត្រី ជាពិសេសប្រជាជនចំណូលថ្មីដែលជម្លៀសមកពីតំបន់ផ្សេងៗ។ ស្ត្រីម្នាក់បានរំលឹកថា "ជួនកាលពួកគេប្រើភាសាមិនល្អទៅលើស្ត្រី ដោយហៅស្ត្រីថា ជាស្រីពេស្យាក្នុងរបបលន់ នល់។" អ្នកឆ្លើយសំណួរម្នាក់ទៀតបានរាយការណ៍ថា កម្មាភិបាលខ្មែរក្រហមបានប្រើសម្ដីមិនល្អចំពោះគាត់ និងប្រាប់គាត់ថា ពួកគេស្រឡាញ់គាត់៖ "ពួកគេបាននិយាយថា ប្រសិនបើខ្ញុំមិនព្រមស្រឡាញ់ពួកគេទេ ពួកគេនឹងសម្លាប់ចោល... ពួកគេនឹងរាយការណ៍អំពីខ្ញុំ ហើយនឹងសម្លាប់ខ្ញុំចោល... ពួកគេហៅខ្ញុំថា"ខ្មាំង"។" ស្ត្រីរូបនេះបានរាយការណ៍បន្តទៀតថា នៅពេលដែលរកឃើញសាច់ញាតិរបស់គាត់ គាត់បានប្រាប់ពួកគេថា គាត់មិនស្រឡាញ់ពួកគេទេ ពួកគេខ្លាចការដាក់ទណ្ឌកម្ម ។

### ៥.២.៤.២ ការបង្ខំឲ្យស្រាត

អ្នកឆ្លើយសំណួរនៅក្នុងការសិក្សានេះក៏បានរាយការណ៍ផងដែរអំពីស្ថានភាពផ្សេងៗ ដែលស្ត្រី និងបុរសត្រូវបានគេបង្ខំឲ្យដោះសម្លៀកបំពាក់។ នៅក្នុងករណីមួយ អ្នកឆ្លើយសំណួរបានរាយការណ៍ថា "ពេលខ្ញុំកំពុងដើរ ស្រាប់តែប្រទះឃើញស្ត្រីវ័យក្មេងពីរនាក់ដោយចៃដន្យ" ដែលគាត់ស្គាល់ថាជាជនជាតិចាម "កំពុងរាំស្រាតនៅចំពោះមុខពួកទាហាន...ពួកគេដាក់ដៃលើក្បាល។" អ្នកឆ្លើយសំណួរជាច្រើនដែលបានឃើញការសម្លាប់រង្គាល បានរាយការណ៍ថា ស្ត្រី និងបុរសត្រូវបានបង្ខំឲ្យដោះសម្លៀកបំពាក់ មុនពេលសម្លាប់ចោល។ អ្នកឆ្លើយសំណួរផ្សេងទៀតបានរាយការណ៍ថា បានស្ដាប់ឮ ជួនកាលពីកម្មាភិបាល ឬសន្តិសុខខ្មែរក្រហមថា ស្ត្រីវ័យក្មេងត្រូវបានកោះហៅឲ្យទៅការិយាល័យស្រុក ហើយត្រូវបានបង្ខំដោះសម្លៀកបំពាក់នៅចំពោះមុខពួកមន្ត្រីនៅទីនោះ។ អ្នកឆ្លើយសំណួរភេទប្រុសម្នាក់មកពីខេត្តស្វាយរៀងបានរាយការណ៍ថា ខ្លួនត្រូវបានប្រធានអញ្ជើញឲ្យចូលមើលក្មេងស្រីវៀតណាមច្រៀងស្រាតនៅក្នុងពន្ធនាគារនៅចំពោះមុខក្រុមបុគ្គលិក សន្តិសុខ និងមេដឹកនាំខ្មែរក្រហម។ ទាំងគាត់ និងអ្នកឆ្លើយសំណួរម្នាក់ទៀតបានរាយការណ៍ដោយឯករាជ្យថា ក្រោយមកគេបានឲ្យស្ត្រីម្នាក់ក្រាបចុះ រំលោភ ហើយក៏សម្លាប់ចោលទៅ។

### ៥.២.៤.៣ សាក្សីដែលត្រូវគេបង្ខំឲ្យមើលហិង្សាលើយេនឌ័រ

អ្នកឆ្លើយសំណួរភេទស្រីម្នាក់ ដែលទើបតែមានអាយុ១៥ឆ្នាំនៅពេលចាប់ផ្ដើមរបបកម្ពុជាប្រជាធិបតេយ្យ និងបានឃើញការរំលោភដ៏សាហាវមួយដោយសម្ងាត់ បានរាយការណ៍ថា គាត់

និងស្ត្រីវ័យក្មេងពីរនាក់ផ្សេងទៀតមកពីអង្គភាពរបស់គាត់ ត្រូវបានកម្មាភិបាលខ្មែរក្រហម ហៅមកដើម្បីបញ្ជូនទៅការដ្ឋានមួយផ្សេងទៀត។ ប៉ុន្តែគាត់បានរាយការណ៍ថា ផ្ទុយទៅវិញពួកគេត្រូវបាននាំទៅព្រៃមួយនៅក្បែរនោះ ហើយនៅពេលនោះគាត់ និងក្មេងស្រីម្នាក់ទៀតត្រូវបានបង្ខំឲ្យមើលក្មេងស្រីទីបីត្រូវគេរំលោភ។ "ពួកគេបាននិយាយថា ពួកគេចង់ឲ្យពួកយើងត្រៀមខ្លួនដើម្បីបម្រើផ្លូវភេទ... ៥ថ្ងៃក្រោយមកដល់វេនខ្ញុំម្តង។"

### ៥.២.៤.៤ ការប៉ះពាល់ដោយបំពាន

អ្នកឆ្លើយសំណួរអង្កេតជាច្រើនបានរាយការណ៍ថា ពួកគេបានឃើញមេដឹកនាំខ្មែរក្រហម និងពួកមន្ត្រីផ្សេងទៀតប៉ះពាល់ និងលូកលាន់ស្ត្រីនៅក្នុងសហករណ៍របស់ពួកគេ។ អ្នកឆ្លើយសំណួរភេទប្រុសម្នាក់មកពីខេត្តបាត់ដំបងបានរៀបរាប់ពីរបៀបដែលមេបញ្ជាការកងកម្លាំងមូលដ្ឋាន "មានអាកប្បកិរិយាមិនល្អ...គាត់បានដើរទៅជិត ស្ទាបអង្អែល ហើយប្រើពាក្យសម្តីចំអេសចំអាសជាមួយស្ត្រីនៅក្នុងសហករណ៍ទៀតផង។" អ្នកឆ្លើយសំណួរម្នាក់ទៀតបានរាយការណ៍ថា មនុស្សជាច្រើននៅក្នុងសហករណ៍របស់គាត់បាន និយាយថា ពួកគេក៏បានឃើញទង្វើបែបហ្នឹងដែរ ប៉ុន្តែគាត់មិនដែលបានឃើញផ្ទាល់ភ្នែកនោះទេ។ អ្នកឆ្លើយសំណួរពីរនាក់ផ្សេងទៀតមកពីខេត្តស្វាយរៀងក៏បានរំលឹកផងដែរអំពីរឿងរ៉ាវរបស់ស្ត្រីមូលដ្ឋានម្នាក់ និងប្អូនស្រីរបស់នាងដែលត្រូវពួកទាហានខ្មែរក្រហមរំលោភ៖ "ពួកគេបានធ្វើឲ្យស្ត្រីវ័យចំណាស់ម្នាក់ និងកូនស្រីរបស់គាត់ឈឺចាប់។ ពួកគេបានបង្ហាញផ្លែត្រប់(ត្រប់ក្តគោ) ហើយចោទស្ត្រីម្នាក់នោះ និងកូនស្រី របស់គាត់ថាជាចោរ។ បន្ទាប់មកពួកគេបានយកមែកឈើ លាត់សំពត់ស្ត្រីវ័យចំណាស់ឡើងទៅលើជាការសើចសប្បាយ។

## ៥.២.៥ ការបង្ខំឲ្យរៀបការ

ដូចបានពិភាក្សាខាងដើមអញ្ចឹង កម្រងសំណួរអង្កេតសម្រាប់ការសិក្សានេះមិនបានសួរអ្នកឆ្លើយសំណួរអំពីប្រធានបទនៃការរៀបការ ឬការបង្ខំឲ្យរៀបការក្នុងរបបខ្មែរក្រហម។ ទោះជាយ៉ាងនោះក្តីតាមគំនិតផ្តួចផ្តើមរបស់ពួកគេអ្នកឆ្លើយសំណួរជិត ២០% បានលើកឡើងពីបញ្ហានេះ។ នៅក្នុងករណីភាគច្រើនអ្នកឆ្លើយសំណួរបានពិភាក្សាអំពីការរៀបការដោយបង្ខំរបស់ខ្លួន ឬការរៀបការដោយបង្ខំរបស់សាច់ញាតិខ្លួន។ ប្រធានបទរួមបីត្រូវបានអ្នកឆ្លើយសំណួរទាំងនេះលើកមកពិភាក្សា៖ ទី១ អាពាហ៍ពិពាហ៍ទាំងនេះបានប្រព្រឹត្តក្នុងបរិបទមួយដែល "ខ្មែរក្រហមមិនអនុញ្ញាតឲ្យមានសេចក្តីស្នេហានោះឡើយ"មានន័យថាផ្ទុយនឹងទម្លាប់អនុវត្តធម្មតា ហើយទី២អាពាហ៍ពិពាហ៍ត្រូវបានរៀបចំផ្ទុយនឹងអ្វីដែលអ្នកឆ្លើយសំណួរបានយល់ថា ជាអាពាហ៍ពិពាហ៍ដ៏សមស្រប។ អ្នកឆ្លើយ សំណួរ

បានរៀបរាប់អំពីអាពាហ៍ពិពាហ៍ ដែលមាន ២០ ទៅជាង ៣០គូ ដែលនាំឲ្យអ្នកឆ្លើយសំណួរម្នាក់លើកឡើងថា ប្រជាជនត្រូវបានរៀបអាពាហ៍ពិពាហ៍ជា"ហ្វូង" ក្រោមរបបខ្មែរក្រហម។

ទីបី ស្របនឹងរបកគំហើញពីការស្រាវជ្រាវ ផ្សេងទៀត អ្នកឆ្លើយសំណួរបានបរិយាយអំពីការដាក់សម្ពាធឲ្យគូស្វាមីភរិយាសយល់ព្រមរៀបការ និងរួមរ័កគ្នាបន្ទាប់ពីរៀបការរួច។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់មកពីខេត្តស្វាយរៀងដែលមានអាយុ១៧ឆ្នាំ កាលពីសម័យនោះបានរាយការណ៍ថា គេបានឲ្យគាត់រៀបការនៅក្នុងឆ្នាំ១៩៧៧ ដោយសារតែគាត់ភ័យខ្លាចថា ប្រសិនបើគាត់មិនរៀបការទេនោះ គេនឹងយកគ្រួសារគាត់ទៅសម្លាប់ចោល។ អ្នកឆ្លើយសំណួរភេទប្រុសម្នាក់នៅខេត្តបាត់ដំបងបានរៀបរាប់រឿងរ៉ាវរបស់ស្ត្រីវ័យក្មេងម្នាក់នៅក្នុងឃុំរបស់គាត់ ដែលត្រូវគេបង្ខំឲ្យរៀបការ ហើយនៅយប់ដំបូងជាមួយប្តីថ្មីរបស់នាង នាងស្លៀកខោជើងវែង និងបានយក មុង ភួយ មកគេងជាមួយនាង ដើម្បីព្យាយាមគេចពីការរួមភេទ។ ក្រោយមកប្តីរបស់នាងបានទុកនាងនៅផ្ទះរបស់អ្នកឆ្លើយសំណួរនេះ ពេលនោះស្រាប់តែគាត់រកមូលហេតុឃើញថា នាងត្រូវប្តីថ្មី រំលោភរួចបោះបង់ចោល។



*រូបចម្លាក់លៀននៅក្នុងខេត្តបាត់ដំបងបង្ហាញអំពីការរៀបការដោយបង្ខំក្នុងសម័យខ្មែរក្រហម*

យោងតាមការអនុវត្ត និងបទពិសោធន៍ផ្សេងៗគ្នាដូចបានរៀបរាប់នៅក្នុងការស្រាវជ្រាវអំពីការបង្ខំឲ្យរៀបការ អ្នកឆ្លើយសំណួរនៅក្នុងការសិក្សានេះក៏បានសម្តែងឥរិយាបថ អំពីការបង្ខំឲ្យរៀបការ ដែលមានលក្ខណៈខុសគ្នាគួរឲ្យកត់សម្គាល់។ ឧទាហរណ៍អ្នកឆ្លើយសំណួរភេទស្រីម្នាក់នៅខេត្តបាត់ដំបងបានរៀបរាប់ថា "នៅក្នុងរបបនោះ ប្រសិនបើបុរសស្នើសុំនរណាម្នាក់រៀបការ ពួកគេអាចសម្រេចបំណងរបស់ខ្លួនទោះបីជាស្ត្រីនោះ មិនចង់ក៏ដោយ។ នាងត្រូវតែយល់ព្រមតាមអង្គការ។" ចំណែកឯអ្នកឆ្លើយសំណួរភេទស្រីម្នាក់នៅខេត្តស្វាយរៀងបានរាយការណ៍ថា នៅពេលដែលកម្មាភិបាលខ្មែរក្រហមស្នើសុំកូនក្រមុំណាមួយ សំណើទាំងនេះមិនត្រូវបានផ្តល់ឡើយ។ ពាក់ព័ន្ធនឹងលទ្ធផល នៃការរៀបអាពាហ៍ពិពាហ៍បែបនេះ អ្នកឆ្លើយសំណួរភេទស្រីម្នាក់មកពីខេត្តស្វាយរៀងបានបរិយាយថា ទោះបីជានាងត្រូវបានបង្ខំឲ្យរៀបការហើយ "ពួកយើងមិនបានស្គាល់គ្នាច្បាស់ក៏ដោយ ក៏ពួកយើងអាចរស់នៅជាមួយគ្នាដោយសុខសាន្តរហូតស្លាប់រៀងៗខ្លួន។" អ្នកឆ្លើយ

> "សម្រាប់អ្នកដែលរៀបអាពាហ៍ពិពាហ៍ ពួកគេត្រូវបានរៀបចំជាក្រុមរួម...២០ ៣០ ឬ ៤០គូ។ អាពាហ៍ពិពាហ៍ត្រូវបានរៀបចំដោយមានរាប់សិបគូ!"
>
> *--អ្នកឆ្លើយសំណួរភេទស្រីមកពីស្វាយរៀង បានរៀបរាប់ពីអាពាហ៍ពិពាហ៍ ដែលគាត់បានឃើញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

សំណួរម្នាក់ថែមទាំងបានលើកឡើងទៀតថា ទោះបីជានាងខកចិត្តចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅឆ្នាំ១៩៧៦ក៏ដោយ ក៏នាងសូមអរគុណដែលនាងមានប្តី ពីព្រោះនាងមានអារម្មណ៍ថា ប្តីនាងបានជួយការពារនាងពីអំពើហិង្សាផ្លូវភេទ ដែលនាងធ្លាប់ឃើញកើតមានចំពោះស្ត្រីផ្សេងទៀត។ ទោះបីយ៉ាងណាក្តី ដូចដែលបានកត់សំគាល់នៅក្នុងរបាយការណ៍ក្នុងផ្នែកនេះ និងផ្នែកដទៃទៀត អំពើរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្តឡើងផងដែរនៅក្នុងទំនាក់ទំនងសហព័ទ្ធ និងការរំលោភទៅលើស្ត្រីដែលបានរៀបការរួចហើយ។

# ៥.៣ ប្រធានបទរួមនៅក្នុងរបាយការណ៍ស្តីពីអំពើហិង្សាលើយេនឌ័រ

## ៥.៣.១ កំហុសផ្នែកសីលធម៌ និងការដាក់កម្រិតបញ្ហាផ្លូវភេទ

មេដឹកនាំខ្មែរក្រហមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគោលនយោបាយជាក់លាក់ ដែលត្រូវបានប្រកាសអំពីក្រមសីលធម៌ទាំង១២សម្រាប់យុទ្ធជន″ ដែលបានហាមឃាត់ដាច់ខាតចំពោះការរំលោភបំពានលើស្ត្រី រួមមានការបង្ខំឲ្យស្ត្រីរួមភេទ ឬរួមភេទជាមួយស្ត្រីដែលមិនមែនជាប្រពន្ធរបស់ខ្លួន។[៨៥] ក្នុងអំឡុងរបបនេះ គោលនយោបាយនេះត្រូវបានអនុវត្តចំពោះយុទ្ធជនក៏ដូចជាប្រជាជនទូទៅ និងត្រូវបានអនុវត្តចំពោះទំនាក់ទំនងដោយព្រមព្រៀង និងមិនព្រមព្រៀងដូចដែលអ្នកឆ្លើយសំណួរកត់សម្គាល់នៅក្នុងការសិក្សានេះ។[៨៦] គោលជំហរនៃរបបនេះទៅលើ "កំហុសផ្នែកសីលធម៌" ដែលជាការរំលោភបំពានលើក្រមសីលធម៌គឺជាពាក្យមួយនៅសម័យនោះ បានដឹកនាំមនុស្សមួយចំនួនរួមមានសហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[៨៧] ដែលបានលើកឡើង ថា គោលនយោបាយនេះត្រូវបានអនុវត្តជាប្រចាំ។ ទស្សនៈនេះត្រូវបានអ្នកឆ្លើយសំណួរមួយចំនួនតូចចែករំលែកនៅក្នុងការអង្កេតនេះ ដែលក្នុងនោះអ្នកឆ្លើយសំណួរម្នាក់ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងនោះបានរាយការណ៍ថា "នៅពេលដែលមេដឹកនាំបានដឹងពីទំនាក់ទំនង (គ្មានការព្រមព្រៀង)... អ្នកទាំងពីរនឹងត្រូវគេសម្លាប់ចោល។" គោលនយោបាយខ្មែរក្រហមស្តីពីកំហុសផ្នែកសីលធម៌ក៏ទំនងជាបានលើកទឹកចិត្តដល់អ្នកផ្សេងទៀត រួមមានប្រជាជនជាច្រើនបាន

> "ទោះបីជា[ខ្មែរក្រហម]មិនបានអនុញ្ញាតឲ្យខុសសីលធម៌ក៏ដោយក៏តាមពិតទៅវាគ្រាន់តែជាការនិយាយប៉ុណ្ណោះ។ ទង្វើរបស់ពួកគេអាក្រក់ជាងសត្វតិរច្ឆានទៅទៀត។"
> *--អ្នកឆ្លើយសំណួរភេទប្រុសនៅខេត្តបាត់ដំបង*

[៨៥] ឆាង យុក "The Sixth Code of Conduct," *Searching for the Truth* ១៥ (២០០១) ១។ *សូមមើល* Chandler, *Tragedy of Cambodian History* ២០៩ *ផងដែរ* ។
[៨៦] *សូមមើល* ឆាង "Sixth Code of Conduct"។
[៨៧] *សូមមើល* សំណុំរឿង០០២ ដីកាដំណោះស្រាយ D427 ពីកថាខណ្ឌ ១៤២៩ (ការថែងថា "គោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យផ្លូវការស្តីពីការរំលោភសេពសន្ថវៈ គឺត្រូវទប់ស្កាត់ ការកើតមានអំពើរំលោភសេពសន្ថវៈ និងដាក់ទណ្ឌកម្មដល់ជនដៃដល់")។

ធ្វើឲ្យគម្រោងនេះមានការអភិវឌ្ឍន៍ ដើម្បីសន្និដ្ឋានអំពីការហាមឃាត់ចំពោះទង្វើអសីលធម៌ដែលត្រូវទប់ស្កាត់ ឬដាក់កម្រិតយ៉ាងខ្លាំងចំពោះការកើតមានអំពើហិង្សាលើយេនឌ័រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។[៨៨] ប៉ុន្តែទាំងទិន្នន័យដែលប្រមូលបាននៅទីនេះ និងនៅក្នុងការសិក្សាកន្លងមក[៨៩] បានលើកឡើងថា ទោះបីជាគោលនយោបាយហាមឃាត់កំហុសផ្នែកសីលធម៌អាចនាំឲ្យមានការដាក់ទណ្ឌកម្មលើបុគ្គលមួយចំនួនចំពោះអំពើហិង្សាលើយេនឌ័រក៏ដោយ ក៏គោលនយោបាយនេះមិនបានទប់ស្កាត់ការកើតមានរាលដាលនូវអំពើហិង្សាលើយេនឌ័រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរ។ ដូចដែលអ្នកស្រាវជ្រាវមួយចំនួនបានលើកឡើង និងដោយមានការគាំទ្រនៅក្នុងបទសម្ភាសន៍របស់យើង លទ្ធផលនេះទំនងជាអាចនិយាយបានថា ជាធម្មតាអំពើហិង្សាលើយេនឌ័រត្រូវបានអនុវត្ត "ដោយលួចលាក់" ប៉ុណ្ណោះ។[៩០] លើសពីនេះទៅទៀត គោលនយោបាយនេះក៏ទំនងជាមានផលប៉ះពាល់ធ្ងន់ធ្ងរក្នុងការដាក់ទណ្ឌកម្មជនរងគ្រោះ។ អ្នកឆ្លើយសំណួរនៅក្នុងការសិក្សានេះបានរាយការណ៍អំពីករណីមួយចំនួន ដែលគេដឹងថាស្ត្រីត្រូវគេរំលោភសេពសន្ថវៈត្រូវបានសម្លាប់ចោលចំពោះការពាក់ព័ន្ធនឹងកំហុសផ្នែកសីលធម៌ ឬធ្វើអត្តឃាដដើម្បីជៀសពីទណ្ឌកម្មចំពោះបទល្មើសដែលគេប្រព្រឹត្តមកលើខ្លួន។

នៅក្នុងការសិក្សានេះអ្នកឆ្លើយសំណួរតែម្នាក់គត់ដែលបានបដិសេធថាមិនបានដឹងអំពីអំពើហិង្សាលើយេនឌ័រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចេញទស្សនៈថា គោលជំហរនៃរបបនេះប្រឆាំងនឹងសេចក្តីស្នេហា និងទំនាក់ទំនងផ្លូវភេទដែលគ្មានការព្រមព្រៀងបានទប់ស្កាត់អំពើហិង្សាលើយេនឌ័រប្រកបដោយប្រសិទ្ធភាព។ គាត់បានរាយការណ៍ថា "ទង្វើនានាទាក់ទងនឹងការរំលោភសេពសន្ថវៈមិនបានកើតឡើងនៅក្នុងសម័យ ប៉ុល ពត នោះទេ... ចំណែកឯសីលធម៌វិញល្អណាស់។ គ្មាននរណាម្នាក់ត្រូវគេបង្ខំឲ្យរួមភេទឡើយ។ បើសិនជនណាហ៊ានធ្វើ ជននោះនឹងត្រូវគេសម្លាប់ចោលមិនខាន។" ផ្ទុយទៅវិញ អ្នកឆ្លើយសំណួរដែលបានឃើញទង្វើនៃអំពើហិង្សាលើយេនឌ័រនេះមានការងឿងឆ្ងល់អំពីគោលនយោបាយរបស់ខ្មែរក្រហមទាក់ទងនឹងទង្វើអសីលធម៌ និងទំនងជាមានទស្សនៈខុសគ្នាតិចតួចអំពីការអនុវត្តគោលនយោបាយប្រឆាំងនឹងកំហុសផ្នែកសីលធម៌ក្រោមរបបខ្មែរក្រហម។ អ្នកឆ្លើយសំណួរម្នាក់ ដែលបានឃើញសាកសពត្រូវគេកាត់អវៈយវៈភេទ

[៨៨] អ្នកប្រាជ្ញជាច្រើននៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកជំនាញដែលធ្វើការអំពើហិង្សាផ្អែកលើយេនឌ័របានបញ្ចេញទស្សនៈនេះប្រាប់អ្នកនិពន្ធ។ *សូមមើល* កំណត់ត្រាបទសម្ភាសន៍ផ្ទាល់របស់អ្នកនិពន្ធ។ អ្នកឆ្លើយសំណួរជាច្រើននៅក្នុងការសិក្សានេះបានគូសបញ្ជាក់ថា អំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហមត្រូវបានដាក់ទណ្ឌកម្ម។ យោងតាមអ្នកឆ្លើយសំណួរម្នាក់បានឲ្យដឹងថា "នៅពេលណាដែលមេដឹកនាំរកឃើញទំនាក់ទំនង[ដែលគ្មានការអនុញ្ញាត] ... អ្នកទាំងពីរនឹងត្រូវសម្លាប់ចោល។"

[៨៩] សំដៅចំពោះកិច្ចពិភាក្សាបញ្ហានេះនៅក្នុងផ្នែកស្តីពីអំពើហិង្សាលើយេនឌ័រនៅក្នុងសម័យខ្មែរក្រហម ខាងដើមទំព័រទី ២៩-៣៣។

[៩០] *សូមមើល* Anderson, "Turning Reconciliation on Its Head" ៧៩០ និង Mam, *Democratic Kampuchea* ២៥។

និងបានដឹងច្បាស់អំពីអំពើហិង្សាផ្លូវភេទដែលមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្ត បានរៀបរាប់ថា "សម្រាប់អ្នកស្លៀកពាក់ខ្មៅនិយាយថា "មេដឹកនាំ" វាមិនអីទេដែលពួកគេបំពានច្បាប់ ប៉ុន្តែសម្រាប់ពួកយើងជាមនុស្សសាមញ្ញវិញ អាចត្រូវគេសម្លាប់ចោល ប្រសិនបើពួកគេរកឃើញថា ពួកយើងមានស្នេហាឬរួមរ័កគ្នាដោយលួចលាក់។"អ្នកឆ្លើយសំណួរម្នាក់ទៀតដែលបានដឹងពីការរំលោភសេពសន្ថវៈជាច្រើននៅក្នុងសហករណ៍របស់គាត់ ដែលគណៈស្រុកបានប្រព្រឹត្ត បានរៀបរាប់នៅក្នុងបទសម្ភាសន៍របស់គាត់ថា "នៅក្នុងរបបនោះ អ្នកដែលគ្រាន់តែជាមនុស្សសាមញ្ញ ឬមានឋានៈតូចតាចនឹងត្រូវគេរកឃើញថាមានទោស ប៉ុន្តែពួកទាហានដែលបានរំលោភសេពសន្ថវៈស្ត្រីមិនដែលជាប់ទោសឡើយ។ ជួនកាលពួកគេថែមទាំងសម្លាប់ស្ត្រីដើម្បីបិទបាំងការពិតទៀតផង។" អ្នកឆ្លើយសំណួរនៅក្នុងការសិក្សានេះបានរាយការណ៍អំពីករណីបីដែលជនដៃដល់នៃអំពើហិង្សាលើយេនឌ័រត្រូវបានចោទប្រកាន់អំពីកំហុសផ្នែកសីលធម៌។ នៅក្នុងករណីមួយក្នុងចំណោមករណីទាំងបីនេះ ជនដៃដល់បានរត់គេចមុនពេលគេវិនិច្ឆ័យទោស ចំណែកឯជនរងគ្រោះវិញត្រូវគេសម្លាប់ចោលដោយសារតែពាក់ព័ន្ធជាមួយជនដៃដល់។ នៅក្នុងករណីទី២ ប្តីជនរងគ្រោះបានចោទប្រកាន់ជនដៃដល់(ប្រធានក្រុម) ហើយគេបានបើក "កិច្ចប្រជុំ វិនិច្ឆ័យ"។ ប៉ុន្តែជនដៃដល់ និងជនរងគ្រោះមិនត្រូវបានដាក់ទណ្ឌកម្មឡើយ។ នៅក្នុងករណីទី៣ ទាំងជនរងគ្រោះ និងជនដៃដល់ត្រូវបានសម្លាប់ចោលដោយសារតែបានប្រព្រឹត្តទង្វើដែលរបបនេះយល់ឃើញថាជាកំហុសផ្នែកសីលធម៌របស់ពួកគេ។

ជាការពិតណាស់ នេះមិនមែនបានន័យថា គោលនយោបាយប្រឆាំងនឹងកំហុសផ្នែកសីលធម៌គ្មានប្រសិទ្ធភាពនោះទេ។ នៅក្នុងបទសម្ភាសន៍ជាច្រើន អ្នកឆ្លើយសំណួរបានរៀបរាប់អំពីទង្វើនានាដែលជនដៃដល់បានប្រព្រឹត្ត ដើម្បីជៀសវាងការរកឃើញបទល្មើសរបស់ពួកគេ រួមមានរបាយការណ៍ដែលពួកគេបានសម្លាប់ជនរងគ្រោះ បានរត់ទៅឆ្ងាយ ឬសម្លាប់ខ្លួនដើម្បីគេចពីទណ្ឌកម្ម។ ជាមួយគ្នានេះដែរ អ្នកឆ្លើយសំណួរភាគច្រើនបានរាយការណ៍ថា ពួកគេមិនហ៊ាននិយាយជាមួយសមាជិកដែលមានភេទផ្ទុយគ្នា ឬពាក់ព័ន្ធនឹងអាកប្បកិរិយាណាមួយ ដែលបង្ហាញពីទំនាក់ទំនងមនោសញ្ចេតនាដោយសារតែពួកគេខ្លាចទទួលទណ្ឌកម្មពីកំហុសផ្នែកសីលធម៌។

ចម្លើយទាក់ទងនឹងកំហុសសីលធម៌បានលើកឡើងថា ការហាមឃាត់កំហុសផ្នែកសីលធម៌អនុវត្តមិនយុត្តិធម៌ចំពោះជនរងគ្រោះដែលគ្មានអំណាច និងជនរងគ្រោះដែលនៅស្ងៀម ដែលបារម្ភខ្លាចថា នឹងធ្វើឲ្យពួកគេក្លាយជាជនរងគ្រោះហើយត្រូវគេសម្លាប់ចោល។ នៅក្នុងករណីមួយ អ្នកឆ្លើយសំណួរម្នាក់បានរាយការណ៍ថា "មានជនរងគ្រោះបួននាក់ហ៊ាននិយាយថា ពួកគេត្រូវគេរំលោភសេពសន្ថវៈ និយាយរួចហើយក៏ត្រូវគេសម្លាប់ចោល។" លើសពីនេះទៅទៀតយ៉ាងហោច

ណាស់នៅក្នុងបទពិសោធន៍ដែលអ្នកឆ្លើយសំណួរត្រូវបានសួរនៅក្នុងការអង្កេតនេះការដាក់ទណ្ឌកម្មរបស់ខ្មែរក្រហមចំពោះការខុសសីលធម៌ ទំនងជាសំដៅទៅលើអ្នកដែលពាក់ព័ន្ធនឹងទំនាក់ទំនងដោយការព្រមព្រៀងច្រើនជាងអំពើហិង្សាផ្លូវភេទ។ នៅក្នុងរឿង៤ ក្នុងចំណោមរឿងទាំង១៧ដែលអ្នកឆ្លើយសំណួរបានរាយការណ៍អំពីបុគ្គល ឬគូស្វាមីភរិយាដែលត្រូវគេចោទប្រកាន់ពីកំហុសផ្នែកសីលធម៌ ជនដែលពាក់ព័ន្ធទាំងនោះគឺទាក់ទងទៅនឹងទំនាក់ទំនងដោយការព្រមព្រៀង។

## ៥.៣.២ ការប្រឈមដោះស្រាយ ការភ័យខ្លាច និងការមាក់ងាយ

អ្នកឆ្លើយសំណួរជាច្រើននៅក្នុងការសិក្សានេះ ជាពិសេសស្ត្រីវ័យក្មេងដែលគេបញ្ជូនឲ្យទៅធ្វើការឆ្ងាយពីគ្រួសារនៅសម័យនោះបានរាយការណ៍ថា បានដឹងច្រើនអំពីការគំរាមកំហែងនៃអំពើហិង្សាផ្លូវភេទ។ នៅក្នុងចម្លើយនោះស្ត្រីទាំងនេះបានបង្កើតយុទ្ធសាស្ត្រ ដើម្បីព្យាយាមជៀសឲ្យផុតពីភាពក្លាយជាជនរងគ្រោះ។ ស្ត្រីវ័យក្មេងម្នាក់ដែលបានរស់នៅក្រោមរបបខ្មែរក្រហម ជាក្មេងជំទង់ម្នាក់បានរៀបរាប់អំពីរឿងដែលមេឃុំរំលោភសេពសន្ថវៈស្ត្រីវ័យក្មេងនៅសាលាឃុំ នៅក្នុងអង្គភាពចល័តរបស់នាង ដោយកត់សម្គាល់ថា "គេបានប្រាប់យើងជាមុនថាកុំទៅ ប្រសិនបើគេហៅអ្នកទៅប្រជុំសម្ងាត់ជាមួយមេឃុំនោះ។" អ្នកឆ្លើយសំណួរម្នាក់ទៀតបានកត់សម្គាល់ថាបន្ទាប់ពីស្ត្រីវ័យក្មេងនៅក្នុងក្រុមការងាររបស់នាងបានដឹងពីការរំលោភសេពសន្ថវៈស្ត្រីច្រើននាក់ផ្សេងទៀត ពួកគេត្រូវបានគេប្រាប់ជាមុនថាឲ្យនៅឆ្ងាយពីកន្លែងដែលមានការរំលោភសេពសន្ថវៈនេះ និងគេចមិនទៅ "កិច្ចប្រជុំពិសេស" ដែលរៀបចំឡើងសម្រាប់តែស្ត្រី។ អ្នកឆ្លើយសំណួរដដែលនេះ ដែលបានធ្វើដំណើរជាមួយសមាជិកនៃកងចល័តបានកត់សម្គាល់ថានាងបានឮការជូនដំណឹងជាមុនដូចគ្នានៅគ្រប់តំបន់ទាំងអស់ដែលគេបញ្ជូននាងឲ្យទៅធ្វើការ។

> "ខ្ញុំគ្រាន់តែភ័យខ្លាចតិចតួចប៉ុណ្ណោះក្នុងការនិយាយចេញមក។ នៅសម័យប៉ុល ពត ប្រសិនបើពួកគេឮនរណាម្នាក់និយាយអំពី[អំពើហិង្សាផ្លូវភេទ/អសីលធម៌] យើងនឹងត្រូវគេសម្លាប់ចោល...គ្មាននរណាម្នាក់ហ៊ាននិយាយទេ សូម្បីនៅពេលដែលយើងដឹងការពិតក៏ដោយក៏យើងមិនហ៊ាននិយាយដែរ។"
>
> *–អ្នកឆ្លើយសំណួរភេទស្រីនៅខេត្តបាត់ដំបង បានសម្តែងនូវការស្ទាក់ស្ទើរក្នុងការពិភាក្សាអំពីអំពើហិង្សាផ្លូវភេទនៅក្នុងបទសម្ភាសន៍របស់នាង*

ប៉ុន្តែអ្នកឆ្លើយសំណួរផ្សេងទៀតបានសម្តែងនូវអារម្មណ៍ឥតប្រយោជន៍ដូចដែលអ្នកដែលរស់នៅក្នុងរបបខ្មែរក្រហមគិតអំពីកាលៈទេសៈរបស់ពួកគេទាំងនោះ ប្អូនស្រីរបស់គាត់ប្រាប់ឪពុកម្តាយថា នាងត្រូវគេរំលោភសេពសន្ថវៈខណៈពេលកំពុងធ្វើនៅឆ្ងាយ ពីគ្រួសារបានរាយការណ៍ថាឪពុករបស់នាងឆ្លើយថា៖ "គាត់បានប្រាប់ខ្ញុំឲ្យប្រុងប្រយ័ត្ន ហើយយើងត្រូវអត់ធ្មត់ដើម្បីរស់។" អ្នកឆ្លើយសំណួរផ្សេងទៀតបានលើកឡើងជាថ្មីអំពីអារម្មណ៍ជាប់ជំពាក់នឹងស្ថានភាពរស់នៅរបស់ពួកគេនៅសម័យនោះ។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់មកពីខេត្តបាត់ដំបង បានរាយការណ៍

## របកគំហើញ

អំពីរឿងរបស់ស្ត្រីក្នុងភូមិមូលដ្ឋានម្នាក់ ដែលត្រូវគេហៅឲ្យទៅប្រជុំជាមួយមន្ត្រីខ្មែរក្រហមម្នាក់ ហើយត្រូវមន្ត្រីនោះរំលោភសេពសន្ថវៈ "នាងមានប្តីហើយ ប៉ុន្តែពួកគេមិនហ៊ាននិយាយអ្វីអាក្រក់អំពីបុរសទាំងនោះទេ ប្រសិនបើហ៊ាននិយាយពួកគេមុខជានឹងត្រូវស្លាប់មិនខាន។" ទិន្នន័យដែលប្រមូលបាននៅក្នុងការអង្កេតនេះក៏បានលើកឡើងថា ការភ័យខ្លាចនោះកើតមានគ្រប់ទីកន្លែងក្នុងចំណោមជនរងគ្រោះនិងអ្នកដែលមិនបានក្លាយជាជនរងគ្រោះផ្លូវភេទ។ ដូចដែលអ្នកឆ្លើយសំណួរភេទស្រីម្នាក់បានលើកឡើងកាលពីសម័យនោះអញ្ចឹង អ្នកដែលនៅស្ងៀម និងធ្វើល្ងង់អាចរស់បានយូរជាងអ្នកដែលបានដឹងរឿងច្រើន។" ស្ត្រីម្នាក់ទៀតបានរាយការណ៍ថា ជនរងគ្រោះដោយការរំលោភសេពសន្ថវៈបានប្រាប់នាងថា ជនដៃដល់បានគំរាមសម្លាប់នាង ប្រសិនបើនាងប្រាប់នរណាម្នាក់អំពីអ្វីដែលបានកើតឡើងនោះ។ នៅក្នុងករណីខ្លះ ការភ័យខ្លាចនេះបណ្តាលមកពីផលប៉ះពាល់ដ៏គួរឲ្យភ័យខ្លាចដោយឃើញស្ត្រីដែលប្តឹងអំពីអំពើហិង្សាលើយេនឌ័រត្រូវគេដាក់ទណ្ឌកម្មពីបទប្រព្រឹត្តអំពើអសីលធម៌។

ទាំងរបកគំហើញពីការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បញ្ជាក់ច្បាស់ថា ទោះបីជាជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រពិតជាបានចូលរួមចែករំលែករឿងរបស់ពួកគេអំពីភាពជាជនរងគ្រោះផ្លូវភេទជារឿយៗ ដែលពួកគេបានជួបប្រទះ ទោះបីជាមានការលើកទឹកចិត្តដ៏គួរឲ្យកត់សម្គាល់ ការនៅស្ងៀមមិននិយាយស្តីក៏នៅតែមាន។ នៅក្នុងការសិក្សានេះ ស្ត្រីម្នាក់ដែលត្រូវប្រធានក្រុមរបស់នាងរំលោភជាក្រុមនោះ បានប្រាប់អ្នកសម្ភាសន៍របស់នាងថា "ខ្ញុំមិនដែលប្រាប់នរណាម្នាក់អំពីរឿងរំលោភសេពសន្ថវៈនេះទេ។ នេះជាលើកទីមួយហើយដែលខ្ញុំបានប្រាប់...សូម្បីតែប្តីក៏ខ្ញុំមិនដែលប្រាប់ផង ប៉ុន្តែក្រោយមកយើងលែងលះគ្នា។" ទោះបីជានាងបានប្រាប់អ្នកសម្ភាសន៍ថា នាងសូមអរគុណដែលមានឱកាស និយាយអំពីរឿងរបស់នាងនៅពេលនេះក៏ដោយ ក៏អ្វីដែលគួរឲ្យកត់សម្គាល់គឺថា នាងមានអារម្មណ៍មិនសប្បាយចិត្ត ដែលបានចែករំលែកព័ត៌មាននេះសូម្បីតែអ្នកដែលខ្លួនស្រឡាញ់ជិតស្និទ្ធបំផុត។ អ្នកឆ្លើយសំណួរជាច្រើនបានបង្វែរអ្នកសម្ភាសន៍ទៅរកស្ត្រីដែលភាគច្រើននៅក្នុងសហគមន៍គេជឿថា បានរងគ្រោះដោយសារអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។ ប៉ុន្តែមិនមានស្ត្រីណាមួយដែលអាចជួបជុំគ្នាបានសារភាពថាខ្លួនបានក្លាយជាជនរងគ្រោះនោះទេ។ លើសពីនេះទៅទៀតអ្នកឆ្លើយសំណួរដែលបានផ្តល់ព័ត៌មាននេះជារឿយៗសង្ស័យថា ជនរងគ្រោះទាំងនោះមិនបាននិយាយជាមួយនរណាម្នាក់អំពីបទពិសោធន៍របស់ពួកគេផង ហើយនៅក្នុងករណីខ្លះពួកគេស្ទាក់ស្ទើរ ឬ បដិសេធមិនផ្តល់ព័ត៌មានបែបនេះនោះទេ ដោយសារតែពួកគេខ្លាចទទួលទណ្ឌកម្មធ្ងន់ធ្ងរបើសិនហ៊ាននិយាយ "រឿងសម្ងាត់"របស់ជនរងគ្រោះ។" នេះមិនមែនបានន័យថា ជនរងគ្រោះជាខ្មែរនឹងមិននិយាយចេញមក

ទេ ឬវប្បធម៌កម្ពុជានឹងទប់ស្កាត់ ប៉ុន្តែផ្ទុយទៅវិញត្រូវទទួលស្គាល់ថា នៅក្នុងវប្បធម៌ផ្សេងទៀត កាលណាគាត់ហ៊ាននិយាយចេញមក ពួកគាត់នឹងប្រឈមគ្រោះថ្នាក់ជាមិនខាន ដូច្នេះពួកគេអាច ត្រូវការសុវត្ថិភាព ការគាំទ្រ និងការលើកទឹកចិត្តនៅក្នុងដំណើរការនេះ។

លើសពីនេះទៅទៀត ការអង្កេតជាច្រើនមកពីអ្នកឆ្លើយសំណួរសម្ភាសន៍លើកឡើងថា ជារឿយៗការទទួលរងនឹងអំពើហិង្សាផ្លូវភេទត្រូវបិទបាំង ដោយសារពួកគេនៅស្ងៀមមិននិយាយស្តី ដោយគូសបញ្ជាក់អំពីការមាក់ងាយពីសង្គមពាក់ព័ន្ធនឹងភាពក្លាយជាជនរងគ្រោះផ្លូវភេទនៅកម្ពុជា។[៩១] អ្នកឆ្លើយសំណួរម្នាក់ដែលបានដឹងច្បាស់ថា ស្ត្រីម្នាក់ដែលត្រូវមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់រំលោភសេពសន្ថវៈ បាននិយាយថា ជនរងគ្រោះនោះនៅមានជីវិត "ប៉ុន្តែគ្រួសាររបស់នាងព្យាយាមលាក់រឿងនោះ។" អ្នកឆ្លើយសំណួរម្នាក់ ដែលជនរងគ្រោះពីការរំលោភសេពសន្ថវៈបានប្រាប់អាថ៌កំបាំងនោះបានរាយការណ៍ដោយភ័យញាប់ញ័រនៅក្នុងបទសម្ភាសន៍នោះថា ជនរងគ្រោះបានប្រាប់គូដណ្តឹងរបស់នាងអំពីការរំលោភសេពសន្ថវៈនេះ ដែលនាំឲ្យនាងមានផ្ទៃពោះ ហើយនាងបានរៀបការជាមួយគ្នា។ការមាក់ងាយនេះក៏ត្រូវបានកត់សម្គាល់តាមរយៈរបាយការណ៍ពីអ្នកឆ្លើយសំណួរដែលបានបកស្រាយអំពីការមើលងាយ ឬប្រមាថ ដែលជួនកាលជនរងគ្រោះបានទទួលរង ឬត្រូវអ្នកជុំវិញខ្លួនប្រាប់។ សាក្សីម្នាក់នៅក្នុងរឿងរំលោភសេពសន្ថវៈជាក្រុមបានរាយការណ៍ថា "ពួកទាហានបានចោទប្រកាន់ជនរងគ្រោះថា ជាស្រីពេស្យា និងពួកគេបាននិយាយថា ប្រសិនបើពីមុនមកស្ត្រីទាំងនោះមិនមែនជាស្ត្រីពេស្យាទេនោះពួកទាហានទាំងនោះមិនប្រព្រឹត្តចំពោះពួកគេបែបនោះទេ។ អ្នក ឆ្លើយសំណួរ ភេទស្រីម្នាក់ដែលបានរាយការណ៍ថា ប្រធានសហករណ៍ម្នាក់ ដែលនាងបានរស់នៅ ពេលនោះ ជុំវិញខ្លួនគាត់មានសុទ្ធតែ "ប្រពន្ធដ៏ស្រស់ស្អាតរបស់អ្នកផ្សេង" ដែលគាត់បានយកមកនៅពេលយប់។ ស្ត្រីម្នាក់នេះបានរៀបរាប់ដោយមើលងាយថា ស្ត្រីទាំងនោះ "រត់មករកគាត់មើលទៅដូចជាស្រី រត់ទៅស្វាគមន៍ម៉ូយអញ្ចឹង។"

ស្ត្រី និងបុរសដែលរស់នៅក្នុងសម័យខ្មែរក្រហមបានដឹង និងភ័យខ្លាចការគំរាមកំហែងនៃអំពើហិង្សាលើយេនឌ័រ និងបានព្យាយាមបង្កើតយុទ្ធសាស្ត្រ ដើម្បីលៃលកដោះស្រាយអំពើនេះ។ ជនរងគ្រោះ និងសាក្សីនៃអំពើហិង្សាលើយេនឌ័រមានទុក្ខព្រួយយ៉ាងខ្លាំងតាមរយៈអ្វីដែលពួកគេបានឃើញ និងជួបប្រទះ ប៉ុន្តែមិនសូវមានឱកាសនិយាយ ឬទទួលការគាំទ្រក្នុងការដោះស្រាយ

---

[៩១] ការមាក់ងាយនេះត្រូវបានចងក្រងច្បាស់លាស់នៅក្នុងឯកសារស្រាវជ្រាវស្តីពីអំពើហិង្សាលើយេនឌ័រនៅកម្ពុជា។ *សូមមើល ឧ.* Surtees, "Rapeand Sexual Transgression in Cambodia" ១០៩-១០៦ (ការលើកឡើងពីប្រភពមួយចំនួនរួមមាន បទសម្ភាសន៍របស់អ្នកនិពន្ធ ព្រមទាំងអ្នកប្រាជ្ញកម្ពុជា Ebihara និង Ledgerwood នៅក្នុងចំណុចនេះ)។ សូមមើល LICADHO, *Rape and Indecent Assault* ៥ ២៩ និង Amnesty International, *Breaking the Silence* ១៧-២០ (ការកត់សម្គាល់លើការបន្តអត្ថិភាពនៃការរើសអើងដ៏គួរកត់សម្គាល់លើជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ) ផងដែរ។

អ្វីដែលពួកគេបានពើបប្រទះនោះទេ។[៩២] លើសពីនេះទៅទៀត មានភស្តុតាងគ្រប់គ្រាន់ថា ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រស្ទាក់ស្ទើរមិនហ៊ាននិយាយ និងដែលមានការមាក់ងាយជាអវិជ្ជមានពាក់ព័ន្ធនឹងជនរងគ្រោះអំពើហិង្សាលើយេនឌ័រ ដែលបញ្ហានេះទំនងជាធ្វើឲ្យពួកគេនៅស្ងៀមមិននិយាយចេញមក។

### ៥.៣.៣ ជនរងគ្រោះ និងជោគវាសនារបស់ពួកគេ

នៅក្នុងករណីទាំងអស់ លើកលែងតែ៤ករណីប៉ុណ្ណោះ ស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រដែលត្រូវបានរាយការណ៍នៅក្នុងការសិក្សានេះ។ វាស្របគ្នានឹងព័ត៌មានដែលត្រូវបានកំណត់នៅក្នុងការសិក្សាផ្សេងទៀត និងការទទួលស្គាល់ជាទូទៅចំពោះអ្នកគាំទ្រ និងអ្នកសិក្សាស្រាវជ្រាវថាស្ត្រីនិងកុមារភាគច្រើនជាជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ។[៩៣] ក្រៅពីសំណួរអំពីភេទរបស់ជនរងគ្រោះ អ្នកឆ្លើយសំណួរជាច្រើនបានសង្កត់ធ្ងន់នៅក្នុងបទសម្ភាសន៍របស់ពួកគេថា ជាពិសេសពួកគេជឿថា ជនជាតិវៀតណាមដែលមានស្បែកស្អាតគួរសម និង "ប្រជាជនថ្មី" បានសំដៅទៅលើអំពើហិង្សាលើយេនឌ័រដែលបង្កឡើងដោយខ្មែរក្រហម។ នេះអាចជាករណីមួយនៅក្នុងស្ថានភាពមួយចំនួនជាពិសេស កន្លែងដែលជនរងគ្រោះត្រូវគេរំលោភជាក្រុម។ ទោះជាយ៉ាងនោះក្តីអ្នកឆ្លើយសំណួរនៅក្នុងការអង្កេតនេះក៏បានរាយការណ៍ផងដែរអំពីអំពើហិង្សាលើយេនឌ័រចំនួនដ៏ច្រើនដែលបានគេប្រព្រឹត្តមកលើប្រជាជនមូលដ្ឋាន ជាពិសេសការរំលោភសេពសន្ថវៈ និងការកេងប្រវ័ញ្ចផ្លូវភេទដែលបានកើតឡើងដដែលៗនៅក្នុងសហករណ៍។ ឧទាហរណ៍បង្ហាញមួយគឺជនរងគ្រោះដោយការរំលោភសេពសន្ថវៈ និងមានគភ៌បីនាក់នៅខេត្តស្វាយរៀងបានរៀបរាប់ពីមុនមកនៅក្នុងរបាយការណ៍នេះ។[៩៤] ពួកគាត់ត្រូវបានរបបនេះចាត់ថ្នាក់ជាប្រជាជនមូលដ្ឋាន ប៉ុន្តែត្រូវមន្ត្រីមូលដ្ឋានម្នាក់រំលោភសេពសន្ថវៈម្តងហើយម្តងទៀត។

[៩២] អ្នកដែលត្រូវបានគេសម្ភាសន៍ជាច្រើននាក់ ក្នុងការស្ទង់មតិនេះ បានបង្ហាញពីការភ្ញាក់ផ្អើលពេលដែលអ្នកសួរសំនួរចង់ពិភាក្សារ អំពីអំពើហិង្សាលើយេនឌ័រជាមួយពួកគេ។ រួមទាំងអ្នកដែលត្រូវបានគេសម្ភាសន៍មួយចំនួន អ្នករស់រានមានជីវិតពីការរំលោភ បានសំដែងការដឹងគុណចំពោះឱកាសដើម្បីចែករំលែកព័ត៌មានពីអំពើហិង្សាលើយេនឌ័រ ហើយភ្ញាក់ថាពុំមាននរណាម្នាក់ធ្លាប់សួរពួកគេពីបញ្ហានេះពីមុនមកទេ។

[៩៣] Nakagawa, *Gender-Based Violence* ២៧-២៨ (កត់សម្គាល់ថា មានតែឧប្បទ្វវហេតុដែលត្រូវបានរាយការណ៍២ ករណីរប៉ុណ្ណោះ នៅក្នុងការសិក្សារបស់អ្នកស្រីដែលពាក់ព័ន្ធនឹងការរំលោភបុរស) Toy-Cronin, *"I Want to Tell You"* ១៨ (សំដៅចំពោះដំណើររឿងសាក្សីផ្ទាល់ក្មែកបីនាក់អំពីអំពើហិង្សាផ្លូវភេទលើបុរសនៅក្នុងទិន្នន័យក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ្នាំ២០០៦ ប៉ុន្តែក៏បានកត់សម្គាល់ថា លក្ខណៈនៃការសិក្សានេះ និងការមាក់ងាយដ៏គួរឲ្យកត់សម្គាល់មកលើបុរសជាជនរងគ្រោះប្រហែលជាមានរបាយការណ៍មិនច្បាស់លាស់អំពីអព្ភូតហេតុនេះទេ)។ សូមមើល Ward, *Sexual Violence Against Women* ១៥ (ការទទួលស្គាល់ថា កុមារា និងបុរសអាចទទួលរងនូវអំពើហិង្សាលើយេនឌ័រ ប៉ុន្តែវិសមភាពអំណាច ដែលជាមូលដ្ឋានគ្រឹះនៃអំពើហិង្សាលើយេនឌ័រ គួបផ្សំនឹងឋានៈតូចជាងរបស់ស្ត្រីនៅគ្រប់សង្គមជាក់ស្តែង មានន័យថា ស្ត្រី និងកុមារីគឺជាចំណុចដៅចម្បងនៃអំពើហិង្សាលើយេនឌ័រ នៅទូទាំងពិភពលោក) ផងដែរ។

[៩៤] ខាងដើមទំព័រទី ៤៧។

បទសម្ភាសន៍សម្រាប់ឆ្លើយសំណួរក៏បានលើកឡើងផងដែរថា អំពើហិង្សាលើយេនឌ័របានកើតឡើងនៅក្នុងអ្នកមានតួនាទីរបស់ខ្មែរក្រហម។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់បានរាយការណ៍ថា "ប្រធានសន្តិសុខបានរំលោភសេពសន្ថវៈសមាជិកបុគ្គលិកម្នាក់របស់អង្គការថ្នាក់លើ ហើយ នាងនោះមានផ្ទៃពោះ។ នៅពេលដែលអ្នកឆ្លើយសំណួរផ្សេងទៀតបានដឹងពីសកម្មភាពទាំងនោះ គាត់បានបាញ់សម្លាប់ខ្លួនជាជាងមានបញ្ហាជាមួយអង្គការ។" អ្នកឆ្លើយសំណួរភេទស្រីម្នាក់ទៀតត្រូវបានគេប្រាប់គាត់ថា ប្រធានក្រុមខ្មែរក្រហមភេទស្រីវ័យក្មេងម្នាក់បានរើទៅនៅជាមួយបុរសថ្នាក់លើរបស់នាង។ ប៉ុន្តែនៅពេលដែលម្ដាយនាងបានដឹងពីការរៀបចំនេះ ហើយបានព្យាយាមជួបមុខកូនស្រីរបស់ខ្លួននាងបានដឹងថា កូនស្រីរបស់នាងត្រូវគេសម្លាប់បាត់ទៅហើយ។ សមាជិកសហគមន៍បានជឿថាកូនស្រីរបស់ស្ត្រីនោះត្រូវបានគេបង្ខំឲ្យបម្រើរ សេវាផ្លូវភេទដល់មេរបស់នាង។ ករណីទាំងនេះបង្ហាញថា ស្ត្រីមកពីសាវតាផ្សេងៗគ្នា ត្រូវបានគេរំលោភនៅក្នុងរបបនេះ។ បំណែងចែកជារួមមួយដែលទំនងជាភ្ជាប់ជនរងគ្រោះទាំងអស់នៅក្នុងការសិក្សានេះ គឺជាភាពងាយរងគ្រោះរបស់ពួកគេ ក្នុងកាលៈទេសៈដែលអ្នកពាក់ព័ន្ធនឹងរបបនេះតែងតែត្រួតត្រាស្ទើរទាំងអស់លើគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅរបស់ជនរងគ្រោះត្រូវបានបញ្ចុះបញ្ចូលឲ្យមើលប្រជាជនណាដែលមានការសង្ស័យ និងការមាក់ងាយ ហើយជារឿយៗមិនត្រូវបានឲ្យទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេទេ។ កាលៈទេសៈទាំងនេះបានធ្វើឲ្យប្រជាជនភាគច្រើនងាយរងគ្រោះ និងបានផ្តល់ឱកាសឲ្យមានអំពើហិង្សាលើយេនឌ័រ និងការរំលោភបំពានផ្សេងទៀតពីពួកខ្មែរក្រហម។ ប៉ុន្តែនៅក្នុងករណីរបស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រ ភាពងាយរងគ្រោះទំនងនឹងកើនឡើងដោយសារឋានៈក្នុងរបបនេះ ឬដោយសារកាលៈទេសៈបែបណាមួយរបស់បុគ្គលម្នាក់ៗ។

> "អ្នកនៅលីវនៅក្នុងកងចល័តតែងតែទទួលរងបញ្ហាបែបនេះ ប៉ុន្តែពួកយើងដែលមានគ្រួសារ និងអ្នកដែលស្នាក់នៅក្នុងភូមិ...មិនបានទទួលរងបញ្ហាបែបនេះទេ។"
>
> *--អ្នកឆ្លើយសំណួរភេទប្រុសនៅខេត្តបាត់ដំបងបាននិយាយយោងទៅភាពងាយរងគ្រោះពិសេសរបស់ស្ត្រីដែលធ្វើការនៅក្នុងកងចល័ត*

ឧទាហរណ៍ ស្ត្រីដែលត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងកងចល័ត ទទួលបានការការពារតិចតួចពីអំពើហិង្សា។ នៅក្នុងការរំលោភជាច្រើនករណីដូចបានរៀបរាប់នៅក្នុងការអង្កេតនេះតាមរាយការណ៍មកថា អំពើហិង្សាលើយេនឌ័របានកើតឡើងនៅឆ្ងាយពីភូមិ ហើយអ្នកឆ្លើយសំណួរបានប្រទះឃើញខណៈពេលដែលពួកគេធ្វើដំណើរ និងធ្វើការនៅក្នុងកងចល័ត។ នៅក្នុងអង្គភាពទាំងនេះជារឿយៗស្ត្រីធ្វើពលកម្មរហូតដល់យប់ និងនៅកន្លែងឆ្ងាយពីគេឯង។ នៅក្នុងករណីផ្សេងទៀត ភាពងាយរងគ្រោះរបស់ជនរងគ្រោះអាចត្រូវបានកើនឡើងដោយសារប្តី ឬសមាជិកគ្រួសារមិននៅ ដូច្នេះហើយបានជាជនដៃដល់ងាយស្រួលប្រព្រឹត្តអំពើហិង្សា។ នៅក្នុងករណីដែល

## របកគំហើញ

ប្រជាជនទូទៅសំដៅចំពោះការធ្វើទុក្ខបុកម្នេញ ដូចជា "ប្រជាជនថ្មី" និងជនជាតិវៀតណាម ស្ថានភាពងាយរងគ្រោះនៅក្នុងរបបនេះបានកើនឡើង ដោយសារការពិតថា ពួកគេត្រូវគេចាត់ទុកថាជា "ខ្មាំង"។ លើសពីនេះទៅទៀតនៅក្នុងឧទាហរណ៍ដែលបានរៀបរាប់ជាច្រើន អ្នកឆ្លើយសំណួរបានរាយការណ៍ថា ជនរងគ្រោះដែលជាអ្នកទីក្រុងត្រូវបានជេរប្រមាថថាជា "ស្រីពេស្យា"។ នៅក្នុងឧទាហរណ៍មួយ អ្នកឆ្លើយសំណួរភេទស្រីម្នាក់មកពីខេត្តបាត់ដំបងបានរាយការណ៍ថា "ពួកទាហានបានចោទប្រកាន់ជនរងគ្រោះថាជាស្រីពេស្យា ហើយពួកគេបាននិយាយថា ប្រសិនបើស្ត្រីមិនបានធ្វើជាស្រីពេស្យាពីមុនមកទេនោះ ពួកទាហានទាំងនេះប្រហែលជាមិនបានប្រព្រឹត្តចំពោះពួកគេបែបនោះទេ។ ពាក្យនេះអាចសំដៅទៅលើការពិតថា បុគ្គលនោះជា "ប្រជាជនថ្មី" (ជាមួយនឹងចំនុចផ្សេងៗទៀតជាអវិជ្ជមានទាក់ទងនឹងផ្នត់គំនិតរបស់ខ្មែរក្រហម) និងក៏និយាយអំពីអត្តចរិតខ្វះសីលធម៌ដែលជាខ្មាំងនៃបដិវត្តន៍។

ផ្អែកលើរបកគំហើញនៃការសិក្សានេះ ជោគវាសនារបស់ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រនេះមានលក្ខណៈស្មុគស្មាញណាស់។ ទោះបីជាគេរាយការណ៍ថាជនរងគ្រោះជាច្រើនត្រូវគេសម្លាប់ចោល ហើយជនរងគ្រោះផ្សេងទៀតបានសម្លាប់ខ្លួនដើម្បីគេចពីការដាក់ទណ្ឌកម្មក៏ដោយ ក៏ជនរងគ្រោះពីការរំលោភសេពសន្ថវៈម្នាក់ និងជនរងគ្រោះពីការរំលោភបំពានខាងផ្លូវភេទជាច្រើនត្រូវបានសម្គាល់សម្រាប់ការសិក្សានេះ។ អ្នកឆ្លើយសំណួរជាច្រើនដែលត្រូវបានសម្ភាសនៅក្នុងការសិក្សានេះបានអះអាងថាបានស្គាល់ជនរងគ្រោះ ដែលនៅមានជីវិតពីការរំលោភសេពសន្ថវៈនិងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងឧទាហរណ៍មួយអ្នកឆ្លើយសំណួរភេទប្រុសបានរៀបរាប់ពីរបៀបដែលស្ត្រីម្នាក់ត្រូវគេរំលោភរួចទុកចោលនៅជិតវត្តក្បែរនោះ។ ស្ត្រីម្នាក់នោះបានរួចជីវិត និងបានដើរទ្រេតទ្រោតត្រឡប់ទៅកាន់ភូមិវិញហើយត្រូវបានអ្នកស្រុកជួយ។ គាត់បានរាយការណ៍ ថាក្រោយមកស្ត្រីនេះបានធ្វើចំណាកស្រុកទៅសហរដ្ឋអាមេរិក។ នៅក្នុងរឿងរ៉ាវផ្សេងទៀត អ្នកឆ្លើយសំណួរបានបញ្ជូនអ្នកស្រាវជ្រាវទៅរកជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រនៅក្នុងសហគមន៍របស់ពួកគេ។ ក្នុងករណីផ្សេងទៀត អ្នកឆ្លើយសំណួរបានរាយការណ៍ថា ពួកគេបានដឹងថា ជនរងគ្រោះទាំងនោះបានរួចជីវិតពីរបបខ្មែរក្រហម ប៉ុន្តែចាប់តាំងពីពេលនោះមកពួកគេមិនដឹងថា ជនរងគ្រោះនៅឯណាទេ។

### ៥.៣.៤ ជនដៃដល់ និងទណ្ឌកម្ម

សំណួរនៅក្នុងការអង្កេតនេះត្រូវបានរៀបចំឡើង ដើម្បីអនុញ្ញាតឲ្យអ្នកឆ្លើយសំណួរផ្តល់ឧទាហរណ៍ និងព័ត៌មានអំពីអំពើហិង្សាលើយេនឌ័រដោយមិនសំដៅចំពោះអត្តសញ្ញាណ ឬ ទំនាក់

ទំនងរបស់ជនដៃដល់ឡើយ។ ប៉ុន្តែនៅក្នុងករណីតែមួយប៉ុណ្ណោះអ្នកឆ្លើយសំណួរបានស្គាល់អត្តសញ្ញាណសមាជិកខ្មែរក្រហមថា ជាជនដៃដល់ក្នុងអំពើហិង្សាលើយេនឌ័រ ដែលត្រូវបានរាយការណ៍នៅទីនេះ។ ជនដៃដល់ត្រូវបានស្គាល់អត្តសញ្ញាណតាមរយៈឋានៈផ្សេងៗគ្នានៃឋានានុក្រមខ្មែរក្រហម រហូតដល់ថ្នាក់គណៈស្រុក។ ដូចដែលគេបានរំពឹងទុកនៅក្នុងរបបដែលព័ត៌មានត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹង ជាពិសេសព័ត៌មានស្ដីពីមេដឹកនាំថ្នាក់លើអ្នកឆ្លើយសំណួរ មិនបានផ្ដល់ព័ត៌មានអំពីអ្នកដែលអាចដឹងអំពីអំពើហិង្សាលើសពីនេះនោះទេ។

> "មនុស្សសាមញ្ញគ្រាន់តែគិតពីក្រពះរបស់ពួកគេប៉ុណ្ណោះ។ ពួកគេមិនមានអាហារគ្រប់គ្រាន់ ដើម្បីពិចារណាធ្វើរឿងបែបហ្នឹងនោះទេ។"
>
> *–អ្នកឆ្លើយសំណួរភេទស្រីដែលមានវ័យ៦៩ឆ្នាំ នៅខេត្តបាត់ដំបង បានឆ្លើយសំណួររបស់អ្នកសម្ភាសន៍ថា ក្រៅពីខ្មែរក្រហម តើប្រជាជនធ្លាប់ប្រព្រឹត្តអំពើហិង្សាលើយេនឌ័រដែរឬយ៉ាងណា*

នៅក្នុងករណីភាគច្រើនទោះបីជាពេលវេលាបានកន្លងផុតទៅ ហើយការពិតថា គេមិនដែលបានសួរនាំពួកគេអំពីហេតុការណ៍នានា ដែលត្រូវបានរៀបរាប់នៅក្នុងបទសម្ភាសន៍ទាំងនេះក៏ដោយ ក៏អ្នកឆ្លើយសំណួរអាចស្គាល់ឈ្មោះជនដៃដល់ពិតប្រាកដនៃអំពើហិង្សាលើយេនឌ័រដែលពួកគេបានរាយការណ៍។ អ្វីដែលមិនគួរឲ្យភ្ញាក់ផ្អើលនោះគឺថា នេះគឺជារឿងទូទៅបំផុតនៅពេលដែលហេតុការណ៍ដែលបានរៀបរាប់បានកើតឡើងនៅក្នុងសហគមន៍របស់ពួកគេ ឬបានកើតឡើងជារឿយៗ។ នៅក្នុងសហគមន៍ជាច្រើនដែលគេបានធ្វើបទសម្ភាសន៍ទាំងនេះអ្នកឆ្លើយសំណួរភាគច្រើនបានរៀបរាប់អំពីករណីផ្សេងៗគ្នានៃអំពើហិង្សាលើយេនឌ័រ ដែលបុគ្គលដដែលបានប្រព្រឹត្ត និង/ឬបានរាយការណ៍ដោយឯករាជ្យអំពីករណីតែមួយគត់ដែលគេបានដឹងឮច្រើនអំពីអំពើហិង្សាលើយេនឌ័រ។ នៅក្នុងករណីនៃអំពើហិង្សាលើយេនឌ័រដែលត្រូវបានប្រព្រឹត្តនៅឆ្ងាយពីភូមិ និងមកលើជនរងគ្រោះដែលធ្វើការនៅក្នុងកងចល័តតាមធម្មតា អ្នកឆ្លើយសំណួរមិនអាចកំណត់ជនដៃដល់ជាជាងបញ្ជាក់ថា ពួកគេជាកម្មាភិបាល ឬ ទាហានខ្មែរក្រហមផ្អែកលើលក្ខណៈ ខាងក្រៅរបស់ពួកគេនោះទេ។

គួរឲ្យកត់សម្គាល់ផងដែរថា អ្នកឆ្លើយសំណួរជាច្រើនដែលបានរស់នៅខេត្តស្វាយរៀងក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យបានតែងតាំងជនដៃដល់ក្នុងអំពើហិង្សាលើយេនឌ័រជា "ទាហានមកពីភូមិភាគនិរតី" ហើយអ្នកឆ្លើយសំណួរមួយចំនួនតូចបានគូសបញ្ជាក់ថា អំពើហិង្សាលើយេនឌ័រកាន់តែកើតមានជាញឹកញាប់ និង/ឬសាហាវ នៅពេលដែលកងទ័ព និងមេដឹកនាំមកពីភូមិភាគនិរតី និងតំបន់២៤ នៅខេត្តតាកែវចូលមកដល់។[៩៥] អ្នកឆ្លើយសំណួរភេទស្រីម្នាក់នៅខេត្តស្វាយ

[៩៥] ភូមិភាគនិរតីក្រោមរបបកម្ពុជាប្រជាធិបតេយ្យរួមមាន ខេត្តតាកែវ ព្រមទាំងតំបន់ផ្សេងទៀត ដែលបច្ចុប្បន្នមាន៖ ខេត្តកំពត កោះកុង កំពង់ស្ពឺ និងកណ្ដាល។

រៀងបានរៀបរាប់នៅក្នុងបទសម្ភាសន៍នេះថា "នៅពេលដែលកម្មាភិបាលមកពីតំបន់២៤ កាន់អំណាច ពួកគេចាប់ផ្តើមធ្វើទារុណកម្មគិលានុបដ្ឋាយិកា និងធ្វើបាបអ្នកស្រុក។" អ្នកឆ្លើយសំណួរ ភេទស្រីម្នាក់ដែលបានរស់នៅខេត្តស្វាយរៀងនៅឆ្នាំ១៩៧៧ បានរាយការណ៍ថា ពួកទាហានភូមិភាគនិរតីបួននាក់បានរំលោភសមាជិកសហករណ៍ម្នាក់ ក្នុងអំឡុងពេលដ៏អាក្រក់មួយនៅពេលដែលការសម្លាប់រង្គាលកំពុងកើតមាន។

អ្នកឆ្លើយសំណួរបានរៀបរាប់អំពីលទ្ធផលផ្សេងៗ សម្រាប់ជនដៃដល់ក្នុងអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម។ អ្នកឆ្លើយសំណួរបានរាយការណ៍ថា ជនដៃដល់ត្រូវបានដាក់ទណ្ឌកម្ម (សម្លាប់ឬបាត់ខ្លួន) ៤ករណី ដែលក្នុងនោះ៣ករណីពាក់ព័ន្ធនឹងពួកមន្ត្រីជាន់ខ្ពស់ ដែលបានប្រព្រឹត្តអំពើហិង្សាលើយេនឌ័រជាច្រើន ដែលគេបានដឹងច្រើននៅក្នុងសហគមន៍របស់ពួកគេ ហើយ១ករណីទៀតពាក់ព័ន្ធនឹងមេដឹកនាំកងកម្លាំងជាន់ទាប។ សូម្បីតែនៅក្នុងករណីដែលជនដៃដល់ទាំងនេះទទួលទណ្ឌកម្មក៏ដោយ ក៏ជួនកាលហេតុផលនៃការដាក់ទណ្ឌកម្មរបស់ពួកគេមិនច្បាស់លាស់នោះទេ។ លើសពីនេះទៅទៀត ក្នុងការផ្លាស់ប្តូរជោគវាសនាដ៏ព្រៃផ្សៃនេះ អ្នកឆ្លើយសំណួរក៏បានរាយការណ៍ផងដែរនៅក្នុងករណី២ ក្នុងចំណោមករណីទាំងនេះ ដែលជនរងគ្រោះ ក៏ដូចជាជនដៃដល់ត្រូវគេសម្លាប់ដោយឈរលើមូលដ្ឋានថា ទាំងជនរងគ្រោះ និងជនដៃដល់ត្រូវទទួលខុសត្រូវក្នុងការប្រព្រឹត្តកំហុសសីលធម៌នោះ។ នៅក្នុងករណីផ្សេងទៀត អ្នកឆ្លើយសំណួរអង្កេតបានរៀបរាប់ថា ជនដៃដល់ត្រូវបាន"ស៊ើបអង្កេត"ប៉ុន្តែមិនត្រូវបានរកឃើញថាមានទោស ហើយបានរត់គេចខ្លួននៅពេលដែលរបបនេះដួលរលំឬត្រូវអ្នកភូមិសម្លាប់ចោលបន្ទាប់ពីវៀតណាមចូលមកកាន់កាប់។

យ៉ាងហោចណាស់នៅក្នុងរបាយការណ៍ស្តីពីអំពើហិង្សាលើយេនឌ័រ ដែលប្រមូលបានតាមរយៈការសិក្សានេះ មានភស្តុតាងតិចតួចក្នុងការលើកឡើងថា ជនដៃដល់ដែលភាគច្រើនជាភ្នាក់ងារបុរសរបស់ខ្មែរក្រហម តែងតែបង្កឲ្យមានទង្វើបែបនេះ។ លើសពីនេះទៅទៀត នៅក្នុងករណីខ្លះដែលពួកគេត្រូវបានដាក់ទណ្ឌកម្ម វាមិនច្បាស់ទាំងស្រុងថា អំពើហិង្សាលើយេនឌ័រ គឺជាហេតុផលមួយសម្រាប់ដាក់ទោសពួកគេ។ នៅក្នុងករណីភាគច្រើន អាជ្ញាធរខ្មែរក្រហមបានដាក់ទណ្ឌកម្មទាំងជនរងគ្រោះ និងជនដៃដល់ចំពោះកំហុសផ្នែកសីលធម៌ ដោយគ្មានធ្វើកិច្ចប្រឹងប្រែងណាមួយដើម្បីកំណត់ថា អ្វីបានកើតឡើងពិតប្រាកដ ឬនរណាជាអ្នកទទួលខុសត្រូវ។

### ៥.៣.៥ ជនជាតិភាគតិច

អ្នកឆ្លើយសំណួរនៅក្នុងការអង្កេតនេះបានលម្អិតអំពីករណីជាច្រើនដែលជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រជាសមាជិកនៃក្រុមជនជាតិភាគតិច។ នៅក្នុងករណីនីមួយៗ អ្នកឆ្លើយសំណួរ

បានលើកឡើងថា អត្តសញ្ញាណជនជាតិភាគតិចរបស់ជនរងគ្រោះគឺជាកត្តាជំរុញមួយនាំឲ្យមានអំពើហិង្សា។ នៅក្នុងឧទាហរណ៍មួយ អ្នកឆ្លើយសំណួរភេទស្រីម្នាក់ដែលបានឃើញម្ដាយជនជាតិវៀតណាមម្នាក់ និងកូនរបស់គាត់ត្រូវរំលោភសេពសន្ថវៈនៅជិតវត្តមួយ បានរាយការណ៍ថា "ខ្មែរក្រហមដឹងថា ជនជាតិវៀតណាមនោះបានរត់ទៅវត្តមួយនៅខេត្តពោធិ៍សាត់ និងបានតាមពួកគេទៅដល់ទីនោះ ក្រោយមកក៏បានរំលោភ រួចសម្លាប់ចោល។" នៅក្នុងករណីមួយផ្សេងទៀតអ្នកឆ្លើយសំណួរបានរៀបរាប់ថាបានឃើញស្ត្រីជនជាតិចាមវ័យក្មេងពីរនាក់ ដែលត្រូវគេបង្ខំឲ្យរាំស្រាតនៅចំពោះមុខពួកទាហានខ្មែរក្រហម និងបានលើកឡើងថា ពួកទាហាន ទាំងនោះ ធ្វើដូច្នោះដើម្បីមើលសាច់ភ្លឺរលោងរបស់ពួកនាង។ ស្រដៀងគ្នានេះដែរ អ្នកឆ្លើយសំណួរម្នាក់ទៀតបានលើកឡើងថា ស្ត្រីជនជាតិចិនម្នាក់ជាចំណុចដៅនៃការរំលោភ ដោយសារតែនាងមានស្បែកស្រស់ស្អាត ដែលអ្នកឆ្លើយសំណួរបានចាត់ទុកថា "ស ដូចពងមាន់។"

## ៥.៣.៦ និន្នាការផ្សេងទៀត៖ ទីកន្លែង ការអនុវត្ត និងពេលវេលា

ទោះបីជាទិន្នន័យនៅក្នុងការសិក្សាស្រាវជ្រាវនេះ ត្រូវបានត្រូវបានប្រមូលដោយគ្មានលក្ខណៈជាតំណាងក៏ដោយ ក៏របកគំហើញមួយចំនួនបានលើកឡើងពីនិន្នាការនានាដែលគួរនឹងយកមកសិក្សា និងពិចារណាបន្ថែម។ ទិន្នន័យទី១ក្នុងចំណោមទិន្នន័យទាំងនេះនិយាយពីសារៈសំខាន់នៃទីកន្លែង។ បទសម្ភាសន៍ទាំងនេះត្រូវបានធ្វើឡើងនៅក្នុងស្រុកពីរនៃខេត្តនីមួយៗ ក្នុងចំណោមខេត្តទាំងពីរ មានជាអាទិ៍ ខេត្តបាត់ដំបង និងស្វាយរៀង។ ជួនកាលការអនុវត្តអំពើ ហិង្សាលើយេនឌ័រដែលត្រូវបានរាយការណ៍នៅក្នុងតំបន់ទាំងនេះមានលក្ខណៈផ្សេងគ្នាពីការអនុវត្តអំពើហិង្សាលើយេនឌ័រដែលត្រូវបានរាយការណ៍នៅក្នុងតំបន់ផ្សេងទៀត។ ឧទាហរណ៍របាយការណ៍ស្ទើរតែទាំងអស់អំពីការកាត់អវៈយវៈ និងការដាក់បង្ហាញជាសាធារណៈនូវប្រដាប់ភេទ ប្រដាប់បន្តពូជ និង រន្ធគូទត្រូវបានរាយការណ៍ថា បានកើតឡើងនៅក្នុងស្រុកមួយនៅខេត្តស្វាយរៀង។ ទោះបីជាអ្នកឆ្លើយសំណួរនៅក្នុងស្រុកទាំងពីរនៅខេត្តបាត់ដំបង និងស្រុកមួយទៀត នៅខេត្តស្វាយរៀងបានរាយការណ៍ថា បានឃើញសាកសពត្រូវគេកាត់អវៈយវៈភេទ សាកសពត្រូវគេរំលោភសេពសន្ថវៈដោយប្រើឧបករណ៍ណាមួយ ឬថែមទាំងអំពើកាត់អវៈយវៈភេទ ក៏ដោយក៏គ្មានរបាយការណ៍ណាមួយស្ដីពីប្រភេទនៃការដាក់បង្ហាញជាសាធារណៈដែលមានរៀបរាប់នៅក្នុងស្រុកមួយនេះត្រូវបានទទួលពីតំបន់ទាំងនេះ។ លើសពីនេះទៅទៀតការពិតថា ប្រដាប់បន្តពូជដែលត្រូវគេកាត់ទាំង

> អំពើរំលោភ សេពសន្ថវៈបានរីករាលដាលពីភូមិមួយទៅភូមិមួយៗ
>
> *–អ្នកឆ្លើយសំណួរភេទស្រីបានធ្វើការនៅក្នុងកងចល័តនៅខេត្តស្វាយរៀង។*

នោះត្រូវបានដាក់បង្ហាញជាសាធារណៈនៅមូលដ្ឋានខ្មែរក្រហមនោះ ទំនងជាលើកឡើងថាមេដឹកនាំខ្មែរក្រហមនៅក្នុងតំបន់នេះមិនត្រឹមតែបានដឹងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបណ្តោយឲ្យកាត់អវៈយវៈភេទ និងទណ្ឌកម្មផ្លូវភេទទៀតផង។ រាល់ការរំលោភជាក្រុមដែលអ្នកឆ្លើយសំណួរបានរាយការណ៍នៅក្នុងការអង្កេតនេះ បានកើតឡើងនៅភាគខាងលិច នៃខេត្តស្វាយរៀង ព្រៃវែង ពោធិ៍សាត់ និងភាគខាងនៃកើតនៃខេត្តបាត់ដំបង។ ដោយហេតុតែខ្មែរក្រហមបានជម្លៀសប្រជាជនភាគច្រើននៅភាគខាងកើតនៃខេត្តស្វាយរៀងទៅតំបន់ភាគខាងលិចបានជានិន្នាការនេះបានលើកឡើងថាអំពើហិង្សាផ្លូវភេទ អាចនឹងត្រូវបានផ្តោតសំខាន់នៅក្នុងតំបន់ដែលប្រជាជនត្រូវគេជម្លៀសបានតាំងលំនៅនៅទីនោះ។ ការនេះត្រូវបានរាយការណ៍បន្ថែមដោយប្រាកដថា អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍អំពីការរំលោភជាក្រុមភ្លាមៗបន្ទាប់ពីការដួលរលំនៃរាជធានីភ្នំពេញនៅជិតពាក់កណ្តាលឆ្នាំ ១៩៧៥ ក្នុងអំឡុងពេលមានចលនាទ្រង់ទ្រាយធំរបស់ប្រជាជនពីខេត្តស្វាយរៀងនៅឆ្នាំ១៩៧៧ និង១៩៧៨ និងថ្ងៃចុងក្រោយនៃរបបខ្មែរក្រហម។ ការអង្កេតនេះក៏បានលើកឡើងផងដែរអំពីការប្រមូលផ្តុំទង្វើមួយចំនួននៃអំពើហិង្សាលើយេនឌ័រនៅក្នុងតំបន់ និងពេលណាមួយ។

# ៦. សេចក្តីសន្និដ្ឋាន



ទិន្នន័យដែលប្រមូលបានពីការសិក្សានេះកាន់តែលម្អិតថែមទៀតទៅលើបែបបទ និងលក្ខណៈសម្គាល់នៃអំពើហិង្សាលើយេនឌ័រ ដែលត្រូវបានប្រព្រឹត្តដោយភ្នាក់ងារខ្មែរក្រហមក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងការសិក្សាស្រាវជ្រាវពីមុនមក។ អំពើហិង្សាលើយេនឌ័រគ្រប់ប្រភេទដែលត្រូវបានកំណត់នៅក្នុងការសិក្សាស្រាវជ្រាវពីមុនមក ក៏ត្រូវបានរាយការណ៍នៅក្នុងការសិក្សានេះផងដែរ។ លក្ខណៈសម្គាល់សំខាន់ៗបន្ថែមទៀតអំពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម ដែលមិនសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវពីមុនមកក៏ត្រូវបានរកឃើញផងដែរ។ ជាពិសេស អ្នកឆ្លើយសំណួរនៅក្នុងការសិក្សានេះបានគូររូបភាពនៃការផ្លាស់ប្តូរទម្លាប់អនុវត្តទាក់ទងនឹងការអនុវត្តន៍គោលនយោបាយរបស់ខ្មែរក្រហមប្រឆាំងនឹងកំហុសសីលធម៌។ អ្នកឆ្លើយសំណួរទាំងនេះបានរៀបរាប់អំពីការដែលជនដៃដល់សម្លាប់ជនរងគ្រោះ ដើម្បីបិទបាំងលើឧក្រិដ្ឋកម្មរបស់ពួកគេ និងការធ្វើអត្តឃាតរបស់ជនរងគ្រោះ ក្នុងបំណងគេចពីទណ្ឌកម្មរបស់ខ្មែរក្រហម។ ប៉ុន្តែអ្នកឆ្លើយសំណួរក៏បានរៀបរាប់អំពីស្ថានភាពផ្សេងៗគ្នាជាច្រើន ដែលគោលនយោបាយខ្មែរក្រហមប្រឆាំងនឹងកំហុសសីលធម៌មិនត្រូវបានពង្រឹង ហើយប្រជាជនបានស៊ូទ្រាំនឹងអំពើហិង្សាលើយេនឌ័រក្នុងសម័យនោះ។

ផ្នែកសំខាន់មួយផ្សេងទៀតនៃរបកគំហើញការសិក្សាស្រាវជ្រាវទាំងនេះគឺ ព័ត៌មានពិស្តារដែលអ្នកឆ្លើយសំណួរបានផ្តល់លម្អិតអំពីប្រភេទនៃអំពើហិង្សាលើយេនឌ័រ ដែលបានកើតឡើងក្នុងតំបន់មួយចំនួន និងពេលពិសេសណាមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ទោះបីជារបកគំហើញទាំងនេះតម្រូវឲ្យមានការស៊ើបអង្កេតបន្ថែមក៏ដោយ ក៏ពួកគេបានផ្តល់នូវគន្លឹះដ៏សំខាន់ក្នុងការឈ្វេងយល់ពីរបៀបដែលអំពើហិង្សាលើយេនឌ័រត្រូវបានអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេស របៀបដែលអំពើហិង្សានេះភ្ជាប់ទំនាក់ទំនងទៅនឹងសកម្មភាព និងគោលនយោបាយនានារបស់មេដឹកនាំខ្មែរក្រហមក្នុងអម្លុងពេលនោះ។ ព័ត៌មានលម្អិតពាក់ព័ន្ធនឹងលក្ខណៈនៃអំពើហិង្សាលើយេនឌ័រនៅក្នុងតំបន់ភូមិសាស្ត្រ និងពេលវេលាណាមួយមិនត្រូវបានរាយការណ៍បញ្ចូលទៅក្នុងព័ត៌មានលម្អិតប្រភេទដូចគ្នានោះទេ ពីព្រោះវាមាននៅក្នុងការសិក្សានេះរួចទៅហើយ។

មិនដូចទិន្នន័យដែលត្រូវបានរាយការណ៍នៅក្នុងការសិក្សាផ្សេងទៀតនោះទេ អ្នកឆ្លើយសំណួរនៅក្នុងការសិក្សានេះក៏បានផ្តល់ព័ត៌មានលម្អិតកម្រិតខ្ពស់អំពីអត្តសញ្ញាណ និងជោគវាសនានៃជនដៃដល់ក្នុងអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។ លទ្ធផលអ្វីដែលជារូបភាពមិនច្បាស់លាស់អំពីរបៀបដែលគេស្គាល់ជនដៃដល់ក្នុងអំពើហិង្សាលើយេនឌ័រ ត្រូវបានប្រព្រឹត្តដោយមេដឹកនាំនៃរបបនេះ។ ការពិតថា ទំនងជាផ្តល់ឱកាសគ្រប់គ្រាន់ដើម្បីឲ្យជនដៃដល់បិទបាំងនូវទង្វើ

# សេចក្តីសន្និដ្ឋាន

របស់ពួកគេក្នុងករណីភាគច្រើនកង្វះគណនេយ្យភាព នៅពេលដែលករណីទាំងនោះត្រូវបានរកឃើញ ហើយសញ្ញានៃការលើកទឹកចិត្ត ឬការអត់ធ្មត់ចំពោះអំពើហិង្សាប្រភេទនេះបានលើកឡើងថា មានសក្តានុពលដែលបណ្តាលឲ្យមានអំពើហិង្សាលើយេនឌ័ររីករាលដាលបែបនេះ ទោះបីជាវាមិនត្រូវបានអនុវត្តជាសាធារណៈ ឬជាគោលនយោបាយផ្លូវការជាលក្ខណៈប្រព័ន្ធ ដែលត្រូវបានអនុវត្តនៅគ្រប់ផ្នែកនៃប្រទេសនេះ។ ទំនាក់ទំនងរវាងតួអង្គខ្មែរក្រហម និងអំពើហិង្សាលើយេនឌ័រដែលត្រូវបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងទង្វើមួយចំនួនដែលធ្វើជាសាធារណៈជាពិសេស ការកាត់អវៈយវៈភេទ និងការដាក់បង្ហាញផ្នែកនៃរាងកាយបានលើកឡើងពីលទ្ធភាពដែលគេប្រើអំពើហិង្សាលើយេនឌ័រជាឧបករណ៍មួយសម្រាប់ដាក់ទណ្ឌកម្មខ្លាំងនៃរបបនេះ និងបន្តត្រួតត្រាលើប្រជាជនសាមញ្ញតាមរយៈការធ្វើឲ្យភ័យខ្លាច និងការបំភ័យដោយអំពើហិង្សាផ្លូវភេទ។ គេត្រូវធ្វើការស្រាវជ្រាវបន្ថែមដើម្បីកំណត់ទំហំដែលការអនុវត្តន៍ផ្សេងទៀតនៃអំពើហិង្សាលើយេនឌ័រ ក៏គេអាចដឹងអត់ធ្មត់ ឬថែមទាំងត្រូវបានជំរុញដោយមេដឹកនាំខ្មែរក្រហម។

គួរកត់សម្គាល់ផងដែរថា តាមរយៈដំណើរការជ្រើសរើសដ៏សាមញ្ញនេះ យើងអាចកំណត់ និងសម្ភាសអ្នកឆ្លើយសំណួរ ដែលមានការយល់ដឹងទូលំទូលាយផ្ទាល់អំពីអំពើហិង្សាលើយេនឌ័រក្រោមរបបខ្មែរក្រហម។ ម៉្យាងទៀតទោះបីជាង៣០ឆ្នាំបានកន្លងផុតទៅចាប់តាំងពីការផុតរលត់នៃរបបកម្ពុជាប្រជាធិបតេយ្យក្តី ក៏អ្នកឆ្លើយសំណួរទាំងនេះអាចរំលឹកដល់ព័ត៌មានលម្អិតដ៏គួរកត់សម្គាល់អំពីព្រឹត្តិការណ៍ទាំងនេះ និងមានបំណងចែករំលែកអ្វីដែលពួកគេបានដឹងនេះដល់អ្នកស្រាវជ្រាវ។ ហេតុការណ៍ទាំងពីរនេះបញ្ជាក់ពីការរកឃើញលើកដំបូងរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដោយលើកឡើងថា ជនរងគ្រោះដោយអំពើហិង្សាលើយេនឌ័រគ្រប់រូបមិនមែនសុទ្ធតែត្រូវគេសម្លាប់ ឬស្លាប់នៅសម័យនោះទេ ហើយជនរងគ្រោះ និងសាក្សីនានាមានបំណងនិយាយអំពីបទពិសោធន៍របស់ពួកគេ។ ថ្វីបើមានបញ្ហាឈ្មនានាពាក់ព័ន្ធនឹងការស្រាវជ្រាវប្រភេទនេះក៏ដោយក៏វាច្បាស់ណាស់ថា ការអនុវត្តន៍បែបនេះអាចនាំឲ្យទទួលបានលទ្ធផលដ៏សំខាន់។

ផ្ទុយពីការយល់ឃើញរបស់សាធារណជន និងអ្នកជំនាញដែលថា អំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហមកម្រនឹងកើតឡើងណាស់ ការរកឃើញការស្រាវជ្រាវទាំងនេះបានលើកឡើងថា វាជាទិដ្ឋភាពដ៏សំខាន់ និងមានគេដឹងច្រើនអំពីការឈឺចាប់ដែលជនរងគ្រោះ និងអ្នករួចជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យបានទទួលរង។ ឥរិយាបថដែលនាំឲ្យខូចសារៈប្រយោជន៍នៃអំពើហិង្សាលើយេនឌ័រមិនគួរកើតឡើងជាការភ្ញាក់ផ្អើលមួយ ដោយសារតែអ្នកសិក្សាស្រាវជ្រាវ អ្នកគាំទ្រ និងសហគមន៍អន្តរជាតិទទួលស្គាល់ភាគច្រើនថា អំពើហិង្សាលើយេនឌ័រក្នុងពេលមានសង្គ្រាម និងជម្លោះជារឿយៗត្រូវបានកាត់បន្ថយ និងមើលរំលងបន្ទាប់ព្រឹត្តិការណ៍ទាំងនេះកើតឡើង។ លើស

# សេចក្តីសន្និដ្ឋាន

ពីនេះទៅទៀតដោយហេតុថាឋានៈរបស់ស្ត្រីនៅកម្ពុជា និងការពិតថា អំពើហិង្សាលើយេនឌ័រនេះបានកើតឡើងអស់រយៈពេលជាយូរ មុនពេលទស្សនាទានសហសម័យនៃឧក្រិដ្ឋកម្មទាំងនេះកើតឡើង ឬសង្គម ទទួលស្គាល់ថា តើគោលគំនិតទាំងនេះមានលក្ខណៈទូទៅ និងបំផ្លាញយ៉ាងណាខ្លះ គេមិនរំពឹងថា ការទទួលស្គាល់ឧក្រិដ្ឋកម្មទាំងនេះនឹងដំណើរការទៅឃើតយ៉ាវនោះទេ។ ប៉ុន្តែដោយហេតុថា ច្បាប់អន្តរជាតិ និងយន្តការគណនេយ្យភាពមានការរីកចម្រើនបានជាមានការយល់ដឹងកាន់តែច្រើនថែមទៀតអំពីការកើនឡើងនិងដំណើរការនៃអំពើហិង្សាលើយេនឌ័រនៅក្នុងស្ថានភាពមានជម្លោះ និងការសិក្សាស្រាវជ្រាវអំពីប្រធានបទនៅកម្ពុជា គឺជាបន្ទុករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជា តួអង្គរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការលើកឡើងពីបញ្ហាអំពើហិង្សាលើយេនឌ័រ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

ការស្រាវជ្រាវនេះបានលើកឡើងពីតម្រូវការបន្តកិច្ចប្រឹងប្រែងប្រកបដោយនិរន្តរភាព ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាលើយេនឌ័រក្នុងរបបខ្មែរក្រហម និងបង្កើតយុទ្ធសាស្ត្រនានាដើម្បីកំណត់ និងដោះស្រាយតម្រូវការរបស់ជនរងគ្រោះពីរបបនេះ។ បច្ចុប្បន្នការស្រាវជ្រាវនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ដើម្បីឲ្យមានប្រសិទ្ធភាព និងត្រឹមត្រូវតាមច្បាប់ គំនិតផ្តួចផ្តើមយុត្តិធម៌អន្តរកាល និងការកសាងសន្តិភាពត្រូវយកយេនឌ័រ និងអំពើហិង្សាលើយេនឌ័រមកពិចារណា។ អ្នកនិពន្ធនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា និងអ្នកដែលបានចូលរួមក្នុងការសិក្សានេះសង្ឃឹមថា ព័ត៌មានដែលត្រូវបានរកឃើញតាមរយៈការស្រាវជ្រាវនេះនឹងដើរតួជាកតាលីកក្នុងការលើកកម្ពស់ការយល់ដឹង និងលើកយកបញ្ហានៃអំពើហិង្សាលើយេនឌ័រ ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យមកពិភាក្សាជាផ្នែកដ៏សំខាន់ ខណៈពេលដែលការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរកាលបន្តទៅមុខ។ ដើម្បីជាប្រយោជន៍ក្នុងការលើកឡើងពីវិធានការជាក់ស្តែងដើម្បីសម្រេចបានគោលដៅនេះ យើងបានផ្តល់អនុសាសន៍ជាច្រើនដូចបានលើកឡើងនៅក្នុងផ្នែកសង្ខេបសំខាន់នៃរបាយការណ៍នេះ។



# ៧. អ្នកនិពន្ធនិងសេចក្ដីថ្លែងអំណរគុណ

## ៧.១ អ្នកឆ្លើយសំណួរ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកឆ្លើយសំណួរអង្កេតកម្ពុជាចំនួន១០៨នាក់ ដែលបានទទួលស្វាគមន៍យើងខ្ញុំនៅផ្ទះ និងនៅសហគមន៍របស់ពួកគាត់ ហើយបានចែករំលែករឿងរ៉ាវអំពីការឈឺចាប់ និងការរួចជីវិតផ្ទាល់ ព្រមទាំងការយល់ដឹងរបស់ពួកគាត់ អំពីអំពើហិង្សាលើយេនឌ័រដល់ក្រុមស្រាវជ្រាវនេះ។

## ៧.២ អ្នកនិពន្ធ

**Katrina Natale** បានចូលរួមក្នុងគម្រោងស្ដីពីអំពើហិង្សាលើយេនឌ័រ ក្នុងនាមជាសមាជិកក្រុមសិក្សាស្រាវជ្រាវនៅក្នុងឆ្នាំ២០១០ ខណៈពេលដែលអ្នកស្រីជានិស្សិតច្បាប់នៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ា បើខេលី។ អ្នកស្រីមានសញ្ញាបត្របរិញ្ញាបត្រផ្នែកសិក្សាអន្តរជាតិ និងវិទ្យាសាស្ត្រនយោបាយពីសាកលវិទ្យាល័យ អូរ៉េហ្គុន និងជាបេក្ខជន **2013 J.D.** ផ្នែកច្បាប់បើខេលី។ ពីមុនមកអ្នកស្រីបានធ្វើការសិក្សាស្រាវជ្រាវនៅសហរដ្ឋអាមេរិកប្រទេសឈីលី និងកម្ពុជា។ អ្នកស្រីក៏បានធ្វើការជាច្រើនពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ និងអំពើហិង្សាផ្លូវភេទជាមួយបណ្ដាអង្គការមិនរកកម្រៃនៅសហរដ្ឋអាមេរិក ប្រទេសឈីលី និងកម្ពុជា។

## ៧.៣ ក្រុមស្រាវជ្រាវ

**Katrina Natale** ជាសមាជិកក្រុមសិក្សាស្រាវជ្រាវ **PGBV** មានតួនាទីជាប្រធានក្រុមស្រាវជ្រាវសម្រាប់ការសិក្សានេះ។ បុគ្គលិក **PGBV** គ្រប់រូបបានលះបង់ពេលវេលា និងធនធានដ៏ច្រើនដល់ការអភិវឌ្ឍន៍ និងការអនុវត្តន៍ការសិក្សាស្រាវជ្រាវនេះ។ ការសិក្សាស្រាវជ្រាវនេះរួមមាន លោក ដួង សាវន អ្នកសម្របសម្រួលកម្មវិធី ហង្ស ចរិយា ជំនួយការច្បាប់ លាង ចរិយា ជំនួយការកម្មវិធីសារ សុភីរ៉ាឌី ជំនួយការកម្មវិធី **Beini Ye** ទីប្រឹក្សាគម្រោង និងយឹម សុធារី អ្នកគាំទ្រផ្លូវចិត្ត។ សូមថ្លែងអំណរគុណ ពិសេសចំពោះអ្នកប្រមូលទិន្នន័យ និងកម្មសិក្សាការីផ្នែករៀបចំទិន្នន័យ ដែលបានចូលរួមក្នុងគម្រោងនេះដោយក្ដីសាទរ និងបានលះបង់ពេលវេលា និងកិច្ចប្រឹងប្រែងដ៏មានតម្លៃក្នុងការធានាឲ្យបាននូវការប្រមូល និងការរៀបចំចងក្រងទិន្នន័យដ៏ច្រើនបែបនេះ។ ក្រុមទាំងនេះរួមមាន៖ ចាន់ សុវណ្ណរ៉ា ឆាយ បុប្ផា ឈឹម ស្រង់ឡង់ ជោ សម្ផស្ស ឈុន គីម៉េង ឈួន រដ្ឋមន្ទីជូ សុវសុទ្ធ ជួត គីរីយ៉ាតាវាស៊ី ដាវ លាក់ភក្តី ហាង មន្ទីជាត ហេង ចិន្តា ហៀង អេងទ្រី អ៊ិន សុភារុណកៅ កុលវ័ន្ត គួយ កក្កដា លីម ដារ៉ា លីម លាងហ៉ាង លុយ ចាន់រុន នី វិសុទ្ធ ផាន់ រដ្ឋា រឿង សុវត្ថិឌី

សាន ស៊ុន ស្មាន់ វណ្ណធីដា សុខ ហ៊ុចហុង វ៉ាន់ សូដាស៊ី និងអ៊ី ហ៊ួយគៀង។ យើងក៏សូមថ្លែងអំណរគុណចំពោះ ក្រុមហ៊ុន ទ្រែនយែរ ខូអិលធីឌី ដែលបានផ្តល់សេវាបកប្រែនៅក្នុងការសិក្សាស្រាវជ្រាវនេះ។

## ៧.៤ ដៃគូ និងទីប្រឹក្សា

ការស្រាវជ្រាវរបស់យើង ជាពិសេសសមាសភាពការងារមូលដ្ឋាន ពឹងផ្អែកយ៉ាងខ្លាំងទៅលើកិច្ចសហប្រតិបត្តិការ និងជំនួយរបស់អន្តរការីមូលដ្ឋានជាច្រើន។ ជំនួយរបស់ពួកគេក្នុងការដឹកនាំសហគមន៍មូលដ្ឋាន ស្គាល់អត្តសញ្ញាណអ្នកឆ្លើយសំណួរ សួរនាំព័ត៌មាន និងផ្តល់ទស្សនៈសំខាន់ៗអំពីបទពិសោធន៍មូលដ្ឋានក្នុងរបបខ្មែរក្រហម ដែលគេបញ្ជាក់ថាគ្មានតម្លៃ។ ទោះបីជាពួកគេនៅតែសុំមិនបញ្ចេញឈ្មោះនៅទីនេះក៏ដោយ ក៏យើងចង់ទទួលស្គាល់តួនាទីរបស់ពួកគេនៅក្នុងភាពជោគជ័យនៃគម្រោងនេះ។ ការសិក្សានេះមិនអាចធ្វើទៅបាន ដោយមិនបម្រើផលប្រយោជន៍ និងការគាំទ្រដល់ពួកគេនោះទេ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះបុគ្គលម្នាក់ៗ និងបណ្តាអង្គការនានាដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងការចូលរួមរបស់ពួកគេដើម្បីជួបពិភាក្សាជាមួយពួកយើងក្នុងអំឡុងពេលធ្វើការសិក្សានេះ៖ **Mychelle Balthazard** មជ្ឈមណ្ឌលវិបត្តិស្ត្រីកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជា **Theresa de Langis** អង្គការយេនឌ័រ និងការអភិវឌ្ឍន៍ **Henri Locard, Vichuta Ly, Kalyanne Mam, Laura McGrew, Kasumi Nakagawa** នី ចាន់ឌី សេវាសង្គមកម្ពុជា និង **Belgin Yigen** ។

## ៧.៥ អ្នកផ្តល់មូលនិធិ

អ្នកនិពន្ធ និងគម្រោងស្តីពីអំពើហិង្សាលើយេនឌ័រនៅក្នុងក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាសូមសំដែងនូវការដឹងគុណដ៏ស្មោះស្ម័គ្រចំពោះម្ចាស់ជំនួយ ដែលបានផ្តល់មូលនិធិសំខាន់ៗ និងការឧបត្ថម្ភគាំទ្រដល់គម្រោងនេះ។ **GIZ** ទីភ្នាក់ងារអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិបានផ្តល់មូលនិធិដល់ការបណ្តុះបណ្តាលការងារមូលដ្ឋាន ការរៀបចំទិន្នន័យ និងដំណាក់កាលវិភាគនៃគម្រោងនេះ។ អង្គការសហប្រជាជាតិស្ត្រីនៅកម្ពុជាបានផ្តល់ហិរញ្ញវត្ថុដល់គម្រោងនេះ និងការបោះពុម្ពផ្សាយរបាយការណ៍ស្រាវជ្រាវចុងក្រោយ។ សាលាច្បាប់ **Berkeley** នៅសាកលវិទ្យាល័យកាលីហ្វ័រញ៉ា **Berkeley** (សហរដ្ឋអាមេរិក) និងសមាគមស្ត្រី **Boalt Hall** អង្គការនិស្សិតនៅឯសាកលវិទ្យាល័យសំដៅលើកកម្ពស់សិទ្ធិស្ត្រីតាមរយៈច្បាប់ បានផ្តល់មូលនិធិលើកដំបូងដើម្បីគាំទ្រដល់សមាគមស្រាវជ្រាវសម្រាប់អ្នកនិពន្ធ **Katrina Natale**។ **GIZ** ក៏បានបរិច្ចាគមូលនិធិដើម្បីឲ្យអ្នកនិពន្ធបន្តការងារគម្រោងនេះ។

របាយការណ៍នេះរៀបចំដោយ:

ផ្តល់មូលនិធិ និងឧបត្ថម្ភដោយ: